សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច

Universite Royal de Droit et des Sciences Economiques

Royal University of law and Economics

# សារណាបញ្ចប់ការសិក្សា

# តួនាទីរបស់ចៅក្រមស៊ើបសួរ

ស្រាវជ្រាវពីថ្ងៃទី ១៨ ខែ មីនា ឆ្នាំ ២០១៩ ដល់ថ្ងៃទី ១៦ ខែ ឧសភា ឆ្នាំ ២០១៩

ស្រាវជ្រាវដោយ
និស្សិតឈ្មោះ លោក **ហង់ ភក្តី**
លោក **ស៊ឹម ឧត្តមច័ន្ទសក្កដា**

សាស្ត្រាចារ្យណែនាំ
លោក **ហ៊ាង ឡេង**

ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**
ជំនាន់ទី ១៩

ឆ្នាំចូលសិក្សា ២០១៥
ឆ្នាំសរសេរសារណា ២០១៩

# សេចក្តីថ្លែងអំណរគុណ

យើងខ្ញុំឈ្មោះ **ហង់ ភក្តី** និង **ស៊ឹម ឧត្តមច័ន្ទសក្កដា** គឺជានិស្សិតឆ្នាំទី៤ ថ្នាក់បរិញ្ញាបត្រ ផ្នែកនីតិសាស្ត្រ ជំនាន់ទី ១៩ ឆ្នាំសិក្សា ២០១៨-២០១៩ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច។

## សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ

អ្នកមានគុណទាំងពីរគឺ **លោកឪពុក និង អ្នកម្តាយ** ដែលជាអ្នកមានគុណដ៏ធំឧត្តុងឧត្តម ដែលបានផ្តល់កំណើតដល់កូន និងខិតខំចិញ្ចឹមបីបាច់ថែរក្សា អប់រំទូន្មានរូបកូនដោយបានជួយទំនុកបម្រុងកូនឱ្យបានទទួលនូវការអប់រំខ្ពង់ខ្ពស់ រហូតដល់បានបញ្ចប់ថ្នាក់បរិញ្ញាបត្រ ប្រកបដោយជោគជ័យគួរជាទីមោទនៈ។

**ឯកឧត្តមសាកលវិទ្យាធិការ សាកលវិទ្យាធិការរង ព្រឹទ្ធបុរស ថ្នាក់ដឹកនាំ មន្ត្រីការិយាល័យ និង លោកគ្រូ អ្នកគ្រូសាស្ត្រាចារ្យ** ទាំងអស់នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ចដែលបានផ្តល់នូវចំណេះដឹង ដំបូន្មានល្អៗដើម្បីបង្ហាត់បង្រៀន និងបានណែនាំដល់រូបខ្ញុំបាទទាំងពីរយ៉ាងយកចិត្តទុកដាក់ចាប់តាំងពីពេលចាប់ផ្តើមរ ហូតដល់ពេលបញ្ចប់ការសិក្សាបានយ៉ាងជោគជ័យ។

លោកពូ អ្នកមីង បងប្រុស បងស្រី មិត្តភក្តិរាល់គ្នា ដែលបានផ្តល់នូវការលើកទឹកចិត្តដល់យើងខ្ញុំ អោយខិតខំប្រឹងប្រែងរៀនសូត្ររហូតដល់បញ្ចប់ថ្នាក់បរិញ្ញាបត្រ។

ជាពិសេសយើងខ្ញុំ សូមថ្លែងអំណរគុណជូនចំពោះ **លោកសាស្ត្រាចារ្យណែនាំ ហ៊ាង ឡេង** ដែលលោកបានចំណាយពេលវេលាយ៉ាងមានតម្លៃក្នុងការត្រួតពិនិត្យ ពន្យល់ ណែនាំ ដល់យើងខ្ញុំ ដើម្បីសរសេរសារណាបញ្ចប់ការសិក្សានេះ បានយ៉ាងជោគជ័យ។

ជាចុងបញ្ចប់ យើងខ្ញុំសូមបួងសួងដល់បារមីនៃវត្ថុស័ក្តសិទ្ធិទាំងពួងនៅលើលោកយើងនេះ មេត្តាថែរក្សាអ្នកមានគុណទាំងពីរ ឯកឧត្តមសាកលវិទ្យាធិការ សាកលវិទ្យាធិការរង ព្រឹទ្ធបុរស ថ្នាក់ដឹកនាំ មន្ត្រីការិយាល័យ និងលោកគ្រូ អ្នកគ្រូសាស្ត្រាចារ្យ លោកពូអ្នកមីង បងប្រុស បងស្រី និង មិត្តភក្តិគ្រប់គ្នា ជាពិសេស លោកសាស្ត្រាចារ្យណែនាំ **ហ៊ាង ឡេង** សូមឲ្យជួបប្រទះតែសេចក្តីសុខ សេចក្តីចម្រើន គ្រប់ពេលវេលា។

# អារម្ភកថា

ដោយបានសិក្សាអស់រយៈពេល ៤ ឆ្នាំ នៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចកន្លងមក គឺជារយៈពេលមួយដែលយើងខ្ញុំទាំងពីរនាក់បានខិតខំប្រឹងប្រែងក្នុងការសិក្សាស្រាវជ្រាវយ៉ាងយកចិត្តទុកដាក់ និងការប្រឹងប្រែងស្តាប់សាស្ត្រាចារ្យពន្យល់ដោយយកចិត្តទុកដាក់ដើម្បីជាទន់ក្នុងការសរសេរសារណាឱ្យបានល្អប្រសើរឡើង។

បន្ទាប់ពីបានសិក្សាមុខវិជ្ជាជាច្រើន នៅក្នុងសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ផ្នែកនីតិសាស្ត្រ យើងខ្ញុំទាំងពីរយល់ឃើញថា មានមុខវិជ្ជាៈច្រើនណាស់ដែលសុទ្ធសឹងតែមានប្រយោជន៍ និងសំខាន់សម្រាប់សិស្សានុសិស្ស។ ប៉ុន្តែនៅក្នុងឱកាសនេះ យើងសូមសម្រេចចិត្តជ្រើសរើសប្រធានបទ **"តួនាទីរបស់ចៅក្រមស៊ើបសួរ"** យកមកសរសេរសារណាបញ្ចប់ថ្នាក់បរិញ្ញាបត្រដោយមូលហេតុចង់ឱ្យច្បាស់អំពីកាតព្វកិច្ច ក៏ដូចជាតួនាទីរបស់ចៅក្រមស៊ើបសួរ។

ស្នាដៃមួយនេះ នឹងចូលរួមចំណែកក្នុងការពង្រឹងនីតិរដ្ឋ ក៏ដូចជាលើកស្ទួយវិស័យយុត្តិធម៌តាមរយៈខ្លឹមសារនៃប្រធានបទ ដែលបង្ហាញជនរួមជាតិ និងសាធារណៈមតិទូទៅអំពីគោលបំណង និងការប្តេជ្ញាចិត្តរបស់អ្នករៀបរៀង។

ប្រធានបទរបស់យើងខ្ញុំ គឺផ្តោតសំខាន់ទៅលើ តួនាទីរបស់ចៅក្រមស៊ើបសសួរ ក្នុងក្របខណ្ឌ ក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧ ដែលបានផ្តល់នូវសិទ្ធិស្របច្បាប់ចំពោះចៅក្រមស៊ើបសួរក្នុងដំណាក់កាលនីមួយៗ ដើម្បីស្វែងរកការពិតជូនជនរងគ្រោះ និងប្រជាពលរដ្ឋ។

យើងខ្ញុំសំណូមពរឱ្យជនរួមជាតិទាំងអស់ ពិសេសស្ថាប័នតុលាការ ស្ថាប័ននគរបាលយុត្តិធម៌ និងស្ថាប័នអនុវត្តច្បាប់នានាផ្តល់ការគាំទ្រ ជាពិសេសចៅក្រមស៊ើបសួរ ដោយចូលរួមអនុវត្តយ៉ាងសកម្មនូវតួនាទី និងភារកិច្ចរបស់ខ្លួន ដើម្បីឱ្យទៅជាចលនារួមដ៏ខ្លាំងក្លា សំដៅសម្រេចឱ្យបាននូវជោគជ័យជាផ្លែផ្កា សម្រាប់ឧត្តមប្រយោជន៍របស់ប្រទេសកម្ពុជាលើវិស័យយុត្តិធម៌។

ដោយសារតែ សៀវភៅនេះ គឺជាស្នាដៃដំបូងរបស់យើងខ្ញុំ ហេតុនេះយើងជឿជាក់ថា ពិតជាមានការខ្វះខាត និងមានកំហុសខ្លះៗជាក់ជាមិនខានឡើយ។ ដូច្នេះយើងខ្ញុំរង់ចាំទទួលដោយក្តីសោមនស្ស នូវរាល់ការរិះគន់ដើម្បីកែលំអក្នុងន័យស្ថាបនាចំពោះស្នាដៃមួយនេះគ្រប់ពេលវេលា។

យើងខ្ញុំសូមសម្តែងនូវសេចក្តីគោរព និងការដឹងគុណដ៏ជ្រាលជ្រៅបំផុត ជូនជនរួមជាតិនៅគ្រប់ទិសទីដែលបានផ្តល់នូវជំនឿ និងការគាំទ្រយ៉ាងធំធេងដល់ស្នាដៃនេះ។ ដោយផ្អែកទៅលើមូលដ្ឋាននៃការគាំទ្រនេះហើយ អ្នករៀបរៀងប្តេជ្ញាប្រមូលផ្តុំកម្លាំងកាយ-ចិត្ត និងប្រាជ្ញា ព្រមទាំងចំណេះដឹងដែលមានពីការសិក្សាស្រាវជ្រាវមកធ្វើការរៀបរៀង ចងក្រង ដើម្បីពន្យល់បកស្រាយឱ្យបានលំអិតលើប្រធានបទស្តីពី **"តួនាទីរបស់ចៅក្រមស៊ើបសួរ"** ។

# មាតិកា

**ទំព័រ**

**សេចក្តីផ្តើម** ........ ១

**ជំពូកទី១**

**ការស្រាវជ្រាវរបស់ចៅក្រមស៊ើបសួរ**

**ផ្នែកទី១ កិច្ចស្រាវជ្រាវទៅលើអង្គហេតុដោយចៅក្រមស៊ើបសួរ** ........ ៤

**កថាខណ្ឌទី១ គោលការណ៍នៃការស៊ើបសួរ** ........ ៥

ក. គោលបំណងនៃការបើកការស៊ើបសួរ ........ ៦

ខ. ការស្រាវជ្រាវចំពោះបុគ្គលិកលក្ខណៈរបស់ជនត្រូវចោទ ........ ៦

គ. សមត្ថកិច្ចដែនដីរបស់ចៅក្រមស៊ើបសួរ ........ ៦

**កថាខណ្ឌទី២ វិធីសាស្ត្រស្រាវជ្រាវរបស់ចៅក្រមស៊ើបសួរ** ........ ៧

ក. ការជូនដំណឹងអំពីការដាក់ឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យ ........ ៧

ខ. ការសួរចម្លើយជនត្រូវចោទ ........ ៩

គ. ការស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី ........ ១០

ឃ. ការស្តាប់ចម្លើយសាក្សី ........ ១១

ង. ការឆែកឆេរ និងការចាប់យកវត្ថុតាង ........ ១៣

ច. ការធ្វើកោសលវិច្ច័យ ........ ១៤

ឆ. ការស្តាប់ទូរស័ព្ទ ........ ១៧

**ផ្នែកទី២ កិច្ចស្រាវជ្រាវទៅលើអង្គហេតុដោយការស្នើសុំឱ្យបំពេញកិច្ច** ........ ១៨

**កថាខណ្ឌទី១ ការចូលរួមតាមរយៈសំណើរបំពេញកិច្ច** ........ ១៨

ក. ការស្នើរសុំបំពេញកិច្ចដោយព្រះរាជអាជ្ញា ........ ១៩

ខ. ការស្នើរសុំបំពេញកិច្ចដោយជនត្រូវចោទ ........ ១៩

គ. ការស្នើរសុំបំពេញកិច្ចដោយដើមបណ្តឹងរដ្ឋប្បវេណី ........ ១៩

**កថាខណ្ឌទី២ ការបំពេញកិច្ចស្រាវជ្រាវតាមរយៈដីការចាត់ឱ្យស៊ើបសួរជំនួស** ........ ២០

ក. មូលហេតុនៃការចាត់ឱ្យបំពេញកិច្ចស៊ើបសួរជំនួស ........ ២១

ខ. កិច្ចស៊ើបសួរជំនួសដែលបំពេញកិច្ចដោយចៅក្រមផ្សេង ........ ២១

គ. កិច្ចស៊ើបសួរជំនួសដោយបំពេញកិច្ចដោយមន្ត្រីនគរបាលយុត្តិធម៌ ........ ២២

# ជំពូកទី២
# វិធានការនិរន្តរាយ

**ផ្នែកទី១ ដីកា** ........................................................ ២៤

**កថាខណ្ឌទី១ ដីកាបង្គាប់ឲ្យចូលខ្លួន** ........................................ ២៤

ក. អត្ថន័យនៃដីកាបង្គាប់ឲ្យចូលខ្លួន ........................................ ២៤

ខ. លក្ខខណ្ឌនៃការចេញដីកាបង្គាប់ឲ្យចូលខ្លួន ........................................ ២៥

គ. ការអនុវត្តដីកាបង្គាប់ឲ្យចូលខ្លួន ........................................ ២៦

**កថាខណ្ឌទី២ ដីកាបង្គាប់ឲ្យនាំខ្លួន** ........................................ ២៦

ក. អត្ថន័យនៃដីកាបង្គាប់ឲ្យនាំខ្លួន ........................................ ២៦

ខ. លក្ខខណ្ឌនៃការចេញដីកាបង្គាប់ឲ្យនាំខ្លួន ........................................ ២៦

គ. ការអនុវត្តដីកាបង្គាប់ឲ្យនាំខ្លួន ........................................ ២៧

**កថាខណ្ឌទី៣ ដីកាបង្គាប់ឲ្យចាប់ខ្លួន** ........................................ ២៨

ក. អត្ថន័យនៃដីកាបង្គាប់ឲ្យចាប់ខ្លួន ........................................ ២៨

ខ. លក្ខខណ្ឌនៃការចេញដីកាបង្គាប់ឲ្យចាប់ខ្លួន ........................................ ២៩

គ. ការអនុវត្តដីកាបង្គាប់ឲ្យចាប់ខ្លួន ........................................ ៣០

**កថាខណ្ឌទី៤ ដីកាបង្គាប់ឲ្យឃុំខ្លួន** ........................................ ៣១

ក. អត្ថន័យនៃដីកាបង្គាប់ឲ្យឃុំខ្លួន ........................................ ៣១

ខ. លក្ខខណ្ឌនៃការចេញដីកាបង្គាប់ឲ្យឃុំខ្លួន ........................................ ៣២

គ. ការអនុវត្តដីកាបង្គាប់ឲ្យឃុំខ្លួន ........................................ ៣២

**ផ្នែកទី២ ការកំណត់សិទ្ធិទៅកាន់ជនត្រូវចោទ** ........................................ ៣៣

**កថាខណ្ឌទី១ ការឃុំខ្លួនបណ្ដោះអាសន្ន** ........................................ ៣៣

ក. លក្ខខណ្ឌនៃការឃុំខ្លួនបណ្ដោះអាសន្ន ........................................ ៣៣

ខ. នីតិវិធីនៃការឃុំខ្លួនបណ្ដោះអាសន្ន ........................................ ៣៥

គ. ថិរវេលានៃការឃុំខ្លួនបណ្ដោះអាសន្ន ........................................ ៣៦

ឃ. ការធានាជនត្រូវចោទឲ្យនៅក្រៅឃុំ ........................................ ៣៨

**កថាខណ្ឌទី២ ការត្រួតពិនិត្យតាមផ្លូវតុលាការ** ........................................ ៤០

ក. លក្ខខណ្ឌសម្រេចដាក់ឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ..... ៤០

ខ. នីតិវិធីនៃការដាក់ឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ............ ៤២

គ. ការអនុវត្តនីតិវិធីដាក់ឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ ...... ៤៣

ឃ. តួនាទីចៅក្រមស៊ើបសួរក្នុងដំណាក់កាលត្រួតពិនិត្យតាមផ្លូវតុលាការ ......៤៣

## ជំពូកទី៣

## ការបិទការស៊ើបសួរ

**ផ្នែកទី១ នីតិវិធីនៃការបិទការស៊ើបសួរ** ........................................ ៤៦

**កថាខណ្ឌទី១ ការជូនពត៌មានដោយចៅក្រមស៊ើបសួរ** ........................................ ៤៦

**កថាខណ្ឌទី២ ការបញ្ជូនសំណុំរឿងដោយព្រះរាជអាជ្ញា** ........................................ ៤៦

**ផ្នែកទី២ ដីកាដោះស្រាយ** ........................................ ៤៧

**កថាខណ្ឌទី១ ដីកាបញ្ជូនទៅពិនិត្យរឿងមូល** ........................................ ៤៨

**កថាខណ្ឌទី២ ដីកាលើកលែងការចោទប្រកាន់** ........................................ ៤៨

**សេចក្តីសន្និដ្ឋាន** ........................................ ៥០

**អនុសាសន៍** ........................................ ៥២

**ឯកសារយោង**

**ឧបសម្ព័ន្ធ**

# សេចក្តីផ្តើម

# សេចក្តីផ្តើម

## ១. លំនាំបណ្តានៃការស្រាវជ្រាវ

រឿងក្តីព្រហ្មទណ្ឌ គឺជាប្រតិកម្មតាមផ្លូវតុលាការរបស់សង្គម បានន័យថាចាប់ពីពេលដែលបទល្មើសមួយត្រូវបានប្រព្រឹត្តរហូតទៅដល់ការដាក់ទណ្ឌកម្ម នឹងមាននីតិវិធីមួយត្រូវបានដំណើរការ ហៅថារឿងក្តីព្រហ្មទណ្ឌ បានន័យថាវាកើតឡើងនៅពេលដែលបទល្មើសមួយត្រូវបានប្រព្រឹត្តរហូតដល់មានការប្រកាសទណ្ឌកម្ម និងអនុវត្តទណ្ឌកម្មឬទោស។ ចំពោះវិធានដែលទាក់ទងនឹងការរៀបចំ ការប្រព្រឹត្តទៅ និងការវិនិច្ឆ័យនៃរឿងក្តីព្រហ្មទណ្ឌនេះគឺបង្កើតបានជាសំណុំវិធានមួយហៅថានីតិវិធីព្រហ្មទណ្ឌនេះឯង។ ដូចច្នេះនីតិវិធីព្រហ្មទណ្ឌ គឺជាសំណុំវិធានដែលគ្រប់គ្រងទៅលើការរៀបចំ ការប្រព្រឹត្តទៅ និងការវិនិច្ឆ័យនៃរឿងព្រហ្មទណ្ឌ ដើម្បីធានានូវប្រសិទ្ធិភាពនៃដំណើរការរបស់តុលាការក៏ដូចជាស្វែងរកយុត្តិធម៌ជូនប្រជាពលរដ្ឋ។ម្យ៉ាងទៀតនីតិវិធីព្រហ្មទណ្ឌនេះត្រូវបានរៀបចំឡើងក្នុងគោលដៅសំខាន់ៗជាអាទិ៍ដូចជា ទាក់ទងទៅដល់ការកំណត់សមត្ថកិច្ច និងការប្រព្រឹត្តទៅរបស់យុត្តាធិកាព្រហ្មទណ្ឌ ដែលយើងហៅថាតុលាការព្រហ្មទណ្ឌ។ ហើយទាក់ទងទៅដល់បែបបទនីតិវិធីនៃការពិនិត្យ ការចោទប្រកាន់បទល្មើស ការស្រាវជ្រាវរកជនល្មើស ការស្វែងរកភស្តុតាង ព្រមទាំងនីតិវិធីនៃការជំនុំជម្រះជនល្មើសផងដែរ។ ដូចច្នេះនិយាយដោយសង្ខេប គោលបំណងធំបំផុតរបស់នីតិវិធីព្រហ្មទណ្ឌ គឺធានានូវប្រសិទ្ធិភាពនៃការបង្ក្រាបផង ហើយក៏ធានានូវសិទ្ធិនិងសេរីភាពរបស់បុគ្គលដែលពាក់ព័ន្ធផងដែរ។ ចំណុចមួយទៀត បើសិនយើងពិនិត្យមើលទៅលើដំណើរការនៃរឿងក្តីព្រហ្មទណ្ឌ យើងអាចចែកចេញជា ៤ (បួន) ដំណាក់កាលទៅតាមលំដាប់លំដោយដូចតទៅ :

*ទីមួយ : ការស៊ើបអង្កេត ដែលធ្វើឡើងដោយនគរបាលយុត្តិធម៌។*

*ទីពីរ : ការចោទប្រកាន់ ដែលធ្វើឡើងដោយព្រះរាជអាជ្ញា។*

*ទីបី : ការស៊ើបសួរ ដែលធ្វើឡើងដោយចៅក្រមស៊ើបសួរ។*

*ទីបួន : ការជំនុំជម្រះ ដែលធ្វើឡើងដោយចៅក្រមជំនុំជម្រះ។*

បើតាមការរៀបរាប់ខាងលើឃើញថា រឿងក្តីព្រហ្មទណ្ឌ គឺពាក់ព័ន្ធដល់ស្ថាប័នជាច្រើនដែលក្នុងនោះរួមមាន: ស្ថាប័ននគរបាលយុត្តិធម៌ ស្ថាប័នអយ្យការ ស្ថាប័នស៊ើបសួរ និងស្ថាប័នជំនុំជម្រះ។ ដែលការបែងចែកនូវតួនាទីរបស់មន្ត្រីទាំងអស់នេះ គឺក្នុងគោលបំណងធានាឲ្យការស៊ើបអង្កេតប្រកបដោយប្រសិទ្ធិភាព មានន័យថា អាចកំណត់ពី បទល្មើស និងបុគ្គលដែលបានប្រព្រឹត្តបទល្មើសបានច្បាស់ជៀសវាងការភាន់ច្រឡំ។ តាមរយៈនៃការស៊ើបអង្កេតនេះ ក្រៅពីមន្ត្រីនគរបាលយុត្តិធម៌

គេឃើញថាចៅក្រមស៊ើបសួរក៏មាន តួនាទីយ៉ាងចម្បងក្នុងការស៊ើបសួរស្វែងរកការពិតផងទាំងភស្តុតាងដាក់បន្ទុក និងភស្តុតាងដោះបន្ទុក។

អាស្រ័យហេតុនេះ ចៅក្រមស៊ើបសួរពិតជាមានតួនាទីយ៉ាងសំខាន់ណាស់ក្នុងដំណាក់កាលនីតិវិធីព្រហ្មទណ្ឌ តាមរយៈតួនាទីស៊ើបសួររបស់គាត់ ពីព្រោះថាដំណាក់កាលនេះ គឺជាដំណាក់កាលមួយដែលបញ្ជាក់បានថាជនរូបណាបានប្រព្រឹត្តបទល្មើស ឬ មិនប្រព្រឹត្តបទល្មើស។

## ២. ចំណោទនៃការស្រាវជ្រាវ

រយៈពេលកន្លងមកនេះ យើងសង្កេតឃើញថាមានមន្ត្រីមួយចំនួនតូច ព្រមទាំងសិស្សានុសិស្សផ្នែកច្បាប់ពុំទាន់ជ្រាបច្បាស់អំពីប្រធានបទនេះនៅឡើយទេ ដែលជាហេតុនាំឲ្យការអនុវត្តច្បាប់នៅក្នុងដែនដីព្រះរាជាណាចក្រកម្ពុជាសព្វថ្ងៃ ទទួលរងនូវផលប៉ះពាល់ដល់សិទ្ធិសេរីភាពរបស់បុគ្គល។ ដើម្បីស្រាយចម្ងល់ខាងលើឱ្យកាន់តែស៊ីជម្រៅ និងមានអត្ថន័យកាន់តែច្បាស់ យើងបានលើកយកសំណួរមួយចំនួនមកចោទសួរដូចជា តើតួនាទីរបស់ចៅក្រមស៊ើបសួរមានអ្វីខ្លះ? តើដំណាក់កាលស៊ើបសួររបស់ចៅក្រមស៊ើបសួរប្រព្រឹត្តទៅយ៉ាងដូចម្តេចខ្លះ? តើច្បាប់បានកំណត់សិទ្ធិ និងអំណាចអ្វីខ្លះដល់ចៅក្រមស៊ើបសួរនៅក្នុងដំណាក់កាលស៊ើបអង្កេត?

## ៣. គោលបំណងនៃការស្រាវជ្រាវ

ចំពោះហេតុផលក្នុងការតាក់តែងអត្ថបទមួយនេះឡើង គឺក្នុងគោលបំណងបង្កើនចំណេះដឹងជាមួយនឹង បទពិសោធខ្លះៗដើម្បីចងក្រងជាឯកសារសម្រាប់ជំនួយស្មារតីដល់អ្នកសិក្សាស្រាវជ្រាវស្វែងយល់ឱ្យកាន់តែច្បាស់អំពីនីតិវិធី និងតួនាទីនៃការស៊ើបសួរដែលត្រូវបានធ្វើឡើងដោយចៅក្រមស៊ើបសួរដូចដែលក្រមនីតិវិធីព្រហ្មទណ្ឌបានបញ្ញត្តិយ៉ាងច្បាស់លាស់។

## ៤. ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ

ប្រធានបទស្រាវជ្រាវនេះ គឺមានវិសាលភាពគ្របដណ្តប់ទៅលើទ្រឹស្តីនិងទិដ្ឋភាពជាក់ស្តែងនៃតួនាទី ភារកិច្ច និងអំណាចរបស់ចៅក្រមស៊ើបសួរនៅក្នុងដំណាក់កាលស៊ើបសួរដែលបានបញ្ញត្តិនៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៩។

## ៥. សារៈសំខាន់នៃការស្រាវជ្រាវ

ក្នុងការស្រាវជ្រាវអត្ថបទ ស្តីអំពី "**តួនាទីរបស់ចៅក្រមស៊ើបសួរ**" ពិតជាបានផ្តល់នូវអត្ថប្រយោជន៍ជាច្រើនរួមមានដូចតទៅ ៖

- បង្កើនចំណេះដឹងផ្នែកច្បាប់ឲ្យកាន់តែល្អប្រសើរ
- ស្វែងយល់កាន់តែច្បាស់អំពីដែនកំណត់ និងវិសាលភាពនៃកាតួកិច្ចរបស់ចៅក្រមស៊ើបសួរ
- បង្កើនភាពជិតស្និតជាមួយសាស្ត្រាចារ្យណែនាំ

- ព្រមទាំងមានឱ្យកាសបញ្ចេញគំនិតដើម្បីកំណែទម្រង់ក្នុងន័យស្ថាបនា។

## ៦. រចនាសម្ព័ន្ធ នៃការស្រាវជ្រាវ

ដើម្បីយល់ឲ្យបានច្បាស់ ខ្ញុំសូមធ្វើការតាក់តែងសារណានេះដោយយោងតាមរចនាសម្ព័ន្ធ អារម្មណ៍កថា សេចក្តីថ្លែងអំណរគុណ សេចក្តីផ្តើម និងខ្លឹមសារដែលបែងចែកជាបីជំពូកដូចខាងក្រោម:

I. ជំពូកទី១ ការស្រាវជ្រាវរបស់ចៅក្រមស៊ើបសួរ

II. ជំពូកទី២ វិធានការនិរន្តរាយ

III. ការបិទការស៊ើបសួរ

ផ្នែកបញ្ចប់នៃសារណានេះ យើងបានរៀបចំឱ្យមានសេចក្តីសន្និដ្ឋាន និងអនុស្សាន៍ដែលជាគំនិតរួមចំណែកក្នុងកំណែទម្រង់។

# ជំពូកទី១
# ការស្រាវជ្រាវរបស់ចៅក្រមស៊ើបសួរ

# ជំពូកទី១
# ការស្រាវជ្រាវរបស់ចៅក្រមស៊ើបសួរ

ការស៊ើបសួរ គឺជាសិទ្ធិក្នុងការបំពេញកិច្ចរបស់ចៅក្រមស៊ើបសួរដើម្បីការស្រាវជ្រាវចំពោះអង្គហេតុនៃបទល្មើសព្រហ្មទណ្ឌ ក្រោយពីទទួលបានដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួររបស់ព្រះរាជអាជ្ញាដោយអនុលោមតាមមាត្រា ៤៤ (ការបើកការស៊ើបសួរ) នៃក្រមនីតិវិធីព្រហ្មទណ្ឌ។ ចំពោះកិច្ចស៊ើបសួរទាំងអស់នេះ ត្រូវបានអនុវត្ត និង ដឹកនាំផ្ទាល់ដោយចៅក្រមស៊ើបសួរដើម្បីប្រមូលភស្តុតាងទាំងអស់ដែលពាក់ព័ន្ធ ដែលបញ្ជាក់ពីការពិតនៃអង្គហេតុព្រហ្មទណ្ឌចាប់តាំងពីការចាប់ផ្តើមស្រាវជ្រាវរហូតដល់បញ្ចប់ការស៊ើបសួរ។ ការស៊ើបសួរត្រូវធ្វើដោយខានមិនបានចំពោះបទឧក្រិដ្ឋ។ រីឯចំពោះបទមជ្ឈិម ការស៊ើបសួរអាចធ្វើក៏បាន ឬ មិនធ្វើក៏បាន[1]។

រាល់ការចូលរួមស្រាវជ្រាវរឿងក្តីព្រហ្មទណ្ឌរបស់ចៅក្រមស៊ើបសួរ ក្នុងដំណាក់កាលស៊ើបសួរ ត្រូវតែរក្សាការសម្ងាត់[2]។ ជាគោលការណ៍ការដំណាក់កាលស៊ើបសួរ ចៅក្រមស៊ើបសួរត្រូវតែស្វែងរកភស្តុតាង ទាំងភស្តុតាងដាក់បន្ទុក និងភស្តុតាងដោះបន្ទុកដើម្បីផ្តល់ភាពយុត្តិធម៌ជូនជនល្មើស និង ជនរងគ្រោះ។ ចំពោះកិច្ចស្រាវជ្រាវនេះមានដូចជា កិច្ចស្រាវជ្រាវចំពោះអង្គហេតុ ដែលជាការស្រាវជ្រាវដើម្បីបញ្ជាក់ឲ្យឃើញថាមានអង្គហេតុដែលបង្កជាបទល្មើស ឬគ្មានបទល្មើសដូចដែលមានកំណត់ក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួររបស់ព្រះរាជអាជ្ញា និងម្យ៉ាងទៀត គឺជាកិច្ចស្រាវជ្រាវដែលទាក់ទងទៅនឹងបុគ្គលិកលក្ខណៈរបស់ជនត្រូវចោទ ថាតើជនត្រូវចោទមានសមត្ថភាពទទួលខុសត្រូវព្រហ្មទណ្ឌដែរ ឬ យ៉ាងណា?

## ផ្នែកទី១ កិច្ចស្រាវជ្រាវទៅលើអង្គហេតុដោយចៅក្រមស៊ើបសួរ

ដំណាក់កាលស្រាវជ្រាវទៅលើអង្គហេតុ គឺជាដំណាក់កាលមួយដែលសំខាន់បំផុតរបស់ចៅក្រមស៊ើបសួរសម្រាប់ធ្វើឡើងដើម្បីស្រាវជ្រាវរកភស្តុតាង ថាតើជនសង្ស័យពិតជាបានប្រព្រឹត្តបទល្មើសមែន ឬ ក៏មិនមែន? តើអង្គហេតុដែលបង្កឡើងនោះ ជាបទល្មើស ឬ មិនមែនជាបទល្មើស?

ចំពោះកិច្ចស្រាវជ្រាវទៅលើអង្គហេតុនេះ ត្រូវបានចៅក្រមស៊ើបសួរអនុវត្ត និងបំពេញតួនាទីរបស់ខ្លួនយ៉ាងយកចិត្តទុកដាក់បំផុត ធ្វើយ៉ាងណាត្រូវរកភស្តុតាងទៅតាមសមត្ថភាព ឬ វិធីសាស្ត្ររបស់ខ្លួនដើម្បីស្វែងរកការពិតឲ្យបានឆាប់រហ័សបំផុតទៅតាមអ្វីដែលអាចធ្វើទៅបាន។ យ៉ាងណាមិញកាតព្វកិច្ចដែលចៅក្រមស៊ើបសួរ ត្រូវតែបំពេញដោយខានពុំបាននោះគឺ ត្រូវស៊ើបសួរទៅលើបុគ្គលិកលក្ខណៈរបស់ជនត្រូវចោទ បានន័យថាត្រូវធ្វើការស្រាវជ្រាវឲ្យឃើញថា តើសកម្មភាពរបស់ជនត្រូវ

[1] មាត្រា ១២២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ
[2] មាត្រា ១២១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

ចោទនាពេលដែលបានប្រព្រឹត្តបទល្មើសនោះ ស្ថិតក្នុងស្ថានភាពបែបណា? តើស្ថិតក្នុងស្ថានភាពសតិវិបល្លាស ឬ ជាករណីការការពារខ្លួនស្របច្បាប់ ឬ ដោយមានការគិតទុកជាមុន។ ត្រង់ចំណុចនេះ ទាមទារឲ្យចៅក្រមស៊ើបសួរ ត្រូវតែស្វែងរកការពិតឲ្យបានឆាប់រហ័សបំផុត ពីព្រោះដើម្បីកុំឲ្យប៉ះពាល់ដល់សិទ្ធិសេរីភាពរបស់ជនត្រូវចោទដែលកំពុងជាប់ឃុំខ្លួនបណ្ដោះអាសន្ន ឬ ស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ។ ចំណុចនេះ គឺទាមទារឲ្យមានការវិភាគលើសកម្មភាព និងសមត្ថភាពរបស់ជនត្រូវចោទនាពេលប្រព្រឹត្តបទល្មើសមានលក្ខណៈយ៉ាងណា ដើម្បីជាភស្តុតាងសម្រាប់កំណត់ជនសង្ស័យក្នុងគោលបំណងបញ្ជូនទៅកាន់តុលាការធ្វើការជំនុំជម្រះ ឬ ត្រូវសម្រេចដោះលែងឲ្យមានសេរីភាពវិញ។

**កថាខណ្ឌទី១ គោលការណ៍នៃការបើកការស៊ើបសួរ**

ការបើកការស៊ើបសួរ ក្នុងករណីបទឧក្រិដ្ឋ ព្រះរាជអាជ្ញាត្រូវតែបើកការស៊ើបអង្កេតដោយបញ្ជូនដីការឿងឱ្យស៊ើបសួរ ដែលត្រូវប្ដឹងទៅកាន់ចៅក្រមស៊ើបសួរ។ ការស៊ើបសួរអាចបើកការប្រឆាំងលើបុគ្គលម្នាក់ ឬ ច្រើននាក់ ដោយមានចង្អុលប្រាប់ឈ្មោះ ឬ ប្រឆាំងទៅលើអញ្ញាតជន[3]។ ក្រោយពីទទួលដីកាឱ្យស៊ើបសួរ ចៅក្រមស៊ើបសួរនឹងបើកការស៊ើបសួរដោយរក្សាការសម្ងាត់។

ការបើកការស៊ើបសួរត្រូវតែធ្វើដោយខានមិនបានចំពោះបទឧក្រិដ្ឋ។ ចំពោះបទមជ្ឈិម ការស៊ើបសួរអាចធ្វើក៏បាន ឬ មិនធ្វើក៏បាន។ ឧទាហរណ៍ អំពើលួចជាប្រភេទបទល្មើសមជ្ឈិមដែលត្រូវបើកការស៊ើបសួរ រីឯចំពោះបទល្មើសមជ្ឈិមជាក់ស្ដែងដូចជាករណីឆក់ទូរសព្ទចៅក្រមស៊ើបសួរមិនធ្វើការស៊ើបសួរក៏បាន។ ការបើកការស៊ើបសួរ ចៅក្រមស៊ើបសួរមិនអាចបំពេញកិច្ចស៊ើបសួរណាមួយបានទេ ប្រសិនបើគ្មានដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួររបស់ព្រះរាជអាជ្ញា។ ប្រសិនបើកាលណាចៅក្រមស៊ើបសួរបានទទួលពាក្យបណ្ដឹង ដោយមានការតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី ចៅក្រមស៊ើបសួរត្រូវតែធ្វើការកត់សំគាល់នូវការដាក់ពាក្យប្ដឹង ដោយមានការតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីតាមដីកា។ បន្ទាប់ចៅក្រមស៊ើបសួរបញ្ជូនបណ្ដឹងនេះទៅព្រះរាជអាជ្ញាជាដំបូងសិន។

ក្រោយពីបានឃើញពាក្យប្ដឹងដោយមានការតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី ព្រះរាជអាជ្ញាត្រូវប្ដឹងទៅចៅក្រមស៊ើបសួរ តាមដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ។

ក្នុងករណីដែលចៅក្រមស៊ើបសួរសម្រេចមិនស៊ើបសួរ ចៅក្រមរូបនេះត្រូវចេញដីកាសម្រេចដោយមានសំអាងហេតុ ដែលត្រូវជូនដំណឹងជាបន្ទាន់ដល់ដើមបណ្ដឹងរដ្ឋប្បវេណី។

ប៉ុន្តែប្រសិនបើ ក្នុងករណីដែលចៅក្រមស៊ើបសួរនៅតែសម្រេចស៊ើបសួរ ចៅក្រមរូបនេះត្រូវចេញដីកាសម្រេចដោយមានសំអាងហេតុ ហើយត្រូវជូនដំណឹងជាបន្ទាន់ដល់ព្រះរាជអាជ្ញា។

[3] មាត្រា ៥៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

**ក. គោលបំណងនៃការបើកការស៊ើបសួរ**

គោលបំណងសំខាន់នៃការបើកការស៊ើបសួរ គឺដើម្បីស្រាវជ្រាវរកភស្តុតាងឲ្យបានគ្រប់គ្រាន់តាមរយៈការស៊ើបសួរ។ ជាធម្មតានៅក្នុងរឿងក្តីព្រហ្មទណ្ឌ ការស៊ើបអង្កេតរបស់មន្ត្រីនគរបាលយុត្តិធម៌ និងការសាកសួរនៅក្នុងដំណាក់កាលអយ្យការពុំទាន់អាចប្រមូលបានអង្គហេតុ និងភស្តុតាងគ្រប់ជ្រុងជ្រោយដែលអាចបញ្ជូនជនសង្ស័យនោះទៅជំនុំជម្រះបានឡើយ ពីព្រោះគេចាត់ទុកថាដំណាក់កាលចោទនេះជាដំណាក់កាលបឋម។ ហេតុដូចនេះ ទើបនីតិវិធីច្បាប់តម្រូវឲ្យមានការបើកការស៊ើបសួរនៅចំពោះមុខចៅក្រមស៊ើបសួរ ដើម្បីធ្វើយ៉ាងណាស្វែងរកការពិតចាំបាច់សម្រាប់ធានាដល់ការចោទប្រកាន់ និងធានានូវនិរន្តរភាពសម្រាប់ដំណើរការកាត់សេចក្តី។

ជាទូទៅសំនួរជាច្រើនបានលេចឡើងនៅក្នុងដំណាក់កាលមួយនេះ ហើយក៏ត្រូវបានយកមកស៊ើបសួរជនត្រូវចោទ និងជនដែលមានការជាប់ពាក់ព័ន្ធដោយការចោទសួរនោះគឺដើម្បីចង់ដឹងថា តើជនសង្ស័យពិតជាបានប្រព្រឹត្តបទល្មើសមែន ឬ មិនមែន។

**ខ. ការស្រាវជ្រាវចំពោះបុគ្គលិកលក្ខណៈរបស់ជនត្រូវចោទ**

ក្នុងកិច្ចស្រាវជ្រាវរបស់ចៅក្រមស៊ើបសួរ គឺ មិនត្រឹមតែស៊ើបសួរឲ្យជាក់ច្បាស់នូវអង្គហេតុ ក៏ដូចជាការប្រមូលភស្តុតាងតែប៉ុណ្ណោះទេ គឺចៅក្រមស៊ើបសួរ ក៏អាចស្រាវជ្រាវអំពីបុគ្គលិកលក្ខណៈរបស់ជនត្រូវចោទ។ ការស្រាវជ្រាវនេះ គឺមានសារៈប្រយោជន៍ដើម្បីបង្ហាញឲ្យឃើញការពិតនៃសកម្មភាពប្រព្រឹត្ត និងចារិតរបស់ជនត្រូវចោទ សមត្ថភាពទទួលខុសត្រូវព្រហ្មទណ្ឌ ក៏ដូចជាសតិអារម្មណ៍របស់ជនត្រូវចោទពេលប្រព្រឹត្តបទល្មើស។ ឧទាហរណ៍៖ ជនត្រូវចោទប្រព្រឹត្តបទល្មើសក្នុងពេលប្រើប្រាស់ជាតិស្រវឹង បានប្រើប្រាស់គ្រឿងញៀន ពេលមានសតិវិប្លាសស្មារតី ឬស្ថានភាពផ្សេងៗ។ ការស្រាវជ្រាវនេះ គឺបង្ហាញពីភាពចេតនា ឬ អចេតនានៃការប្រព្រឹត្តបទល្មើសដោយជនត្រូវចោទ។

លើសពីនេះទៅទៀតការស្រាវជ្រាវ អំពីបុគ្គលិកលក្ខណៈរបស់ជនត្រូវចោទ គឺដើម្បីទទួលបាននូវពត៌មានផ្សេងៗ ដែលទាក់ទងទៅនឹងអត្តចារិតរបស់ជនត្រូវចោទ ក៏ដូចជាឲ្យបានដឹងនូវរាល់សកម្មភាពរស់នៅប្រចាំថ្ងៃរបស់ជនត្រូវចោទដើម្បីរកមូលហេតុផ្សេងៗ ដែលបណ្តាលឲ្យមានការប្រព្រឹត្តបទល្មើស។ ម្យ៉ាងវិញទៀត ការស្រាវជ្រាវនេះក៏អាចបញ្ជាក់បានផងដែរអំពីភាពសុចរិតរបស់ជនត្រូវចោទពីព្រោះថាការចោទប្រកាន់មួយចំនួនអាចមានការភណ្ឌច្រឡំទៅលើបុគ្គលណាមួយ ឬ ដោយមានការទម្លាក់កំហុស។

**គ. សមត្ថកិច្ចដែនដីរបស់ចៅក្រមស៊ើបសួរ**

ក្នុងនីតិវិធីនៃការស៊ើបសួរ ចៅក្រមស៊ើបសួរដែលមានសមត្ថកិច្ចដែនដីដើម្បីបំពេញតួនាទីរបស់

ខ្លួន ជាទូទៅគេកំណត់តាមវិធីដូចខាងក្រោម ៖

- សមត្ថកិច្ចរបស់ចៅក្រមស៊ើបសួរនា ទីកន្លែងប្រព្រឹត្តបទល្មើស
- សមត្ថកិច្ចរបស់ចៅក្រមស៊ើបសួរនា ទីលំនៅឋាន ឬ ទីសំណាក់របស់បុគ្គលដែលសង្ស័យថា បានប្រព្រឹត្តបទល្មើស
- ចៅក្រមស៊ើបសួរនា ទីកន្លែងចាប់ខ្លួនបុគ្គលដែលសង្ស័យថា បានប្រព្រឹត្តបទល្មើស។

ក្នុងករណីដែលមានទំនាស់រវាងចៅក្រមស៊ើបសួរច្រើនរូប នៅសាលាដំបូងខុសៗគ្នា ហើយទទួលបានបណ្ដឹងទាំងអស់គ្នា អំពីរឿងក្ដីព្រហ្មទណ្ឌតែមួយដូចគ្នា ទំនាស់នេះត្រូវបានបញ្ជូនទៅប្រធានសភាស៊ើបសួរដើម្បីសម្រេច។

វិវាទសមត្ថកិច្ចដែនដី រវាងសភាស៊ើបសួរច្រើន ត្រូវសម្រេចដោយប្រធានតុលាការកំពូល ដោយការសម្រេចនេះបិទផ្លូវតវ៉ា[4]។

**កថាខណ្ឌទី២ វិធីសាស្ត្រស្រាវជ្រាវរបស់ចៅក្រមស៊ើបសួរ**

វិធីសាស្ត្រស្រាវជ្រាវសំខាន់ៗរបស់ចៅក្រមស៊ើបសួរ ដើម្បីស្វែងរកការពិតឲ្យបានច្បាស់ក្នុងនោះរួមមានដូចជា ការជូនដំណឹងអំពីការដាក់ឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យ ការសួរចម្លើយជនត្រូវចោទ ការស្ដាប់ចម្លើយដើមបណ្ដឹងរដ្ឋប្បវេណី ការស្ដាប់ចម្លើយសាក្សី ការឆែកឆេរ និងការចាប់យកវត្ថុតាង ការធ្វើកុសលវិច័យ ការស្ដាប់ទូរស័ព្ទ។ ការស្រាវជ្រាវនេះត្រូវតែធានានូវការគោរពអំពីគោលការណ៍សេរីភាពរបស់បុគ្គល[5]។

**ក. ការជូនដំណឹងអំពីការដាក់ឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យ**

ដីកាសម្រេចដាក់ជនត្រូវចោទឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ គឺជាវិធានការនៃសេចក្ដីសម្រេចរបស់ចៅក្រមស៊ើបសួរជំនួសឱ្យការឃុំខ្លួនបណ្ដោះអាសន្ន ក្នុងកម្មវត្ថុរឹតបន្តឹងនូវសេរីភាពទៅលើជនត្រូវចោទដែលត្រូវបានចោទប្រកាន់អំពីបទល្មើស ដែលត្រូវផ្ដន្ទាទោសដាក់ពន្ធនាគារ។

ចៅក្រមស៊ើបសួរ គឺពិតជាអាចសម្រេចដាក់ជនត្រូវចោទឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការតាមគំនិតផ្ដើមផ្ទាល់របស់ខ្លួន ឬតាមសេចក្ដីសន្និដ្ឋានរបស់ព្រះរាជអាជ្ញា (ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ)។ នៅក្នុងដីកាសម្រេចរបស់ខ្លួន ចៅក្រមស៊ើបសួរត្រូវបញ្ជាក់អំពីកាតព្វកិច្ចដែលតម្រូវទៅលើជនត្រូវចោទ[6]។

[4] មាត្រា ១២៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

[5] មាត្រា ២០៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

[6] មាត្រា ២២៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

ជាធម្មតាចៅក្រមស៊ើបសួរ មានសិទ្ធិចេញដីកាសម្រេចដាក់ជនត្រូវចោទ និងបុគ្គលដែលស្ថិតក្នុងឋានៈជាចារី ជាអ្នកផ្តើមគំនិត ឬជាអ្នកសមគំនិតឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ ត្រូវជូនដំណឹងក្នុងរយៈពេលយ៉ាងខ្លីបំផុតដល់ព្រះរាជអាជ្ញា និងជនត្រូវចោទ។ ផ្ទុយទៅវិញ ប្រសិនបើចៅក្រមស៊ើបសួរ បានទទួលបណ្តឹងសេចក្តីសន្និដ្ឋានរបស់ព្រះរាជអាជ្ញា សុំឱ្យដាក់ជនត្រូវចោទឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ តែខ្លួនបដិសេធមិនព្រមសម្រេចតាមការសុំទេ គាត់ត្រូវចេញដីកាបដិសេធការសុំនេះក្នុងរយៈពេល ៥ (ប្រាំ) ថ្ងៃ។ ដីកាសម្រេចនេះ ត្រូវជូនដំណឹងក្នុងរយៈពេលយ៉ាងខ្លីបំផុតដល់ព្រះរាជអាជ្ញា។ ប្រសិនបើចៅក្រមស៊ើបសួរមិនបានចេញសេចក្តីសម្រេចក្នុងរយៈពេល ៥ (ប្រាំ) ថ្ងៃទេ ព្រះរាជអាជ្ញាអាចធ្វើពាក្យប្តឹងទៅសភាស៊ើបសួរដែលជាអ្នកសម្រេចជំនួស។

នៅពេលចេញដីកានេះ ចៅក្រមស៊ើបសួរអាចបង្គាប់ឱ្យជនត្រូវចោទដាក់ប្រាក់ធានា ហើយត្រូវបង្គាប់ឱ្យជនត្រូវចោទដាក់តម្កល់នូវសំណុំឯកសារមួយចំនួន (អត្តសញ្ញាណប័ណ្ណ សៀវភៅគ្រួសារ កាតបម្រើការងារ...) ដែលបញ្ជាក់អំពីអត្តសញ្ញាណរបស់ជនត្រូវចោទ ព្រមទាំងត្រូវដកហូតរក្សាទុកនូវសម្ភារៈផ្សេងៗមួយចំនួនផងដែរ (អាវុធ)[7]។

នៅពេលដែលជនត្រូវចោទចូលបង្ហាញខ្លួនលើកដំបូង ចៅក្រមស៊ើបសួរត្រូវតែពិនិត្យមើលអត្តសញ្ញាណជនត្រូវចោទ ហើយប្រាប់ជនរូបនេះឲ្យបានដឹងនូវរឿងរ៉ាវដែលចោទប្រកាន់ និងប្រាប់អំពីឈ្មោះបទល្មើសដែលកំណត់ដោយច្បាប់ ។ ចៅក្រមស៊ើបសួរប្រាប់ជនត្រូវចោទថា ខ្លួនអាចឆ្លើយ ឬមិនឆ្លើយបានដោយសេរី ។ និទ្ទេសស្តីពីការប្រាប់នេះត្រូវបានចុះនៅក្នុងកំណត់ហេតុនៅពេលចូលបង្ហាញខ្លួនលើកដំបូង ។

ប្រសិនបើជនត្រូវចោទឆ្លើយនោះ ចៅក្រមស៊ើបសួរត្រូវតែទទួលចម្លើយនោះភ្លាម មានន័យថាខណៈពេលជនត្រូវចោទ បានចូលបង្ហាញខ្លួនដំបូង ចៅក្រមស៊ើបសួរមានកិច្ចសំខាន់បីយ៉ាងគឺ ធ្វើកំណត់ហេតុស្តីពីការបង្ហាញខ្លួនលើកដំបូង កំណត់ហេតុសួរដេញដោលចំពោះមុខ និងកំណត់ហេតុសួរចម្លើយជនត្រូវចោទ។ ក្រោយមកទៀតចៅក្រមស៊ើបសួរប្រាប់ជនត្រូវចោទឲ្យបានដឹងអំពីសិទ្ធិរបស់ខ្លួនក្នុងការជ្រើសរើសមេធាវី ឬក្នុងការសុំឲ្យចាត់តាំងមេធាវីឲ្យខ្លួន ដោយអនុវត្តតាមច្បាប់ស្តីពីលក្ខន្តិកៈមេធាវី។ ចំពោះជនត្រូវចោទជាអនីតិជនត្រូវតែមានមេធាវីអមជានិច្ច បើគ្មានការជ្រើសរើសដោយជនត្រូវចោទទេ មេធាវីត្រូវបានចាត់តាំងនៅក្នុងលក្ខខណ្ឌដែលចែងដោយច្បាប់ស្តីពីលក្ខន្តិកៈមេធាវី។ ក្រោយពីការចូលបង្ហាញខ្លួនលើកទីមួយ ជនត្រូវចោទដែលនៅក្រៅឃុំ ត្រូវប្រកាសប្រាប់

[7] មាត្រា ២២៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

ដល់ចៅក្រមស៊ើបសួរអំពីអាស័យដ្ឋានរបស់ខ្លួន ។ ជនត្រូវចោទត្រូវបានដំណឹងថា ៖

- ខ្លួនត្រូវតែជូនពត៌មាន ដល់ចៅក្រមស៊ើបសួរ នៅពេលណាដែលខ្លួនប្តូរអាស័យដ្ឋាន[8]
- គ្រប់ការឲ្យដំណឹងដែលបានធ្វើឡើងតាមអាស័យដ្ឋានចុងក្រោយ ដែលប្រកាសឡើង ដោយជនត្រូវចោទនោះ ត្រូវបានចាត់ទុកថាបានធ្វើឡើងដល់សាមីខ្លួនផ្ទាល់ ។

### ខ. ការសួរចម្លើយជនត្រូវចោទ

នៅពេលចូលបង្ហាញខ្លួនលើកដំបូង ចៅក្រមស៊ើបសួរពិនិត្យអត្តសញ្ញាណរបស់ជនត្រូវចោទប្រាប់ជននេះឱ្យដឹងរឿងរ៉ាវដែលត្រូវបានចោទប្រកាន់ និងប្រាប់អំពីឈ្មោះបទល្មើស។ ហើយចៅក្រមស៊ើបសួរប្រាប់ជនត្រូវចោទថាខ្លួនអាចឆ្លើយឬមិនឆ្លើយដោយសេរី។ ប៉ុន្តែត្រូវតែនិទ្ទេសស្តីអំពីការប្រាប់នេះត្រូវចុះក្នុងកំណត់ហេតុនៅពេលចូលបង្ហាញខ្លួនដំបូង។ ការសួរចម្លើយជនត្រូវចោទគឺដើម្បីទទួលបានពតិមានពាក់ព័ន្ធនឹងបទល្មើស ហើយវាជាដំណាក់កាលមួយក្នុងការបំភ្លឺឲ្យឃើញកាន់តែច្បាស់នូវអង្គហេតុណាមួយ ឬបុគ្គលិកលក្ខណៈរបស់ជនត្រូវចោទផងដែរ។

ចំពោះការសួរចម្លើយនេះ កាលណាជនត្រូវចោទមានមេធាវីអម ចៅក្រមស៊ើបសួរ ត្រូវកោះហៅមេធាវីយ៉ាងតិចបំផុត ៥ (ប្រាំ) ថ្ងៃ មុនពេលសួរចម្លើយ។ ក្នុងចិរវេលានេះ មេធាវីអាចពិនិត្យមើលសំណុំរឿងនីតិវិធី ។ ជនត្រូវចោទអាចត្រូវសួរចម្លើយដោយចៅក្រមស៊ើបសួរបានតែនៅចំពោះមុខមេធាវីរបស់ខ្លួនតែប៉ុណ្ណោះ ។ ប៉ុន្តែប្រសិនជាមេធាវីត្រូវបានកោះហៅយ៉ាងត្រឹមត្រូវហើយ មិនចូលបង្ហាញខ្លួននៅថ្ងៃ និងម៉ោងកំណត់ទេ នោះចៅក្រមស៊ើបសួរអាចសួរចម្លើយជនត្រូវចោទ ដោយគ្មានវត្តមានមេធាវី ។ និទ្ទេសស្តីអំពីអវត្តមានមេធាវីនេះត្រូវបានចុះក្នុងកំណត់ហេតុសួរចម្លើយជនត្រូវចោទឲ្យបានត្រឹមត្រូវ ។

ក្នុងករណីពិសេស ចៅក្រមស៊ើបសួរ ក៏អាចសួរចម្លើយជនត្រូវចោទ ដោយមិនបាច់កោះហៅមេធាវីបាន ប្រសិនបើជនត្រូវចោទបោះបង់ចោលយ៉ាងជាក់លាក់នូវវត្តមានរបស់មេធាវីខ្លួន ។ ការបោះបង់ចោលនេះត្រូវបានចុះក្នុងកំណត់ហេតុផ្សេងពីកំណត់ហេតុសួរចម្លើយ និងត្រូវចុះហត្ថលេខាដោយជនត្រូវចោទផ្ទាល់។

ក្នុងករណីបន្ទាន់ ចៅក្រមស៊ើបសួរក៏អាចធ្វើការសួរចម្លើយដោយមិនបាច់កោះហៅមេធាវីបានដែរ ។ ភាពបន្ទាន់នេះត្រូវតែបណ្តាលមកពីគ្រោះថ្នាក់ដល់ស្លាប់ ឬបណ្តាលមកពីការភ័យខ្លាចពីការបាត់បង់តំរុយនៃភស្តុតាង។ ប្រភេទនៃភាពបន្ទាន់ត្រូវតែចុះនិទ្ទេសនៅក្នុងកំណត់ហេតុ[9]។ ចៅក្រមស៊ើបសួរ អាចហៅរកអ្នកបកប្រែដើម្បីធ្វើការការបកប្រែឲ្យជនត្រូវចោទបាន។

---

[8] មាត្រា ១៨៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

[9] មាត្រា ១៨៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

នៅពេលសួរចម្លើយជនត្រូវចោទ ព្រះរាជអាជ្ញា និងមេធាវីអាចលើកសំណួរផ្សេងៗដែលមានប្រយោជន៍ដល់បទល្មើសបានដែរ ដោយមានការអនុញ្ញាតពីចៅក្រមស៊ើបសួរ។ ក្នុងករណីមិនអនុញ្ញាត ករណីនេះត្រូវចុះនិទ្ទេសនៅក្នុងកំណត់ហេតុ[10]។

ប្រសិនបើកាលណាថិរវេលា ៤ (បួន) ខែ បានកន្លងផុតទៅ ចាប់ពីពេលសួរចម្លើយនៅពេលបង្ហាញខ្លួន លើកដំបូង ជនត្រូវចោទមិនត្រូវបានសួរចម្លើយ ឬសួរតទល់ទេ ចៅក្រមស៊ើបសួរត្រូវតែទទួល ចម្លើយ ប្រសិនបើជនត្រូវចោទបានស្នើសុំ ។ បើចៅក្រមស៊ើបសួរមិនព្រមកោះហៅជនត្រូវចោទក្នុងថិរវេលា ១ (មួយ) ខែ បន្ទាប់ពីការសុំទេ នោះជនត្រូវចោទអាចប្តឹងផ្ទាល់ទៅសភាស៊ើបសួរដែលទទួលចម្លើយនេះដោយខ្លួនឯង បន្ទាប់មកកំណត់ហេតុត្រូវបញ្ជូនទៅចៅក្រមស៊ើបសួរពីព្រោះការសួរចម្លើយជនត្រូវចោទ គឺជាកាតព្វកិច្ចរបស់ចៅក្រមស៊ើបសួរដែលត្រូវតែបំពេញដើម្បីទទួលយកពត៌មានផ្សេងៗពីជនត្រូវចោទ[11]។

ក្រៅពីនេះមេធាវីរបស់ជនត្រូវចោទដែលជាប់ឃុំ ក៏អាចប្រាស្រ័យទាក់ទងដោយសេរីជាមួយកូនក្តី របស់ខ្លួននៅក្នុងពន្ធនាគារ ឬនៅក្នុងមណ្ឌលឃុំខ្លួន ។ ការសន្ទនារបស់មេធាវី និងជនត្រូវចោទមិនអាចត្រូវគេស្តាប់ ឬថតបានទេ ។ មេធាវីអាចអានលិខិតនៃសំណុំរឿងឲ្យកូនក្តីស្តាប់ ។ ផ្ទុយទៅវិញមេធាវីមិនអាចឲ្យលិខិតថតចម្លងពីលិខិតសំណុំរឿង ដល់កូនក្តីរបស់ខ្លួនបានឡើយ[12]។

### គ. ការស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី

ដើមបណ្តឹងរដ្ឋប្បវេណី អាចជាជនរងគ្រោះ ឬអាចនិយាយបានថាជនទាំងឡាយណាដែលទទួលរងនូវអំពើល្មើស ហើយព្យសនកម្មនៃការខូចខាតមានពិតប្រាកដ ឬ អាចជាអាណាព្យាបាលរបស់ជនរងគ្រោះ។ ចំពោះគោលបំណងនៃការស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី គឺដើម្បីទទួលបាននូវពត៌មានផ្សេងៗ ពាក់ព័ន្ធជាមួយនឹងបទល្មើស ក៏ដូចជាឲ្យអំពើនៃព្យសនកម្មផ្សេងៗ ដែលជាហេតុបណ្តាលមកពីការប្រព្រឹត្តបទល្មើសនិងការទាមទារសំណងការខូចខាត។ ប្រសិនបើក្នុងករណីដើមបណ្តឹងរដ្ឋប្បវេណី ជាជនរងគ្រោះនៃបទល្មើស ដូចច្នេះការស្តាប់ចម្លើយនេះវាពិតជាមានប្រយោជន៍ច្រើនក្នុងការស្រាវជ្រាវពីជនរងគ្រោះ ជាជនដែលជួបហេតុការផ្ទាល់ដោយខ្លួនត្រូវទទួលបានការរំលោភបំពាន ពីសំណាក់ចារី ដែលចម្លើយនេះអាចចង្អុលបង្ហាញមុខ ឬ ឈ្មោះចារី ឬ ជនពាក់ព័ន្ធ អាចជាសហចារី អ្នកផ្តើមគំនិត អ្នកសមគំនិត ឬ សាក្សីផ្សេងទៀត។ ចម្លើយដើមបណ្តឹងរដ្ឋប្បវេណីត្រូវបានរៀបរាប់អំពីថ្ងៃ ខែ ឆ្នាំដែលខ្លួនទទួលរងអំពើល្មើសច្បាប់របស់ពិរុទ្ធជន។ ចម្លើយ

[10] មាត្រា ១៤៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

[11] មាត្រា ១៤៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

[12] មាត្រា ១៤៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

នេះត្រូវរៀបរាប់អំពីទំនាក់ទំនងរវាងអ្នកទាំងពីរ (ជនរងគ្រោះ និងជនត្រូវចោទ)។ ក្នុងរយៈកាលកន្លងមកមុនពេលកើតហេតុ ហើយបរិយាយដល់សកម្មភាពរបស់ជនត្រូវចោទដែលធ្វើមកលើខ្លួន។ ទន្ទឹមនឹងយកចម្លើយពីដំណើររឿងហេតុដែលកើតមានឡើង ចៅក្រមស៊ើបសួរក៏ត្រូវសួរបន្ថែមនូវសំណូមពររបស់ជនរងគ្រោះទៀតផង។ ការធ្វើបែបនេះ គឺដើម្បីឈានដល់ការវិនិច្ឆ័យ បាននូវអំពើរបស់អ្នកប្រព្រឹត្តបទល្មើស និងថែមទាំងផ្តល់នូវភាពយុត្តិធម៌ជូនជនរងគ្រោះ។

ដើមបណ្តឹងរដ្ឋប្បវេណីអាចពឹងពាក់មេធាវីបាន ដើម្បីការពារប្រយោជន៍របស់ខ្លួនបាន។ ក្នុងករណីនេះ ចៅក្រមស៊ើបសួរត្រូវបានកោះហៅមេធាវីរបស់ដើមបណ្តឹងរដ្ឋប្បវេណី យ៉ាងតិចបំផុត ៥ (ប្រាំ) ថ្ងៃ មុនពេលស្តាប់ចម្លើយដើម្បីទុកចិរវេលានេះ ឲ្យមេធាវីអាចពិនិត្យសំណុំរឿងបាន។ ដើមបណ្តឹងរដ្ឋប្បវេណី អាចត្រូវបានគេស្តាប់ចម្លើយតែនៅចំពោះមុខមេធាវីរបស់ខ្លួនប៉ុណ្ណោះ។ ប៉ុន្តែបើមេធាវីដែលត្រូវបានកោះហៅយ៉ាងត្រឹមត្រូវ ហើយមិនបានចូលបង្ហាញខ្លួននៅថ្ងៃ និងម៉ោងតាមកំណត់ទេ ចៅក្រមស៊ើបសួរក៏អាចស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណីដោយគ្មានវត្តមានមេធាវី។ និទ្ទេសស្តីពីអវត្តមាន ត្រូវបានចុះក្នុងកំណត់ហេតុស្តាប់ចម្លើយ ។

ក្នុងករណីពិសេស ចៅក្រមស៊ើបសួរអាចស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណីបានដោយមិនចាំបាច់កោះហៅមេធាវី ប្រសិនបើដើមបណ្តឹងរដ្ឋប្បវេណីបោះបង់ចោលយ៉ាងជាក់លាក់នូវវត្តមានមេធាវីរបស់ខ្លួន។ ការបោះបង់នេះត្រូវចុះនិទ្ទេសនៅក្នុងកំណត់ហេតុមួយដោយឡែកពីកំណត់ហេតុស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី និងត្រូវចុះហត្ថលេខាដោយដើមបណ្តឹងរដ្ឋប្បវេណី ។

ក្នុងករណីបន្ទាន់ ចៅក្រមស៊ើបសួរក៏អាចស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី ដោយមិនចាំបាច់កោះហៅមេធាវីបានដែរ ។ ភាពបន្ទាន់ត្រូវបណ្តាលមកពីគ្រោះថ្នាក់ដល់ស្លាប់ ឬបណ្តាលមកពីភ័យខ្លាចបាត់បង់តំរុយភស្តុតាង។ ប្រភេទនៃភាពបន្ទាន់ត្រូវតែចុះនិទ្ទេសនៅក្នុងកំណត់ហេតុ[13]។ ចៅក្រមស៊ើបសួរក៏អាចស្វែងរកអ្នកបកប្រែបានក្នុងករណីជនរងគ្រោះត្រូវការជាចាំបាច់។

ម្យ៉ាងវិញទៀត នៅក្នុងពេលស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី ព្រះរាជអាជ្ញា និងមេធាវីអាចលើកសំណួរមកសួរ និងពិភាក្សាដេញដោលបាន ដោយមានការអនុញ្ញាតពីចៅក្រមស៊ើបសួរ ។ ក្នុងករណីមិនអនុញ្ញាត ករណីនោះត្រូវបានចុះនិទ្ទេស នៅក្នុងកំណត់ហេតុ[14]។

### ឃ. ការស្តាប់ចម្លើយសាក្សី

សាក្សី គឺជាបុគ្គលដែលបានដឹង ឬបានឃើញហេតុការណ៍ណាមួយជុំវិញការប្រព្រឹត្តបទល្មើសនៅកន្លែងកើតហេតុ។ សាក្សីមានគឺមានពីរប្រភេទគឺ សាក្សីដាក់បន្ទុក និងសាក្សីដោះបន្ទុក។

[13] មាត្រា ១៥០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

[14] មាត្រា ១៥១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

ការស្តាប់ចម្លើយសាក្សី ចៅក្រមស៊ើបសួរ អាចស្តាប់ចម្លើយបុគ្គលគ្រប់រូប ដែលចម្លើយនោះអាចមានប្រយោជន៍នៅក្នុងការសំដែងឲ្យឃើញការពិត ។ ហើយចៅក្រមស៊ើបសួរអាចស្តាប់ចម្លើយសាក្សីដាច់ពីគ្នា ដោយគ្មានវត្តមានជនត្រូវចោទ និងដើមបណ្តឹងរដ្ឋប្បវេណី។ ម្យ៉ាងវិញទៀតចៅក្រមស៊ើបសួរក៏អាចសួរតទល់គ្នារវាងជនត្រូវចោទ ដើមបណ្តឹងរដ្ឋប្បវេណី និងសាក្សីផងបានដែរ។ បុគ្គលគ្រប់រូប ដែលត្រូវបានចៅក្រមស៊ើបសួរកោះហៅក្នុងឋានៈជាសាក្សី ត្រូវតែមកបង្ហាញខ្លួន។ ក្នុងករណីសាក្សីនៅរឹងទទឹង នោះចៅក្រមស៊ើបសួរអាចសុំឲ្យកងកម្លាំងសាធារណៈបង្ខំសាក្សីនេះឲ្យចូលមកបង្ហាញខ្លួនបាន។ ចៅក្រមស៊ើបសួរចេញបញ្ជាឲ្យចូលមកបង្ហាញខ្លួន ដោយបញ្ជានេះត្រូវតែមានអត្តសញ្ញាណរបស់សាក្សី និងត្រូវចុះកាលបរិច្ឆេទ និងចុះហត្ថលេខាដោយចៅក្រមស៊ើបសួរព្រមទាំងមានបោះត្រាផងដែរ[15]។ រាល់ចម្លើយរបស់សាក្សី គឺមានប្រយោជន៍ក្នុងការសម្តែងឲ្យឃើញការពិតនៃអង្គហេតុ កាលណាចម្លើយនោះស៊ីសង្វាក់គ្នាទៅនឹងចម្លើយរបស់ជនត្រូវចោទ ឬ ជនរងគ្រោះ ហើយវាក៏ជាមូលដ្ឋានមួយផ្នែកសម្រាប់វិនិច្ឆ័យរបស់ចៅក្រមស៊ើបសួរ។ ប៉ុន្តែរាល់ចម្លើយរបស់សាក្សីទាំងអស់ ចៅក្រមស៊ើបសួរមានសិទ្ធិសម្រេចថា គួរជឿ ឬ មិនគួរឲ្យជឿ។

មុននឹងអនុញ្ញាតឲ្យសាក្សីស្រាយបំភ្លឺ គឺច្បាប់តម្រូវឲ្យសាក្សីម្នាក់ៗត្រូវស្បថតាមសាសនា ឬជំនឿរបស់ខ្លួនថានឹងនិយាយការពិត ដែលទម្រង់នៃការស្បថត្រូវធ្វើដូចមានកំណត់ក្នុងឧបសម្ព័ន្ធនៃក្រមនីតិវិធីព្រហ្មទណ្ឌ។ ប្រសិនបើសាក្សីមិនចេះភាសាខ្មែរ (និយាយ អាន ស្តាប់) នោះទេ ចៅក្រមស៊ើបសួរអាចស្វែងរកអ្នកបកប្រែម្នាក់ ដើម្បីស្តាប់ចម្លើយសាក្សី។ ចំពោះការធ្វើសម្បថនេះ សាក្សីមួយចំនួនត្រូវបានច្បាប់អនុញ្ញាតឲ្យរួចផុតពីសម្បថមានដូចតទៅ :

- ឪពុក ម្តាយ និងបុព្វជនគ្រប់រូបរបស់ជនត្រូវចោទ ។
- កូនប្រុស កូនស្រី និងបច្ឆាជនគ្រប់រូបផ្សេងទៀតរបស់ជនត្រូវចោទ ។
- បង ប្អូនប្រុស ស្រី របស់ជនត្រូវចោទ ។
- បង ប្អូនប្រុស ស្រីរបស់ជនត្រូវចោទ។
- ប្តី ឬប្រពន្ធរបស់ជនត្រូវចោទ ទោះបីបានលែងលះគ្នាហើយក៏ដោយ ។
- កុមារអាយុតិចជាង ១៤ឆ្នាំ[16]។

ដើម្បីគោរពសិទ្ធិការពារខ្លួន ចៅក្រមស៊ើបសួរមិនអាចស្តាប់ចម្លើយក្នុងឋានៈជាសាក្សី នូវបុគ្គលណាមួយដែលមានតំរុយពិរុទ្ធភាពថាបានប្រព្រឹត្តបទល្មើសនោះទេ គ្រាន់តែជូនដំណឹងអំពីការដាក់ឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការបានហើយ។

---

[15] មាត្រា ១៥៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

[16] មាត្រា ១៥៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

ប្រសិនបើសាក្សីឈឺ ឬមិនអាចធ្វើដំណើរបាន ចៅក្រមស៊ើបសួរ និងក្រឡាបញ្ជី អាចចុះទៅកាន់លំនៅឋាន ឬទីកន្លែងដែលសាក្សីនោះទៅ ដើម្បីទទួលចម្លើយ[17]។

**ខ. ការឆែកឆេរ និងការចាប់យកវត្ថុតាង**

ការឆែកឆេរ និងចាប់យកវត្ថុតាង គឺជាវិធានការមួយដែលចៅក្រមស៊ើបសួរអនុវត្តដើម្បីស្វែងរកការពិតនៃពិរុទ្ធភាពរបស់ជនល្មើសទាំងឡាយណាដែល ប្រព្រឹត្តបទល្មើសបង្កគ្រោះថ្នាក់ដល់សង្គមជាតិ ដល់ប្រយោជន៍របស់ប្រជាពលរដ្ឋ។ តាមក្រមនីតិវិធីព្រហ្មទណ្ឌ ចៅក្រមស៊ើបសួរមានសិទ្ធិក្នុងការឆែកឆេរចាប់យកវត្ថុតាងដើម្បីជាប្រយោជន៍ចំពោះការស្រាវជ្រាវ។

ការឆែកឆេរលំនៅដ្ឋាន ជាវិធានការបង្ខិតបង្ខំរបស់អាជ្ញាធរដែលមានសមត្ថកិច្ច ក្នុងការស្វែងរកវត្ថុតាងនានា សម្រាប់បំភ្លឺការពិតរបស់អំពើអ្វីមួយ ដើម្បីធានាដល់ការដោះស្រាយបណ្តឹងណាមួយឲ្យបានត្រឹមត្រូវតាមច្បាប់។ អំណាចនៃការឆែកឆេរលំនៅដ្ឋាន បណ្តាលឲ្យប៉ះពាល់សិទ្ធិស្របច្បាប់របស់បុគ្គលឯកជន សិទ្ធិខាងលំនៅដ្ឋាន ទ្រព្យសម្បត្តិ សិទ្ធិសេរីភាព កេត្តិយស និងសេចក្តីថ្លៃថ្នូរ។ ដូច្នេះអាជ្ញាធរមានសមត្ថកិច្ចត្រូវតែធ្វើឡើងឲ្យបានត្រឹមត្រូវតឹងរឹងបំផុតដោយមានសំអាងច្បាស់លាស់ ដែលជាមូលដ្ឋានពិត និងតាមបញ្ញត្តិច្បាប់។

ចំពោះវិធានអនុវត្តការឆែកឆេរ ចៅក្រមស៊ើបសួរអាចធ្វើការឆែរឆេរបាននៅចំពោះមុខអ្នកកាន់កាប់ទីកន្លែង ឬ បើគ្មានអ្នកកាន់កាប់ទេ ត្រូវធ្វើនៅចំពោះមុខសាក្សី ២ (ពីរ) នាក់ ដែលខ្លួនចាត់តាំង និងអាជ្ញាធរមូលដ្ឋានដូចជាប៉ុស្តិ៍ ចៅសង្កាត់/ឃុំ មេភូមិ។ ត្រូវចាំថាសាក្សីមិនអាចជានគរបាល ឬ ជាកងរាជអាវុធហត្ថ ដែលជាកងកម្លាំងចូលរួមប្រតិបត្តិការក្នុងការឆែរឆេរបាននោះឡើយ ។

ចៅក្រមស៊ើបសួរ មិនអាចផ្តើមឆែរឆេរមុនម៉ោង ៦ (ប្រាំមួយ) ព្រឹក និង ក្រោយម៉ោង ១៨ (ដប់ប្រាំបី) ល្ងាចបានទេ លើកលែងតែក្នុងករណីឆែរឆេរនៅគ្រប់កន្លែងដែលផលិត រក្សាទុក ជួញដូរ ចែកចាយ ឬប្រើប្រាស់ គ្រឿងញៀន ។

ចៅក្រមស៊ើបសួរក៏អាចធ្វើការឆែរឆេរនៅក្នុងការិយាល័យមេធាវីផងដែរ ប៉ុន្តែត្រូវធ្វើនៅចំពោះមុខប្រធានគណៈមេធាវី ឬ ប្រតិភូរបស់ប្រធានគណៈមេធាវីនោះ ។

ក្នុងការឆែកឆេរចៅក្រមស៊ើបសួរត្រូវធ្វើកំណត់ហេតុ ស្តីអំពីការឆែរឆេរដោយមានចុះហត្ថលេខារបស់ខ្លួន និងក្រឡាបញ្ជី រួមជាមួយអ្នកកាន់កាប់ទីកន្លែង ឬ សាក្សី ២ (ពីរ) នាក់ ។

កំណត់ហេតុនេះ ត្រូវតែចុះនិទ្ទេសអំពីអត្តសញ្ញាណរបស់អ្នកកាន់កាប់ទីកន្លែងទាំងអស់ ឬសាក្សីនីមួយៗ។ កាលបើការឆែរឆេរប្រព្រឹត្តទៅនៅក្នុងការិយាល័យមេធាវី កំណត់ហេតុនេះត្រូវចុះ

[17] មាត្រា ១៥៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

និទ្ទេសអំពីវត្តមានរបស់ប្រធានគណៈមេធាវី ឬរបស់ប្រតិភូនៃប្រធានគណៈមេធាវីនេះ[18]។

ក្នុងប្រតិបត្តិការនៃការឆែកឆេរ ចៅក្រមស៊ើបសួរអាចចាប់យកវត្ថុតាងដែលចាប់បាន និងមានបិទស្លាកបោះត្រាលើវត្ថុតាងនោះ។ ក្រោយពីបានបង្ហាញវត្ថុដែលចាប់ដល់អ្នកកាន់កាប់ទីកន្លែង ឬដល់សាក្សីទាំង ២ នាក់ រួចមក ចៅក្រមស៊ើបសួរធ្វើកំណត់ហេតុស្តីពីការចាប់ ដែលរួមមានបញ្ជីសារពើភ័ណ្ឌនៃវត្ថុដែលចាប់ក ។ កំណត់ហេតុស្តីពីការចាប់នេះ ត្រូវមានចុះហត្ថលេខារបស់ចៅក្រមស៊ើបសួរ និងក្រឡាបញ្ជី រួមជាមួយអ្នកកាន់កាប់ទីកន្លែង ឬសាក្សី ២ នាក់ ។ កំណត់ហេតុត្រូវមានចុះនិទ្ទេសអំពីអត្តសញ្ញាណនៃអ្នកកាន់កាប់ទីកន្លែង ឬសាក្សីនីមួយៗ ។

បន្ទាប់ពីការចាប់យកវត្ថុតាង នៅពេលដែលមិនទាន់ចេញដីកាដំណោះស្រាយរឿងនៅឡើយទេ ចៅក្រមស៊ើបសួរ មានសមត្ថកិច្ចប្រគល់សងទៅម្ចាស់ដើមវិញនូវវត្ថុដែលចាប់បាន កាលណាកម្មសិទ្ធិនេះគ្មានការជំទាស់អ្វីប្រាកដប្រជាទេ។ លើសពីនេះចៅក្រមស៊ើបសួរត្រូវតែធ្វើការសម្រេចតាមដីកាដែលមានសំអាងហេតុ ក្រោយពីបានទទួលមតិពីព្រះរាជអាជ្ញា ។ ហើយដីកាសម្រេចនេះ ត្រូវឲ្យដំណឹងជាបន្ទាន់ដល់អ្នកប្តឹង និងមេធាវីរបស់អ្នកប្តឹង ប្រសិនបើមាន ។ ប៉ុន្តែវត្ថុតាងដែលចាប់យកមិនគួរប្រគល់សងទៅឲ្យអ្នកប្តឹងសុំទេ កាលណាវិធានការនេះ អាចបង្កជាឧបសគ្គដល់ការសំរេចឲ្យឃើញការពិត ។

ចំពោះវត្ថុដែលមានគ្រោះថ្នាក់ដលល់បុគ្គល ឬទ្រព្យសម្បត្តិដូចជាអាវុធ ឬជាតិផ្ទុះ ព្រមទាំងវត្ថុ ដែលការកាន់កាប់មិនស្របច្បាប់ មិនអាចប្រគល់សងទៅឲ្យសាមីខ្លួនបានទេ។ វត្ថុទាំងនេះត្រូវរឹបអូសជាកម្មសិទ្ធិរបស់រដ្ឋ[19]។

### ច. ការធ្វើកោសលវិច្ឆ័យ

ភាពចាំបាច់នៃការធ្វើកោសលវិច្ឆ័យ ធ្វើឲ្យយើងអាចរកឃើញ ឬ អាចឲ្យយើងប្រើប្រាស់សញ្ញាសម្គាល់មួយចំនួន ឬ ភស្តុតាងផ្សេងៗដោយសារមធ្យោបាយបច្ចេកទេស និង វិទ្យាសាស្ត្រមួយចំនួន។ នៅក្នុងដំណាក់កាលនៃការស៊ើបសួរ ដើម្បីជាប្រយោជន៍ដល់ការស្រាវជ្រាវរកការពិត ច្បាប់បានអនុញ្ញាតឲ្យចៅក្រមស៊ើបសួរក៏អាចបង្គាប់ឲ្យអ្នកជំនាញធ្វើកុសលវិច្ឆ័យ ដោយធ្វើការវិភាគ និងបញ្ជាក់លទ្ធផលដោយអ្នកជំនាញ ប្រសិនបើមានករណីខ្លះចៅក្រមស៊ើបសួរមិនអាចធ្វើការវាយតម្លៃខ្លួនឯងបាននោះដូចជា ប្រភេទគ្រឿងញៀន សាកសព ប្រភេទឈាម ប្រភេទអាវុធ (កាំភ្លើង កាំបិទ ឬ ឧបករណ៍ផ្សេងៗដែលប្រើសម្រាប់ប្រព្រឹត្តបទល្មើស) ។

កាលណាចៅក្រមស៊ើបសួរយល់ឃើញថាបញ្ហាបច្ចេកទេសគឺបានកើតឡើង នោះចៅក្រម

---

[18] មាត្រា ១៥៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

[19] មាត្រា ១៦១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

ស៊ើបសួរអាចបង្គាប់ឲ្យធ្វើកោសលវិច្ឆ័យដោយឯកឯង ឬ តាមពាក្យសុំរបស់ព្រះរាជអាជ្ញារបស់ជនត្រូវចោទ ឬដើមបណ្តឹងរដ្ឋប្បវេណី ។

កាលណាចៅក្រមស៊ើបសួរបដិសេធមិនព្រមធ្វើតាមពាក្យសុំធ្វើកោសលវិច្ឆ័យទេ ចៅក្រមស៊ើបសួរត្រូវសំរេចតាមដីកាដោយមានសំអាងហេតុ ។ ដីកាត្រូវសំរេចក្នុងរយះពេល ៥ (ប្រាំ) ថ្ងៃ ប្រសិនបើពាក្យសុំនោះចេញមកពីព្រះរាជអាជ្ញា និង ១ (មួយ) ខែ ប្រសិនបើពាក្យនោះចេញមកពីជនត្រូវចោទ ឬដើមបណ្តឹងរដ្ឋប្បវេណី ។ ដីកាសម្រេចនេះត្រូវជូនដំណឹងឲ្យដល់អ្នកប្តឹងជាបន្ទាន់[20]។

ចៅក្រមស៊ើបសួរ តាមធម្មតាត្រូវជ្រើសរើសអ្នកជំនាញដែលត្រូវបានចុះឈ្មោះនៅក្នុងបញ្ជីថ្នាក់ជាតិនៃអ្នកជំនាញ ។

ចៅក្រមស៊ើបសួរ តាមដីកាដោយមានសំអាងហេតុជាពិសេស អាចចាត់តាំងអ្នកជំនាញដែលគ្មានឈ្មោះក្នុងបញ្ជីថ្នាក់ជាតិបាន ។ ក្នុងករណីនេះអ្នកជំនាញត្រូវស្បថតាម សាសនា ឬជំនឿរបស់ខ្លួនថា ខ្លួននិងផ្តល់ជំនួយដោយស្មោះត្រង់ដល់ការស្វែងរកយុត្តិធម៌[21]។

ចំពោះដីកាចាត់តាំងអ្នកជំនាញ គឺត្រូវបានចាត់តាំងតាមដីការបស់ចៅក្រមស៊ើបសួរ ដែលដីកានេះត្រូវបញ្ជាក់អំពីបេសកកម្មរបស់អ្នកជំនាញ ព្រមទាំងរយៈពេលដែលត្រូវបំពេញបេសកកម្មនេះផងដែរ ។ ប៉ុន្តែបេសកកម្មអាចទាក់ទងទៅនិងបញ្ហាដែលមានលក្ខណៈបច្ចេកទេសតែប៉ុណ្ណោះ។ ជាក់ស្តែងការធ្វើកោសលវិច័យភាគច្រើន គឺធ្វើឡើងទៅលើការស៊ើបសួរពីបទល្មើសគ្រឿងញៀន ដោយចៅក្រមស៊ើបសួរ ចេញដីកាចាត់តាំងអ្នកជំនាញដើម្បីឲ្យធ្វើកុសលវិច័យលើវត្ថុដែលសង្ស័យថាមានផ្ទុកសារធាតុញៀន ដើម្បីទទួលបានលទ្ធផល បញ្ជាក់ថាវត្ថុនោះមានផ្ទុកសារធាតុញៀនដែរ ឬ ទេ? តើជាប្រភេទថ្នាំអ្វី និងមានកម្រិតជាតុសុទ្ធចំនួនប៉ុន្មាន? ករណីនេះ ការធ្វើកុសលវិច័យពិតជាមានសារសំខាន់បំផុតពីព្រោះ ការចោទប្រកាន់ជនណាម្នាក់ថាជួញដូរ ឬ រក្សាទុកដោយខុសច្បាប់នូវសារធាតុញៀន លុះត្រាតែវត្ថុតាងដែលចាប់យកនោះពិតជាមានសារធាតុញៀនមែនទើបអាចធ្វើការចោទប្រកាន់បាន អំពើបទល្មើសនេះបានដោយស្របនឹងច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។ ករណីនេះប្រសិនបើលទ្ធផលនៃកោសលវិច័យបញ្ជាក់ថា វត្ថុតាងនោះពិតជាមានសារធាតុញៀនវិញនោះ គឺតុលាការអាចធ្វើការចោទប្រកាន់បាន ប៉ុន្តែប្រសិនបើគ្មានសារធាតុញៀនវិញនោះ គឺមិនអាចចោទប្រកាន់លើជនត្រូវចោទបានឡើយ មានន័យថាត្រូវដោះលែងព្រោះគ្មានបទល្មើស។

ម្យ៉ាងវិញទៀតប្រសិនបើជាការគួរ ជាទូទៅចៅក្រមស៊ើបសួរប្រគល់វត្ថុដែលចាប់បានមួយផ្នែក ឬទាំងអស់នោះជូនអ្នកជំនាញ ។ ចៅក្រមស៊ើបសួរត្រូវធ្វើកំណត់ហេតុស្តីពីការប្រគល់វត្ថុដែល

[20] មាត្រា ១៦២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

[21] មាត្រា ១៦៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

ចាប់បាន ។ អ្នកជំនាញអាចបំបែកស្លាកដែលបិទដើម្បីធ្វើកោសលវិច័យបាន ។ ប្រសិនបើកោសលវិច័យនេះអាចធ្វើឲ្យខូចខាត ឬវិនាសដល់វត្ថុដែលចាប់បាននោះ អ្នកជំនាញត្រូវជូនពត៌មានដល់ចៅក្រមស៊ើបសួរ និងសុំការអនុញ្ញាតពីចៅក្រមនេះ មុននិងចាប់ផ្តើមប្រតិបត្តិការរបស់ខ្លួន ។

ការត្រួតពិនិត្យបេសកកម្មរបស់អ្នកជំនាញដោយចៅក្រមស៊ើបសួរ តម្រូវឲ្យអ្នកជំនាញត្រូវតែជូនពត៌មានដល់ចៅក្រមស៊ើបសួរអំពីការប្រព្រឹត្តទៅនៃបេសកកម្មរបស់ខ្លួន ការលំបាកដែលខ្លួនអាចជួបប្រទះ[22]។

ប្រសិនបើអ្នកជំនាញមិនគោរពរយៈពេលដែលកំណត់ដោយចៅក្រមស៊ើបសួរទេ ចៅក្រមស៊ើបសួរចាត់អ្នកជំនាញផ្សេងទៀតជំនួសអ្នកជំនាញនោះ។ ប្រសិនបើកាលៈទេសៈតម្រូវ នោះចៅក្រមស៊ើបសួរអាចអនុញ្ញាតតាមដីកាសម្រេចឲ្យធ្វើការពន្យារពេលបាន ។

កាលណារបាយការណ៍នៃការធ្វើកោសលវិច័យត្រូវបានបញ្ចប់ហើយ ចៅក្រមស៊ើបសួរត្រូវជូនពត៌មានដល់ព្រះរាជអាជ្ញាដើម្បីដាក់ចូលក្នុងសំណុំរឿងស៊ើបសួរ ។ បន្ទាប់មកចៅក្រមស៊ើបសួរកោះហៅជនត្រូវចោទ ហើយនិងមេធាវីដើម្បីប្រាប់ឲ្យដឹងពីសេចក្តីសន្និដ្ឋាននៃកោសលវិច័យនេះ។ ចៅក្រមស៊ើបសួរអាចកោះហៅដើមបណ្តឹងរដ្ឋប្បវេណី និងមេធាវីផងដែរ ដើម្បីប្រាប់ឲ្យដឹងពីសេចក្តីសន្និដ្ឋាននៃកោសលវិច័យ ។

ចៅក្រមស៊ើបសួរត្រូវតែកំណត់រយៈពេលដែលអនុញ្ញាតឲ្យព្រះរាជអាជ្ញា ជនត្រូវចោទ ឬដើមបណ្តឹងរដ្ឋប្បវេណីដាក់ពាក្យសុំធ្វើសកោសលវិច្ឆ័យបន្ថែម ឬប្រតិកោសលវិច្ឆ័យ ។ រយៈពេលនេះមិនអាចតិចជាង ១០ (ដប់)ថ្ងៃនោះទេ ។ ក្នុងរយៈពេលនេះ សំណុំរឿងដែលរួមមានរបាយការណ៍កោសលវិច័យ អាចត្រូវបានពិនិត្យមើលដោយមេធាវី ។

គ្រប់ពាក្យសំដីកោសលវិច្ឆ័យបន្ថែម ឬប្រតិកោសលវិច្ឆ័យ ត្រូវតែមានសំអាងហេតុ និងធ្វើឡើងជាលាយលក្ខណ៍អក្សរ ។

កាលណាចៅក្រមស៊ើបសួរមិនព្រមសម្រេចចិត្តធ្វើតាមពាក្យសុំធ្វើកោសលវិច្ឆ័យបន្ថែម ឬប្រតិកោសលវិច្ឆ័យទេ ចៅក្រមស៊ើបសួរត្រូវសម្រេចតាមដីកាដោយមានសំអាងហេតុ ។ ដីកាត្រូវសម្រេចក្នុងរយៈពេល ៥ (ប្រាំ) ថ្ងៃ ប្រសិនបើពាក្យសុំចេញមកពីព្រះរាជអាជ្ញា និង ១ (មួយ) ខែ ប្រសិនបើពាក្យនេះចេញពីជនត្រូវចោទ ដើមបណ្តឹងរដ្ឋប្បវេណី ។ ដីកា ត្រូវឲ្យដំណឹងជាបន្ទាន់ដល់អ្នកប្តឹង។ គ្រប់ពាក្យសុំធ្វើកោសលវិច័យបន្ថែម ឬប្រតិកោសលវិច័យដែលធ្វើឡើងក្រោយផុតរយៈពេលដែលកំណត់ដោយចៅក្រមស៊ើបសួរ ត្រូវដាក់បញ្ចូនក្នុងសំណុំរឿង ។

[22] មាត្រា ១៦៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

បើចៅក្រមស៊ើបសួរដែលបានទទួលពាក្យសុំធ្វើកោសលវិច័យ ធ្វើកោសលវិច័យបន្ថែម ឬប្រតិកោសលវិច្ឆ័យ មិនព្រមសំរេចក្នុងរយៈពេលនេះ អ្នកដែលសុំអាចធ្វើពាក្យប្តឹងដោយផ្ទាល់ទៅតាមរយៈ ពាក្យសុំដល់សភាស៊ើបសួរដែលសម្រេចជំនួសចៅក្រមស៊ើបសួរ[23]។

ចំណែកឯសោហ៊ុយសំរាប់ធ្វើកោសលវិច័យជាបន្ទុករបស់អ្នកស្នើសុំ ។ កាលណាចៅក្រមស៊ើបសួរ ព្រះរាជអាជ្ញា ឬមន្ត្រីនគរបាលយុត្តិធម៌ ស្នើសុំឲ្យធ្វើកោសលវិច័យ កោសលវិច័យបន្ថែម ឬធ្វើប្រតិកោសលវិច័យ សោហ៊ុយទាំងនេះជាបន្ទុករបស់រដ្ឋ[24]។

**ឆ. ការស្តាប់ទូរស័ព្ទ**

ការស្តាប់ទូរស័ព្ទ ជាអាទ៍ ដែលបង្គាប់ដោយចៅក្រមស៊ើបសួរ ត្រូវបានធ្វើឡើងដើម្បីតម្រូវការចាំបាច់ក្នុងការសំដែងឲ្យឃើញនូវការពិត ឬ ជាប្រយោជន៍ចំពោះបទល្មើសទាំងឡាយណាដែលមានពាក់ព័ន្ធ នឹងបណ្តាញទូរស័ព្ទដែលចៅក្រមស៊ើបសួរអាចបង្គាប់ឲ្យស្តាប់ និងថតការសន្ទនាតាមទូរស័ព្ទបាន ។ លើសពីនេះចៅក្រមស៊ើបសួរក៏អាចបង្គាប់ឲ្យចាប់ និងថតគ្រប់ការ ឆ្លើយឆ្លងគ្នា តាមមធ្យោបាយទូរគមនាគមន៍ផងដែរដូចជា សារតាមរយៈទូរសារ ឬសារតាមអិនធើណែតជាអាទ៍។ ឧទាហរណ៍ ៖ ករណីការស៊ើបអង្កេតពីបទល្មើសគម្រាមថានឹងសម្លាប់ ដែលជនរងគ្រោះអះអាងថាជនត្រូវចោទបានទូរស័ព្ទមកគម្រាមខ្លួនជាច្រើនដង។ ករណីនេះចៅក្រមស៊ើបសួរមានសិទ្ធិបង្គាប់ឲ្យមន្ត្រីដែលមានជំនាញធ្វើការថតយកការសន្ទនាតាមទូរស័ព្ទសម្រាប់ទុកជាភស្តុតាង។

ចៅក្រមស៊ើបសួរអាចសុំឲ្យគ្រប់អង្គភាពសាធារណៈគ្រប់ជាន់ថ្នាក់ទាំងអស់ ឬ គ្រប់មន្ត្រីរាជការជំនាញតាំង ឧបករណ៍បច្ចេកទេស និង ធ្វើការថត ដោយតម្រូវឲ្យចៅក្រមស៊ើបសួរបញ្ជាក់នៅក្នុងដីកាសម្រេចរបស់ខ្លួន អំពីប្រភេទនៃទំនាក់ទំនងដែលត្រូវចាប់ ព្រមទាំងអំពីរយៈពេលនៃបេសកកម្មរបស់ខ្លួន ។

គ្រប់អង្គភាពសាធារណៈ មន្ត្រីរាជការដែលបានចាត់តាំង ត្រូវបំពេញតាមពាក្យសុំរបស់ចៅក្រម ស៊ើបសួរ ។ នៅក្នុងពេលអនុវត្តបេសកកម្ម អង្គភាពសាធារៈ ឬគ្រប់មន្ត្រីរាជការដែលចាត់តាំង ត្រូវតែជូនពត៌មានដល់ចៅក្រមស៊ើបសួរអំពីការប្រព្រឹត្តទៅនៃបេសកកម្មអំពីការលំបាកជាយថាហេតុ ។ កាលណាបេសកកម្មត្រូវបានបំពេញរួចហើយ អង្គភាពសាធារណៈ ឬ គ្រប់មន្ត្រីរាជការត្រូវចម្លងជាលាយលក្ខណ៍អក្សរនូវសំឡេងដែលថតបាន ។ ការធ្វើឲ្យទៅជា លាយលក្ខណ៍អក្សរនេះ ត្រូវឆ្លុះបញ្ចាំងយ៉ាងត្រឹមត្រូវនូវខ្លឹមសារនៃសំឡេងដែលថតបាន ។ សំឡេងដែលថតបាននេះត្រូវប្រគល់ជូនចៅក្រមស៊ើបសួរ និងបិទស្លាក។

[23] មាត្រា ១៧០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

[24] មាត្រា ១៧១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

គ្រប់ពេលវេលា ចៅក្រមស៊ើបសួរអាចចុះទៅកាន់ទីកន្លែងដែលធ្វើការចាប់ និងថតចូលទៅកាន់ទីកន្លែងទាំងនោះ មិនអាចត្រូវហាមឃាត់ដល់ចៅក្រមស៊ើបសួរដោយសំអាងលើមូលហេតុអ្វីបានទេទោះបីជាកន្លែងឃោធាក៏ដោយ។ ម្យ៉ាងទៀតចៅក្រមស៊ើបសួរក៏អាចធ្វើកិច្ចការនេះតាមដីកាចាត់ឲ្យស៊ើបសួរជំនួសបានផងដែរ[25]។

## ផ្នែកទី២ កិច្ចការស្រាវទៅលើអង្គហេតុដោយការស្នើសុំឱបំពេញកិច្ច

ជាគោលការណ៍ស៊ើបសួរជាតួនាទីរបស់ចៅក្រមស៊ើបសួរ ដែលច្បាប់តម្រូវឲ្យចៅក្រមស៊ើបសួរអាចបំពេញភារកិច្ចរបស់ខ្លួន តាមដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួររបស់ព្រះរាជអាជ្ញា។ បន្ថែមពីលើនេះ ចៅក្រមស៊ើបសួរក៏អាចបើកកិច្ចស៊ើបសួរតាមរយៈការស្នើសុំឲ្យបំពេញកិច្ចដោយជនត្រូវចោទ និងដោយដើមបណ្ដឹងរដ្ឋប្បវេណីផងដែរ នេះសបញ្ជាក់ឲ្យឃើញថាទាំងព្រះរាជអាជ្ញាក្ដី ជនត្រូវចោទក្ដី និង ដើមបណ្ដឹងរដ្ឋប្បវេណីក្ដី គឺមានសិទ្ធិអនុញ្ញាតដោយច្បាប់យ៉ាងពេញលេញក្នុងការសម្រេចចិត្តស្នើសុំចៅក្រមស៊ើបសួរស្វែងរកការពិត ដែលខ្លួនគិតថាមានប្រយោជន៍ដល់រឿងក្ដីព្រហ្មទណ្ឌ។ ប៉ុន្តែក្នុងករណីដែល ចៅក្រមស៊ើបសួរមានភារកិច្ចណាមួយដែលជាឧបសគ្គរាំងស្ទះដល់ការស៊ើបសួរស្វែងរកការពិតនោះ តាមរយៈក្រមនីតិវិធីព្រហ្មទណ្ឌក៏បានអនុញ្ញាតឲ្យចៅក្រមស៊ើបសួរអាចចាត់ឲ្យចៅក្រមផ្សេងទៀត ឬ មន្ត្រីនគរបាលយុត្តិធម៌ឲ្យបំពេញកិច្ចស្រាវជ្រាវជំនួសឲ្យខ្លួនបានផងដែរ។

ដើម្បីឱ្យយល់កាន់តែច្បាស់នូវការស្នើសុំឲ្យបំពេញកិច្ច ទៅលើបទល្មើសដោយមានការស្នើរសុំដោយព្រះរាជអាជ្ញា ជនត្រូវចោទ និង ដើមបណ្ដឹងរដ្ឋប្បវេណី ព្រមទាំងកិច្ចស៊ើបសួរជំនួសដែលបំពេញដោយចៅក្រមផ្សេងទៀត និង កិច្ចស៊ើបសួរជំនួសដែលបំពេញដោយមន្ត្រីនគរបាលយុត្តិធម៌ យើងបានធ្វើការបែងចែកជាពីរ កថាខណ្ឌធំៗក្នុងគោលបំណងជួយសម្រួលប្រធានបទឲ្យកាន់តែមានន័យគ្រប់គ្រាន់។

### កថាខណ្ឌទី១ ការចូលរួមតាមរយៈសំណើរបំពេញកិច្ចដោយភាគី

ចំពោះសំណើរសុំឲ្យបំពេញកិច្ច គឺជានីតិវិធីមួយដែលអនុញ្ញាតឱ្យព្រះរាជអាជ្ញា ជនត្រូវចោទ ដើមបណ្ដឹងរដ្ឋប្បវេណី ស្នើរសុំឱ្យចៅក្រមស៊ើបសួរណាមួយដែលខ្លួនយល់ឃើញថាមានប្រយោជន៍ក្នុងការសម្ដែងឲ្យឃើញការពិត។ ក្នុងករណីមានការស្នើរសុំឱ្យបំពេញកិច្ចណាមួយ ចៅក្រមស៊ើបសួរមិនជាប់កាតព្វកិច្ចត្រូវតែស៊ើបសួរតាមការស្នើរសុំនោះ។ ប៉ុន្តែចៅក្រមស៊ើបសួរអាចបដិសេធសំណើរបានដោយតម្រូវឲ្យជូនដំណឹងដល់អ្នកស្នើសុំ។ ប្រសិនបើគ្មានជូនដំណឹងអំពីការបដិសេធ

[25] មាត្រា ១៧២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

ដល់អ្នកស្នើសុំទេ នោះអ្នកស្នើសុំអាចប្ដឹងឧទ្ធរណ៍ទៅសភាស៊ើបសួរ។

**ក. ការស្នើសុំបំពេញកិច្ចដោយព្រះរាជអាជ្ញា**

ជាគោលការណ៍ នៅគ្រប់ពេលវេលានៃការស៊ើបសួរ ព្រះរាជអាជ្ញាមានសិទ្ធិស្នើសុំឱ្យចៅក្រមធ្វើកិច្ចស៊ើបសួរណាមួយដែលខ្លួនយល់ឃើញថាមានប្រយោជន៍។ ជាធម្មតាការស្នើសុំឲ្យបំពេញកិច្ចរបស់ព្រះរាជអាជ្ញាភាគច្រើន គឺមានគោលបំណងក្នុងការបំពេញបន្ថែមនូវចំណុចខ្វះខាតដែលចៅក្រមស៊ើបសួរ បានបំពេញដើម្បីឲ្យកាន់តែមានភាពច្បាស់លាស់។ ដូច្នេះនៅគ្រប់ពេលវេលា នៃការស៊ើបសួរព្រះរាជអាជ្ញាអាចសុំឲ្យចៅក្រមស៊ើបសួរ ធ្វើកិច្ចស៊ើបសួរណាមួយដែលខ្លួនយល់ឃើញថាមានប្រយោជន៍។ ករណីនេះបើចៅក្រមស៊ើបសួរ មិនព្រមធ្វើតាមសេចក្ដីសន្និដ្ឋានរបស់ព្រះរាជអាជ្ញាទេនោះចៅក្រមស៊ើបសួររូបនេះ ត្រូវចេញដីកាបដិសេធនៅក្នុងរយៈពេល ១៥ (ដប់ប្រាំ) ថ្ងៃបន្ទាប់ពីខ្លួនទទួលបាន។ ហើយដីកាដែលចៅក្រមស៊ើបសួរសម្រេចចេញ ត្រូវមានសំអាងហេតុ និងត្រូវជូនដំណឹងជាបន្ទាន់ទៅព្រះរាជអាជ្ញា ក្នុងថេរវេលាយ៉ាងឆាប់បំផុត។ ប៉ុន្តែក្នុងករណី ដែលចៅក្រមស៊ើបសួរមិនបានធ្វើការសម្រេចនៅក្នុងថេរវេលា ១៥ (ដប់ប្រាំ) ថ្ងៃទេ ព្រះរាជអាជ្ញាអាចប្ដឹងដោយផ្ទាល់ទៅសភាស៊ើបសួរតាមរយៈពាក្យសុំ ដើម្បីឱ្យសភាស៊ើបសួរសម្រេចជំនួសចៅក្រមស៊ើបសួរ[26]។

**ខ. ការស្នើសុំបំពេញកិច្ចដោយជនត្រូវចោទ**

នៅគ្រប់ពេលវេលានៃការស៊ើបសួរ ជនត្រូវចោទមានសិទ្ធិស្នើសុំឲ្យចៅក្រមស៊ើបសួរ សួរចម្លើយខ្លួន ស្ដាប់ចម្លើយសាក្សី សួរតទល់គ្នា ឬ ចុះទៅដល់ទីកន្លែងបានដោយពាក្យសុំត្រូវធ្វើជាលាយលក្ខណ៍អក្សរ ហើយមានសំអាងហេតុ។ ករណីដែលចៅក្រមស៊ើបសួរមិនព្រមធ្វើតាមពាក្យសុំនោះទេ ចៅក្រមស៊ើបសួរត្រូវចេញដីកាបដិសេធនៅក្នុងថិរវេលា ១ (មួយ) ខែ ក្រោយពីទទួលពាក្យសុំ។ ដីកាត្រូវមានសំអាងហេតុ ហើយត្រូវជូនដំណឹងជាបន្ទាន់ដល់ព្រះរាជអាជ្ញា និងជនត្រូវចោទ។ ប្រសិនបើចៅក្រមស៊ើបសួរមិនបានសម្រេចក្នុងថេរវេលា ១ (មួយ) ខែនោះទេ ជនត្រូវចោទអាចប្ដឹងដោយផ្ទាល់សុំសភាស៊ើបសួរតាមរយៈពាក្យសុំ ដើម្បីឱ្យសភាស៊ើបសួរសម្រេចជំនួសចៅក្រមស៊ើបសួរ[27]។

**គ. ការស្នើសុំបំពេញកិច្ចដោយដើមបណ្ដឹងរដ្ឋប្បវេណី**

នៅគ្រប់ពេលវេលានៃការស៊ើបសួរ ដើមបណ្ដឹងរដ្ឋប្បវេណីមានសិទ្ធិស្នើសុំឲ្យចៅក្រមស៊ើបសួរសួរចម្លើយខ្លួន ស្ដាប់ចម្លើយសាក្សី សួរចម្លើយជនត្រូវចោទ សួរតទល់គ្នា ឬ ចុះទៅដល់ទីកន្លែងបាន

[26] មាត្រា ១៣២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

[27] មាត្រា ១៣៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

ដោយពាក្យសុំត្រូវធ្វើជាលាយលក្ខណ៍អក្សរ ហើយមានសំអាងហេតុ។ ករណីដែលចៅក្រមស៊ើបសួរមិនព្រមធ្វើតាមពាក្យសុំនោះទេ ចៅក្រមស៊ើបសួរត្រូវចេញដីកាបដិសេធនៅក្នុងថិរវេលា ១ (មួយ) ខែក្រោយពីទទួលពាក្យសុំ។ ដីកាត្រូវមានសំអាងហេតុ ហើយត្រូវជូនដំណឹងជាបន្ទាន់ដល់ព្រះរាជអាជ្ញា និងដើមបណ្ដឹងរដ្ឋប្បវេណី។ ប្រសិនបើចៅក្រមស៊ើបសួរមិនបានសម្រេចក្នុងថេរវេលា ១ (មួយ) ខែទេ ដើមបណ្ដឹងរដ្ឋប្បវេណីអាចប្ដឹងដោយផ្ទាល់សុំសភាស៊ើបសួរតាមរយៈពាក្យសុំ ដើម្បីឱ្យសភាស៊ើបសួរសម្រេចជំនួសចៅក្រមស៊ើបសួរ[28]។

## កថាខណ្ឌទី២ ការបំពេញកិច្ចស្រាវជ្រាវតាមរយៈដីកាចាត់ឲ្យស៊ើបសួរជំនួស

ការបំពេញកិច្ចស្រាវជ្រាវតាមរយៈដីកាចាត់ឲ្យស៊ើបសួរជំនួស ជាវិធានមួយដែលចៅក្រមស៊ើបសួរអាចផ្ទេរភារកិច្ចរបស់ខ្លួនទៅឱ្យបុគ្គលដែលមានសមត្ថកិច្ចក្នុងការបំពេញកិច្ច។ ធ្វើបែបនេះ គឺជាការសុំរបស់ចៅក្រមស៊ើបសួរ ដើម្បីឱ្យចៅក្រមស៊ើបសួរផ្សេង ឬមន្ត្រីនគរបាលយុត្តិធម៌ ឬអង្គភាពនគរបាលយុត្តិធម៌បំពេញកិច្ចមួយចំនួនតាមរយៈដីកាចាត់ឲ្យស៊ើបសួរជំនួស[29]។

ក្នុងដីកាចាត់ឲ្យស៊ើបសួរជំនួស ត្រូវបញ្ជាក់អំពីប្រភេទនៃកិច្ចដែលត្រូវធ្វើ។ កិច្ចនោះត្រូវតែមានទំនាក់ទំនងដោយផ្ទាល់ជាមួយបទល្មើសដែលបានចោទប្រកាន់។ ដីកាចាត់ឲ្យស៊ើបសួរជំនួសត្រូវតែណែនាំឲ្យបានច្បាស់លាស់ និងមិនត្រូវប្រគល់សិទ្ធិជាលក្ខណៈទូទៅទេ។ ករណីចៅក្រមស៊ើបសួរកំណត់ថិរវេលាត្រូវអនុវត្តដីកាចាត់ឲ្យស៊ើបសួរនេះ។ ដីកាចាត់ឲ្យស៊ើបសួរត្រូវចុះកាលបរិច្ឆេទ និងចុះហត្ថលេខាដោយចៅក្រមស៊ើបសួរ និង មានបោះត្រាផង។ ម្យ៉ាងទៀតចៅក្រមស៊ើបសួរអាចដកហូតដីកាចាត់ឲ្យស៊ើបសួរជំនួសបានគ្រប់ពេលវេលា[30]។

ជាទូទៅ រាល់កិច្ចស៊ើបសួរទាំងអស់អាចជាកម្មវត្ថុនៃដីកាចាត់ឲ្យស៊ើបសួរជំនួស។ ប៉ុន្តែក្រមនីតិវិធីព្រហ្មទណ្ឌបានដាក់កំហិតខ្លះដល់ការប្រគល់សិទ្ធិឲ្យមន្ត្រីនគរបាលយុត្តិធម៌។ ចៅក្រមស៊ើបសួរមិនអាចប្រគល់សិទ្ធិឲ្យមន្ត្រីនគរបាលយុត្តិធម៌ ធ្វើការស៊ើបសួរជំនួសទាក់ទិននឹងការសួរចម្លើយជនត្រូវចោទ និង ការស្ដាប់ចម្លើយដើមបណ្ដឹងរដ្ឋប្បវេណី[31]។

នៅក្នុងការបំពេញកិច្ចស៊ើបសួរជំនួសចៅក្រមស៊ើបសួរ មន្ត្រីនគរបាលយុត្តិធម៌ ដែលស្ដាប់ចម្លើយសាក្សីត្រូវឲ្យសាក្សីនោះស្បថជាមុនសិន មុនសឹងស្ដាប់ចម្លើយ។ ប្រសិនបើមានការឃាត់ខ្លួនក្នុងក្របខណ្ឌនៃការអនុវត្តដីកាចាត់ឲ្យស៊ើបសួរជំនួស។ ប៉ុន្តែអំណាចដែលប្រគល់ឲ្យព្រះរាជអាជ្ញា

[28] មាត្រា ១៣៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

[29] មាត្រា ១៧៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

[30] មាត្រា ១៧៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

[31] មាត្រា ១៨០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

ត្រូវបានប្រើប្រាស់ដោយចៅក្រមស៊ើបសួរ[32]។

ចំពោះអ្នកដែលអាចទទួលការចាត់ឲ្យស៊ើបសួរជំនួសរួមមាន ចៅក្រមនៃតុលាការរបស់ខ្លួន ឬ តុលាការផ្សេងទៀត និងមន្ត្រីនគរបាលយុត្តិធម៌។

### ក. មូលហេតុនៃការចាត់ឲ្យបំពេញកិច្ចស៊ើបសួរជំនួស

ជាការពិតណាស់ចៅក្រមស៊ើបសួរ មានតួនាទីយ៉ាងសំខាន់ក្នុងដំណើរការនីតិវិធីព្រហ្មទណ្ឌ តាមរយៈការស៊ើបសួររបស់គាត់។ ពីព្រោះថាដំណាក់កាលនៃការស៊ើបសួរនេះ គឺជាដំណាក់កាលមួយដែលបង្ហាញថាជនណាបានប្រព្រឹត្តបទល្មើស ឬមិនបានប្រព្រឹត្តបទល្មើស។ អាស្រ័យហេតុនេះ ភារកិច្ចរបស់ចៅក្រមស៊ើបសួរ ដែលសំខាន់បែបនេះតុលាការមិនអាចអនុវត្តនីតិវិធីផ្សេងៗដោយរំលងពីដំណាក់កាលស៊ើបសួរនេះបានឡើយបើទោះបីជាក្នុងកាលៈទេសៈណាក៏ដោយ ឲ្យតែស្ថិតក្នុងប្រភេទនៃបទល្មើសឧក្រិដ្ឋ។ ប៉ុន្តែយ៉ាងណាក្តីប្រសិនបើមានមូលហេតុមួយចំនួនដែលជាហេតុបណ្តាលឲ្យចៅក្រមស៊ើបសួរមិនអាចបំពេញតួនាទីរបស់ខ្លួនបាន ដូចជាបញ្ហាជម្ងឺ ឬ មានធុរៈចាំបាច់ផ្សេងៗ ការធ្វើដំណើរផ្លូវឆ្ងាយ។ល។ ដូច្នេះដោយសារតែកិច្ចនោះត្រូវធ្វើជាបន្ទាន់ ហើយចៅក្រមស៊ើបសួរមិនអាចបំពេញកិច្ចនោះ ទើបក្រមនីតិវិធីព្រហ្មទណ្ឌសម្រេចអនុញ្ញាតឲ្យមានលក្ខខណ្ឌអាចឱ្យចៅក្រមស៊ើបសួរចាត់អ្នកបំពេញកិច្ចស៊ើបសួរជំនួសខ្លួនបាន។

### ខ. កិច្ចស៊ើបសួរជំនួសដែលបំពេញដោយចៅក្រមផ្សេងទៀត

កាលណាដីកាចាត់ឲ្យស៊ើបសួរជំនួសត្រូវបានចេញឲ្យដោយចៅក្រមណាម្នាក់ ចៅក្រមរូបនោះប្រើប្រាស់អំណាចទាំងអស់របស់ចៅក្រមស៊ើបសួរ[33]។

ការចាត់ឲ្យស៊ើបសួរជំនួសនេះ គឺជានីតិវិធីមួយដែលចៅក្រមស៊ើបសួរអាចប្រគល់សិទ្ធិរបស់ខ្លួននៃសាលាដំបូង ឬសាលាផ្សេងទៀតដើម្បីបំពេញកិច្ចស៊ើបសួរមួយចំនួនដែលមានចង្អុលបង្ហាញក្នុងដីកា។ នៅពេលដែលចៅក្រមស៊ើបសួរចេញដីកាស៊ើបសួរជំនួសឱ្យទៅចៅក្រមណាម្នាក់ ចៅក្រមរូបនោះអាចប្រើប្រាស់អំណាចទាំងអស់របស់ចៅក្រមស៊ើបសួរ ដែលអំណាចទាំងនោះរួមមានដូចជា ការដាក់ជនជាប់ចោទឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យ ធ្វើការសួរចម្លើយជនត្រូវចោទ ធ្វើការស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី ធ្វើការស្តាប់ចម្លើយសាក្សី ធ្វើការឆែកឆេរ ការចាប់យកវត្ថុតាងធ្វើកុសលវិច័យ ធ្វើការស្តាប់ទូរស័ព្ទ ចេញដីកាបង្គាប់ឲ្យចូលខ្លួន ដីកាបង្គាប់ឲ្យនាំខ្លួន ដីកាបង្គាប់ឲ្យចាប់ខ្លួន និង ដីកាបង្គាប់ឲ្យឃុំខ្លួនជាដើម។

---

[32] មាត្រា ១៨២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

[33] មាត្រា ១៧៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

ជាក់ស្តែងការចាត់ឲ្យស៊ើបសួរជំនួស ធ្វើឡើងដើម្បីកាត់បន្ថយការលំបាកផ្សេងៗរបស់ចៅក្រមស៊ើបសួរ ដោយសារស្ថានភាពការងារមានលក្ខណៈមមាញឹក ឬនៅពេលចៅក្រមស៊ើបសួរមានភារកិច្ចចាំបាច់ដោយខានពុំបាន ទើបអនុញ្ញាតឲ្យមានការចូលរួមជួយបំពេញកិច្ចការខ្លះពីសំណាក់ចៅក្រមផ្សេងទៀតដើម្បីចំណេញពេលវេលា និងមិនឲ្យនីតិវិធីយឺតយ៉ាវ។

បន្ទាប់ពីចៅក្រមស៊ើបសួរដែលទទួលភារកិច្ចបានបំពេញកិច្ចចប់សព្វគ្រប់ ចៅក្រមរូបនោះត្រូវធ្វើកំណត់ហេតុ ដើម្បីជាព័ត៌មានក្នុងការបញ្ជូនទៅចៅក្រមស៊ើបសួរ ដែលជាអ្នកចេញដីកាឱ្យស៊ើបសួរជំនួសនោះ។

## គ. កិច្ចស៊ើបសួរជំនួសដែលបំពេញដោយមន្ត្រីនគរបាលយុត្តិធម៌

ចៅក្រមស៊ើបសួរ ក៏អាចប្រើប្រាស់វិធានការបង្គាប់ឱ្យស៊ើបសួរជំនួសនូវកិច្ចមួយចំនួនដល់មន្ត្រីនគរបាលយុត្តិធមិ ដោយចង្អុលបង្ហាញក្នុងដីកាបង្គាប់ឲ្យស៊ើបសួរជំនួស ដោយការអនុវត្តដីកាស៊ើបសួរជំនួសមន្ត្រីនគរបាលយុត្តិធមិ ត្រូវស្ថិតក្នុងអំណាចរបស់ចៅក្រមស៊ើបសួរ ហើយត្រូវរាយការណ៍ជូនតែចៅក្រមរូបនោះតែម្នាក់គត់[34]។ មន្ត្រីនគរបាលយុត្តិធមិអាចបំពេញកិច្ចបានតែក្នុងករណីមានចែងក្នុងដីកាចាត់ឱ្យស៊ើបសួរជំនួសនៅក្នុងរង្វង់សមត្ថកិច្ចដែនដីរបស់ខ្លួន លើកលែងតែចៅក្រមស៊ើបសួរអនុញ្ញាតឱ្យធ្វើប្រតិបត្តិការបន្ទាន់លើវិសាលភាពដែនដីជាតិទាំងមូល ប៉ុន្តែត្រូវមានជំនួយពីមន្ត្រីនគរបាលយុត្តិធមិដែលមានសមត្ថកិច្ចដែនដី[35]។ ចៅក្រមស៊ើបសួរ ត្រូវចាត់ឲ្យមន្ត្រីនគរបាលយុត្តិធមិណាម្នាក់ដើម្បីបំពេញកិច្ចមួយចំនួនជំនួសខ្លួនដូចជា សិទ្ធិអំណាចក្នុងការធ្វើកំណត់ហេតុស្តីពីការស្រាវជ្រាវ និង ពិនិត្យអំណាចក្នុងការឆែកឆេរ ការចាប់យកវត្ថុតាង ការឃាត់ខ្លួននៅក្នុងក្របខណ្ឌនៃដីកាចាត់ឲ្យស៊ើបសួរជំនួស ការស្តាប់ទូរស័ព្ទ និងការធ្វើកំណត់ហេតុផ្សេងៗដែលសាងដោយមន្ត្រីនគរបាលយុត្តិធមិ ក្នុងក្របខណ្ឌនៃការអនុវត្តដីកាចាត់ឲ្យស៊ើបសួរជំនួសចេញពីចៅក្រមស៊ើបសួរ។ លើសពីនេះមន្ត្រីនគរបាលយុត្តិធម៌អាចកោះហៅ និងស្តាប់ចម្លើយសាក្សីប៉ុន្តែមុននិងឆ្លើយចំពោះសំណួរ សាក្សីម្នាក់ៗត្រូវស្បថតាមសាសនា ឬជំនឿរបស់ខ្លួនថា និយាយតែការពិត ។ ប៉ុន្តែសាក្សីដែលមានរៀបរាប់នៅមាត្រា ១៥៦ ត្រូវបានលើកលែងមិន បាច់ធ្វើសម្បថ។ ដើម្បីគោរពសិទ្ធិការពារខ្លួន មន្ត្រីនគរបាលយុត្តិធម៌មិនអាចស្តាប់ចម្លើយក្នុងឋានៈជាសាក្សីនូវបុគ្គលណាមួយដែលមានតម្រុយនៃពិរុទ្ធភាពលើបុគ្គលនោះទេ ។ កាលណាស្តាប់ចម្លើយសាក្សីណាម្នាក់បានធ្វើឲ្យលេចតម្រុយនៃពិរុទ្ធភាពសាក្សីនោះ មន្ត្រីនគរបាលយុត្តិធមិត្រូវបញ្ឈប់ការស្តាប់ ហើយត្រូវរាយការណ៍ជូនទៅកាន់ចៅក្រមស៊ើបសួរ ។ មន្ត្រីនគរបាលយុត្តិធម៌ អាចហៅរកអ្នកបកប្រែដែល

[34] មាត្រា ១៧៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

[35] មាត្រា ១៧៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

បានស្បថស្របតាមសាសនា ឬជំនឿរបស់ខ្លួនថា ខ្លួននិងជួយបកប្រែជូនតុលាការឲ្យបានត្រឹមត្រូវ ក្នុងករណីសាក្សីមិនចេះភាសាខ្មែរ។

បុគ្គលដែលបានកោះហៅក្នុងឋានៈជាសាក្សី ត្រូវតែចូលមកបង្ហាញខ្លួន។ ក្នុងករណី រឹងទទឹង មន្ត្រីនគរបាលយុត្តិធម៌រាយការណ៍ជូនចៅក្រមស៊ើបសួរ ដើម្បីចេញបញ្ជាឲ្យចូលខ្លួន ដោយក្នុងបញ្ជានោះមានចុះអត្តសញ្ញាណនៃសាក្សី។ បញ្ជានេះត្រូវមានចុះកាលបរិច្ឆេទ និងហត្ថលេខាដោយចៅក្រមស៊ើបសួរ និងមានបោះត្រាផង។ បញ្ជាឲ្យចូលបង្ហាញខ្លួន អនុញ្ញាតឲ្យមន្ត្រី នគរបាលយុត្តិធម៌ប្រើប្រាស់កម្លាំងជាសាធារណៈដើម្បីបង្ខំឲ្យសាក្សីចូលបង្ហាញខ្លួនចំពោះមុខខ្លួន[36]។

ការសាកសួរចម្លើយរបស់ជនត្រូវចោទ ឬ ដើមបណ្តឹងរដ្ឋប្បវេណីមន្ត្រីនគរបាលយុត្តិធម៌មិនអាចធ្វើកិច្ចនេះបានឡើយ[37]។

**សំគាល់៖** ក្នុងក្របខណ្ឌនេះ មន្ត្រីនគរបាលយុត្តិធម៌ពុំអាចសួរចម្លើយជនត្រូវចោទ ឬ ស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណីបានទេ។ ប៉ុន្តែមន្ត្រីនគរបាលយុត្តិធម៌ អាចធ្វើការឆែកឆេរ និងចាប់យកវត្ថុតាងនៅក្នុងលក្ខខណ្ឌដែលមានការអនុញ្ញាតពីចៅក្រមស៊ើបសួរ។ ដើម្បីឆ្លើយតបនឹងតម្រូវការចាំបាច់ មន្ត្រីនគរបាលយុត្តិធម៌អាចធ្វើការហាមឃាត់ជនត្រូវចោទ តែត្រូវមានការអនុញ្ញាតពីចៅក្រមស៊ើបសួរ។

[36] មាត្រា ១៧៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ
[37] មាត្រា ១៨០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

# ជំពូកទី២
# វិធានការនិរន្តរាយ

# ជំពូកទី២
# វិធានការនិរន្តរាយ

និរន្តរាយ មានន័យថាការមិនមានអន្តរាយដំណើរដែលគ្មានគ្រោះថ្នាក់[38]។ វិធានការនេះ សំដៅដល់ការចេញដីកាចាប់ខ្លួន ការចោទប្រកាន់ ការឃុំខ្លួន ឬ ការដាក់ឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការដោយចៅក្រមស៊ើបសួរ។

ដើម្បីធានាដល់កិច្ចស៊ើបសួរឲ្យប្រព្រឹត្តទៅដោយមានប្រសិទ្ធិភាព ក្រមនីតិវិធីព្រហ្មទណ្ឌ បានប្រគល់អំណាចក្នុងការចាប់បង្ខំតាមរយៈវិធានការនិរន្តរាយទៅដល់ចៅក្រមស៊ើបសួរ។ យ៉ាងណាវិញដោយផ្អែកលើមូលដ្ឋានគ្រឹះនៃការចាត់ការតាមរយៈវិធានការនិរន្តរាយ ចៅក្រមស៊ើបសួរ មានអំណាចប្រើប្រាស់នូវដីកាជាច្រើន ដើម្បីស្តែងឡើងពីសកម្មភាពរបស់ខ្លួន។ នេះជាគោលការណ៍នៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌ ដើម្បីជាការងាយស្រួលស្វែងរកភស្តុតាងពិតប្រាកដ សម្រាប់ដាក់បន្ទុកដោះបន្ទុកទៅដល់ចៅក្រមស៊ើបសួរក្នុងរឿងក្តីព្រហ្មទណ្ឌ។

## ផ្នែកទី១ ដីកា

ដីកា ជាបញ្ជាជាលាយល័ក្ខអក្សរចេញពីអាជ្ញាធរមានសមត្ថកិច្ចដែលបង្គាប់ឱ្យចាត់ការនូវអំពើណាមួយ។ មួយវិញទៀតបញ្ជាដែលបង្គាប់ឱ្យចាប់ខ្លួនជនណាម្នាក់ ឬច្រើននាក់ជាការចេញដីកាដោយអង្គការតុលាការ ឬមន្ត្រីរាជការណាមួយ។ ជាទូទៅគេអាចទាញយកតាមអត្ថន័យច្បាប់បានន័យថា ដីកាជាសេចក្តីសម្រេចរបស់ចៅក្រម ដើម្បីអនុញ្ញាតធ្វើការបង្គាប់ឱ្យធ្វើកិច្ចការអ្វីមួយតាមបញ្ជារបស់ចៅក្រមក្នុងរឿងអ្វីមួយ ឬជាសេចក្តីបង្គាប់ជាលាយលក្ខណ៍អក្សរដែលចេញដោយចៅក្រមម្នាក់។

ចំពោះវិធានការនិរន្តរាយនេះ ចៅក្រមស៊ើបសួរ អាចចេញដីកាបង្គាប់ឱ្យចូលខ្លួន ដីកាបង្គាប់ឱ្យនាំខ្លួន ដីកាបង្គាប់ឱ្យចាប់ខ្លួន និង ដីកាបង្គាប់ឱ្យឃុំខ្លួន[39]។

### កថាខណ្ឌទី១ ដីកាបង្គាប់ឲ្យចូលខ្លួន

#### ក. អត្ថន័យនៃដីកាបង្គាប់ឲ្យចូលខ្លួន

ដីកាបង្គាប់ឲ្យចូលខ្លួន គឺជាបញ្ជាដល់បុគ្គលណាម្នាក់ ឬ ច្រើននាក់ ឱ្យចូលទៅបង្ហាញខ្លួននៅចំពោះមុខចៅក្រមស៊ើបសួរ[40]។ ជាទូទៅដីកាបង្គាប់ឱ្យចូលខ្លួន អាចចេញចំពោះជនត្រូវចោទ ឬចំពោះបុគ្គលដែលមានតម្រុយពិរុទ្ធភាព ពីព្រោះក្នុងការស្រាវជ្រាវរបស់ចៅក្រមស៊ើបសួរ ជាពិសេស

[38] យោងតាមវចនានុក្រមសម្តេច ជួនណាត
[39] មាត្រា ១៨៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ
[40] មាត្រា ១៨៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

ការស្តាប់ចម្លើយជនត្រូវចោទ ឬ ជនដែលមានតម្រុយពិរុទ្ធភាព គឺជាកិច្ចការមួយដែលសំខាន់ដើម្បីទទួលបាននូវចម្លើយដោយតាមរយៈការសួរចម្លើយជនត្រូវចោទ ដើម្បីបញ្ជាក់ឱ្យកាន់តែច្បាស់នូវការពិតអំពីអង្គហេតុ ក៏ដូចជាការស្វែងរកជនពាក់ព័ន្ធដែលជាភស្តុតាងដែលសំខាន់។

### ខ. លក្ខខណ្ឌនៃការចេញដីកាបង្គាប់ឲ្យចូលខ្លួន

កម្មវត្ថុនៃការចេញដីកាបង្គាប់ឲ្យចូលខ្លួន គឺដើម្បីបញ្ជាក់ឲ្យបុគ្គលដែលត្រូវចោទ ចូលមកបង្ហាញខ្លួននៅចំពោះមុខចៅក្រមស៊ើបសួរ ដើម្បីឲ្យចៅក្រមស៊ើបសួរធ្វើការសាកសួរព័ត៌មាន សួររកចម្លើយ ឬ ស្តាប់ចម្លើយអំពីរឿងហេតុពាក់ព័ន្ធនឹងបទចោទប្រកាន់របស់ព្រះរាជអាជ្ញា។

នៅក្នុងចំណាត់ការវិធានការនិរន្តរាយ ដើម្បីឱ្យការស៊ើបសួរស្វែងរកការពិតនៃរឿងមួយដែលប្រព្រឹត្តទៅបានដោយរលូនរបស់ចៅក្រមស៊ើបសួរ ត្រូវតែមានការសហការពីព្រះរាជអាជ្ញា។ ប៉ុន្តែការចេញដីកាបង្គាប់ឲ្យចូលខ្លួន មិនអាចអនុវត្តបានដោយភ្លាមៗឡើយ ទោះជាមានសេចក្តីសន្និដ្ឋានពីព្រះរាជអាជ្ញាក៏ដោយ។ មូលហេតុមកពី នៅក្នុងសេចក្តីសន្និដ្ឋានបង្គាប់ឲ្យចូលខ្លួន បានធ្វើសេចក្តីសន្និដ្ឋានចោទប្រកាន់ទៅលើបុគ្គលដែលមិនទាន់ស្គាល់អត្តសញ្ញាណច្បាស់លាស់។ ហេតុដូច្នេះការចេញដីកាបង្គាប់ឱ្យចូលខ្លួនគ្មានប្រសិទ្ធិភាព។ ដោយឡែក ជាចំណាត់ការដើម្បីឆ្លើយតបទៅនឹងករណីនេះ ជាដំបូង ចៅក្រមស៊ើបសួរធ្វើការស៊ើបសួរត្រូវធ្វើការស្រាវជ្រាវរកសវតាជាតិរបស់បុគ្គលនោះជាមុនសិន តាមរយៈដីកាចាត់ឱ្យស៊ើបសួរជំនួស ចៅក្រមស៊ើបសួរអាចចេញដីកាបង្គាប់ឲ្យចូលខ្លួន។ ករណីដែលមានការស្នើសុំដោយមន្ត្រីនគរបាលយុត្តិធម៌។

ចំពោះដីកាបង្គាប់ឱ្យចូលខ្លួន ត្រូវចុះនិទ្ទេសដូចជា ៖

- អត្តសញ្ញាណនៃបុគ្គលដែលពាក់ព័ន្ធ
- បទល្មើសដែលចោទប្រកាន់ និងអត្ថបទច្បាប់ដែលកំណត់ និងបង្ក្រាបបទល្មើសនេះ
- ថ្ងៃ ខែ ឆ្នាំ ម៉ោង និងទីកន្លែងដែលត្រូវចូលខ្លួនបង្ហាញខ្លួននៅមុខចៅក្រមស៊ើបសួរ
- ឈ្មោះ និងឋានៈរបស់ចៅក្រមដែលចេញដីកា ។

ដីកាបង្គាប់ឲ្យចូលខ្លួនត្រូវមានចុះកាលបរិច្ឆេទ និងចុះហត្ថលេខាដោយចៅក្រមស៊ើបសួរ និងមានបោះត្រាផង[41]។ មួយវិញទៀត ដីកាបង្គាប់ឱ្យចូលខ្លួន មិនមានវិធានការចាប់បង្ខំដល់ជនដែលចៅក្រមបានកំណត់ឈ្មោះនៅក្នុងដីកានោះទេ មានន័យថាជនដែលទទួលបានដំណឹងនៃដីកានេះរួចហើយ បុគ្គលនោះអាចចូល ឬមិនចូលបង្ហាញខ្លួននៅចំពោះមុខចៅក្រមស៊ើបសួរដោយសេរី។ ប៉ុន្តែទោះបីជាបែបណាក៏ដោយ ដីកាបង្គាប់ឲ្យចូលខ្លួន មិនមានអនុភាពដោយផ្ទាល់ក្នុងការចាប់បង្ខំបុគ្គលនោះឱ្យត្រូវតែចូលបង្ហាញខ្លួនចំពោះមុខចៅក្រមស៊ើបសួរក៏ពិតមែន តែវាមានតម្លៃជាការជម្រុញ

[41] មាត្រា ១៨៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

ទៅលើយន្តការនៃនីតិវិធីបន្ត ក្នុងករណីដែលបុគ្គលនោះបដិសេធមិនព្រមចូលខ្លួនតាមដីកាបង្គាប់ឱ្យចូលខ្លួនដោយគ្មានមូលហេតុត្រឹមត្រូវ។ ចំណាត់ការបន្ត ចៅក្រមស៊ើបសួរអាចចេញដីកាបង្គាប់ឲ្យនាំខ្លួន។

**គ. ការអនុវត្តដីកាបង្គាប់ឲ្យចូលខ្លួន**

ការអនុវត្តដីកាបង្គាប់ឱ្យចូលខ្លួននេះ ត្រូវបានចេញដោយចៅក្រមស៊ើបសួរជូនទៅកាន់មន្ត្រីនគរបាលយុត្តិធម៌ ឬ មន្ត្រីអាជ្ញាសាលា ដោយក្រឡាបញ្ជីឱ្យដីកាទៅបុគ្គលទាំងនេះយកដីកាបង្គាប់ឲ្យចូលខ្លួនទៅដល់បុគ្គលដែលពាក់ព័ន្ធ គឺត្រូវបញ្ជាក់ប្រាប់ទៅបុគ្គលនោះអំពីកម្មវត្ថុនៃដីកានេះឱ្យទទួលយកចុងដីកា ហើយត្រូវចុះហត្ថលេខា ឬ ផ្តិតម្រាមដៃនៅលើដើមដីកានោះផង។ ប្រសិនបើបុគ្គលនោះមិនព្រមយកដីកានេះ ត្រូវបញ្ជាក់ពីមូលហេតុនៃការមិនព្រមយកដីកានោះ។ បន្ទាប់មកទៀតមន្ត្រីមានសមត្ថកិច្ចត្រូវបញ្ជូនដីកានោះត្រលប់មកជូណចៅក្រមស៊ើបសួរ អោយបានរហ័សតាមដែលខ្លួនអាចធ្វើបាន។

**កថាខណ្ឌទី២ ដីកាបង្គាប់ឲ្យនាំខ្លួន**

**ក. អត្ថន័យនៃដីកាបង្គាប់ឲ្យនាំខ្លួន**

ដីកាបង្គាប់ឱ្យនាំខ្លួន គឺជាបញ្ជាដល់កងកម្លាំងសាធារណៈឱ្យចាប់ និង នាំខ្លួនបុគ្គលណាម្នាក់ទៅចំពោះមុខចៅក្រមស៊ើបសួរ។ ហើយចៅក្រមស៊ើបសួរមានអំណាចចេញនូវដីកាបង្គាប់ឱ្យនាំខ្លួន[42]។ មានន័យថាការចេញដីកានេះ គឺជាករណីចាំបាច់ដើម្បីបង្ខំជនត្រូវចោទ ឬ ជនដែលមានតម្រុយពិរុទ្ធភាព ឲ្យចូលបង្ហាញខ្លួននៅចំពោះមុខចៅក្រមស៊ើបសួរតាមរយៈការប្រើប្រាស់កម្លាំងសាធារណៈឲ្យចាប់ និង នាំយកបុគ្គលនោះមកបង្ហាញខ្លួនចំពោះមុខចៅក្រមស៊ើបសួរ។

**ខ. លក្ខខណ្ឌនៃការចេញដីកាបង្គាប់ឲ្យនាំខ្លួន**

ប្រសិនបើជនត្រូវចោទមិនបានចូលខ្លួនតាមដីកាបង្គាប់ឲ្យចូលខ្លួនទេ នោះចៅក្រមស៊ើបសួរអាចចេញដីកាបង្គាប់ឱ្យនាំខ្លួនជនត្រូវចោទបាន ករណីដែលជនត្រូវចោទមិនបានរត់គេចទៅទីណានោះ។ ចំណុចនេះមានន័យថាប្រសិនបើជនត្រូវចោទកំពុងរស់នៅជាធម្មតានៅមូលដ្ឋានដោយគ្មានការរត់គេចខ្លួន គឺចៅក្រមស៊ើបសួរអាចចេញដីកាបង្គាប់ឲ្យនាំខ្លួនជនត្រូវចោទតែម្តង។

ប្រសិនបើករណី ចៅក្រមស៊ើបសួរយល់ឃើញថា ការចេញដីកាបង្គាប់ឱ្យចូលខ្លួនទៅកាន់ជនត្រូវចោទពីបទឧក្រិដ្ឋ ឬ បទមជ្ឈឹម ធ្វើឱ្យជនត្រូវចោទមានបំណងរត់គេចខ្លួន នោះចៅក្រមស៊ើបសួរមានសិទ្ធិចេញដីកាបង្គាប់ឱ្យនាំខ្លួនតែម្តង។

[42] មាត្រា ១៨៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

ម្យ៉ាងវិញទៀត ក្នុងករណីចៅក្រមបានចេញដីកាបង្គាប់ឲ្យចូលខ្លួន ប៉ុន្តែជនត្រូវចោទនៅតែរឹងទទឹងមិនព្រមចូលបង្ហាញខ្លួនចំពោះមុខតុលាការជាដាច់ខាត ចៅក្រមស៊ើបសួរអាចចេញដីកាបង្គាប់ឱ្យនាំខ្លួនដែលមានអនុភាពដើម្បីធ្វើការនាំខ្លួនជននោះមកស៊ើបសួរដើម្បីស្វែងរកការពិត។

ដើម្បីឱ្យដីកាបង្គាប់ឱ្យនាំខ្លួន មានអនុភាពត្រូវចុះនិទ្ទេសដូចតទៅ ៖

- លេខ ថ្ងៃ ខែ ឆ្នាំ សំណុំរឿង
- អត្តសញ្ញាណនៃបុគ្គលដែលពាក់ព័ន្ធ
- បទល្មើសដែលបានចោទប្រកាន់ និងអត្ថបទច្បាប់ដែលកំណត់ និងបង្ក្រាបបទល្មើស
- ឈ្មោះ និង ឋានៈរបស់ចៅក្រមដែលចេញដីកា
- ដីកានេះត្រូវចុះលេខរៀងនៃការចេញដីកា ស្របតាមលំដាប់លេខរៀងនៃសៀវភៅចុះលេខដីកាបង្គាប់ឱ្យនាំខ្លួន។

ដីកាបង្គាប់ឱ្យនាំខ្លួន ត្រូវតែចុះកាលបរិច្ឆេទ និងនិទ្ទេស ដូចដែលបានចង្អុលបង្ហាញខាងលើទើបដីកានេះមានប្រសិទ្ធិភាព។

ដីកាបង្គាប់ឱ្យនាំខ្លួនត្រូវចុះកាលបរិច្ឆេទ និង ចុះហត្ថលេខាដោយចៅក្រមស៊ើបសួរ និងមានបោះត្រារបស់ចៅក្រមស៊ើបសួរផង[43]។

### គ. ការអនុវត្តដីកាបង្គាប់ឲ្យនាំខ្លួន

ដីកាបង្គាប់ឱ្យនាំខ្លួន ត្រូវប្រគល់ដល់មន្ត្រីនគរបាលយុត្តិធម៌ដែលជាអ្នកទទួលបន្ទុកក្នុងការអនុវត្ត។ ប្រសិនបើចាំបាច់ ដីកាបង្គាប់ឱ្យនាំខ្លួនត្រូវផ្សព្វផ្សាយដល់អង្គភាពនគរបាល ឬកងរាជអាវុធហត្ថតាមរយៈគ្រប់មធ្យោបាយដូចជា ព័ត៌មានកាសែត វិទ្យុ ទូរទស្សន៍ ឬប្រព័ន្ធអ៊ីនធើណែតជាអាទ៍។ មានន័យថាដីកាបង្គាប់ឱ្យនាំខ្លួន អាចជាកម្មវត្ថុក្នុងការធ្វើការផ្សព្វផ្សាយលើវិសាលភាពដែនដីនៃព្រះរាជាណាចក្រកម្ពុជាទាំងមូល។ ការផ្សព្វផ្សាយបែបនេះ ចំពោះភាពបន្ទាន់នៃការអនុវត្តដីកាដើម្បីបង្កាជនត្រូវចោទកុំឱ្យព្យាយាមរត់គេចខ្លួនចេញពីដែនដីប្រទេសកម្ពុជា។ ដើមដីកានេះ ត្រូវប្រគល់ជូនជាបន្ទាន់ដល់មន្ត្រីនគរបាលយុត្តិធម៌ដែលទទួលបន្ទុកតាមរយៈក្រឡាបញ្ជី។ ចំពោះដីកា ត្រូវមានបោះត្រាក្រហមដែលមិនមែនជាសន្លឹកថតចម្លង។ មិនថាស្ថិតក្នុងកាលៈទេសៈបែបណាទេ មន្ត្រីនគរបាលយុត្តិធម៌ ត្រូវតែគោរពសិទ្ធិលំនៅឋាន បើទោះជាស្ថិតក្នុងលក្ខខណ្ឌបន្ទាន់ក្នុងការអនុវត្តដីកាយ៉ាងណាក៏ដោយ មានន័យថាមន្ត្រីនគរបាលយុត្តិធម៌ មិនអាចចូលទៅនាំខ្លួនជនត្រូវចោទមុនម៉ោង ៦ ព្រឹក និង ក្រោយម៉ោង ១៨ ល្ងាចបានជាដាច់ខាត។ ម្យ៉ាងវិញទៀត ប្រសិនបើស្ថិតនៅក្នុងបេសកកម្មនៃការអនុវត្តដីកាបង្គាប់ឱ្យនាំខ្លួន មន្ត្រីនគរបាលយុត្តិធម៌ជួបនូវការលំបាកផ្សេងៗ

[43] មាត្រា ១៩១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

មន្ត្រីនគរបាលយុត្តិធម៌ត្រូវជូនដំណឹងស្ដីអំពីការលំបាករបស់ខ្លួនទៅកាន់ចៅក្រមស៊ើបសួរ[44]។ ក្រោយពីធ្វើការនាំខ្លួនជនដែលជាប់ពាក់ព័ន្ធបានហើយ មន្ត្រីនគរបាលយុត្តិធម៌ ត្រូវតែនាំជននោះទៅបង្ហាញខ្លួននៅចំពោះមុខចៅក្រមស៊ើបសួរ ដើម្បីឱ្យចៅក្រមស៊ើបសួរធ្វើការសួរចម្លើយ ឬ ស្ដាប់ចម្លើយដែលពាក់ព័ន្ធ។ ប្រសិនបើមានកាលៈទេសៈណាមួយដែលជាហេតុនាំឲ្យមន្ត្រីនគរបាលយុត្តិធម៌ មិនអាចនាំខ្លួនបុគ្គលដែលជាប់ពាក់ព័ន្ធទៅបង្ហាញខ្លួននៅចំពោះមុខចៅក្រមស៊ើបសួរក្រោយពេលចាប់ខ្លួនបានទេ បុគ្គលនោះត្រូវនាំខ្លួនបង្ហាញខ្លួនយ៉ាងយូរបំផុតថ្ងៃបន្ទាប់ដល់ចៅក្រមស៊ើបសួរ ឬ អ្នកជំនួស។ ប្រសិនបើការបង្ហាញខ្លួននៅថ្ងៃបន្ទាប់ទេ បុគ្គលពាក់ព័ន្ធត្រូវបានដោះលែងឲ្យមានសេរីភាពវិញ[45]។ នេះមានន័យថាថិរវេលានៃការឃាត់ខ្លួន (ឃុំខ្លួន) ជនណាម្នាក់មិនអាចលើសពីរយៈពេល ៤៨ ម៉ោងនោះទេ។ កាលណាបុគ្គលជាប់ពាក់ព័ន្ធ ត្រូវបាននាំខ្លួនដល់ចៅក្រមស៊ើបសួររួចមក ដោយស្ថិតនៅក្នុងជម្រើសរបស់ខ្លួន ចៅក្រមស៊ើបសួរអាចធ្វើការឃុំខ្លួន ឬ មិនឃុំខ្លួន ( ដាក់ឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ) ទៅលើបុគ្គលនោះ។ យោងតាមការអនុវត្តជាក់ស្ដែង ចៅក្រមស៊ើបសួរតែងសម្រេចធ្វើការឃុំខ្លួនក្នុងករណីបទល្មើសដែលចោទប្រកាន់ទៅលើបុគ្គលនោះជាប្រភេទបទល្មើសធ្ងន់ធ្ងរ (បទឧក្រិដ្ឋ) ឬ អាស្រ័យលើបុគ្គលិកលក្ខណៈនៃបុគ្គលនោះផ្ទាល់តែម្តង។

### កថាខណ្ឌទី៣ ដីកាបង្គាប់ឲ្យចាប់ខ្លួន

#### ក. អត្ថន័យនៃដីកាបង្គាប់ឲ្យចាប់ខ្លួន

ដីកាបង្គាប់ឲ្យចាប់ខ្លួន ជាបញ្ជារបស់ចៅក្រមស៊ើបសួរ បង្គាប់ឲ្យកម្លាំងសាធារណៈទាំងអស់ស្រាវជ្រាវរកចាប់ខ្លួនជនត្រូវចោទ ឬ បុគ្គលដែលជាប់ពាក់ព័ន្ធ មានពិរុទ្ធភាពមកចំពោះមុខចៅក្រមស៊ើបសួរដើម្បីនាំខ្លួនជននោះទៅពន្ធនាគា ឬ មណ្ឌលឃុំខ្លួន និង បញ្ជាដល់ប្រធានពន្ធនាគារ ឬ មណ្ឌលឃុំខ្លួនបុគ្គលនោះ ចំពោះបុគ្គលដែលបានគេចខ្លួនដោយមិនដឹងស្ថិតនៅទីណា។ ទោះបី ជាដីកាបង្គាប់ឲ្យចាប់ខ្លួន ត្រូវបានចេញដោយចៅក្រមស៊ើបសួរក៏ពិតមែន ប៉ុន្តែដើម្បីធានាឱ្យមានប្រសិទ្ធិភាព ក្រមនីតិវិធីព្រហ្មទណ្ឌតម្រូវឲ្យ មុននឹងចេញដីកាបង្គាប់ឲ្យចាប់ខ្លួន ចៅក្រមស៊ើបសួរត្រូវតែទទួលយោបល់ពីព្រះរាជអាជ្ញាក្នុងដីកានេះជាមុនសិន ដើម្បីសម្រេចនូវមូលហេតុក្រោយពីទទួលយោបល់ពីព្រះរាជអាជ្ញា។ យ៉ាងណាមិញ ដីកាបង្គាប់ឲ្យចាប់ខ្លួន គឺធ្វើឡើងដោយមានការកំណត់ពីនិទ្ទេស និងមានកាលបរិច្ឆេទ ហើយចុះហត្ថលេខាដោយចៅក្រមស៊ើបសួរដោយមានបោះត្រាផងគ្រាន់ជាបញ្ជារបស់ចៅក្រមស៊ើបសួរ បញ្ជាឲ្យកងកម្លាំងសាធារណៈស្វែងរកជនត្រូវចោទ ឬជនដែល

[44] មាត្រា ១៩២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

[45] មាត្រា ១៩៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

ជាប់ពាក់ព័ន្ធ ឬជនដែលមានពិរុទ្ធភាពមកចំពោះមុខចៅក្រមស៊ើបសួរដើម្បីធ្វើការសាកសួរយកចម្លើយ ឬ ស្ដាប់ចម្លើយពាក់ព័ន្ធនឹងបទចោទប្រកាន់របស់ព្រះរាជអាជ្ញា។

**ខ. លក្ខខណ្ឌនៃការចេញដីកាបង្គាប់ឲ្យចាប់ខ្លួន**

ដីកាបង្គាប់ឱ្យចាប់ខ្លួន អាចចេញទៅលើជនត្រូវចោទ ឬបុគ្គលដែលមានតម្រុយពិរុទ្ធភាព។ ចៅក្រមស៊ើបសួរអាចធ្វើការចេញដីកានេះបានលុះត្រាតែ ៖

- បទល្មើសដែលចោទប្រកាន់ គឺជាប្រភេទបទឧក្រិដ្ឋ ឬបទមជ្ឈឹម ដែលត្រូវបានផ្ដន្ទាទោសដាក់ពន្ធនាគារ[46]។
- បុគ្គលដែលជាប់ពាក់ព័ន្ធ បានរត់គេចខ្លួនមិនដឹងជាស្ថិតនៅទីកន្លែងណា ឬស្ថិតនៅក្រៅដែនដីនៃព្រះរាជាណាចក្រកម្ពុជា។

ជាការពិតណាស់ ទោះបីជាដីកាបានបំពេញតាមលក្ខណ្ឌខាងលើក៏ពិតមែន ប៉ុន្តែដីកានេះមិនអាចធ្វើការចេញភ្លាម ដោយចៅក្រមស៊ើបសួរមិនបានជូនដំណឹង ឬ សុំយោបល់ពីព្រះរាជអាជ្ញាទេនោះ មានន័យថាចៅក្រមស៊ើបសួរត្រូវចេញដីកានេះ ដោយមានថៃងពីមូលហេតុក្រោយពីទទួលបានយោបល់ពីព្រះរាជអាជ្ញា។ ហើយហេតុផលនៃការសុំយោបល់ពីព្រះរាជអាជ្ញា ពីព្រោះដោយយោងលើហេតុផលក្នុងនាមជាព្រះរាជអាជ្ញា គឺជាម្ចាស់នៃបណ្ដឹងអាជ្ញា និងជាអ្នកទទួលបន្ទុកអនុវត្ត និងផ្សព្វផ្សាយដីកាបង្គាប់ឲ្យចាប់ខ្លួនផ្ទាល់តែម្តង។ ការជូនដំណឹងដល់ព្រះរាជអាជ្ញាអំពីការស្នើសុំចាប់ខ្លួនរបស់ចៅក្រមស៊ើបសួរ ត្រូវធ្វើឡើងតាមរយៈ **ដីកាបញ្ជូនឱ្យឆ្លើយ**។ ចំពោះយោបល់នៃការឆ្លើយតបលើការចាប់ខ្លួនរបស់ព្រះរាជអាជ្ញា មិនអាចជាកាតព្វកិច្ចដែលចៅក្រមស៊ើបសួរត្រូវអនុវត្តតាមនោះទេ មានន័យថាចៅក្រមស៊ើបសួរមានសិទ្ធិពេញលេញក្នុងការចេញដីកាបង្គាប់ឲ្យចាប់ខ្លួនទៅលើជនត្រូវចោទបានដោយមានមូលហេតុ សំអាងហេតុ និង សំអាងច្បាប់ត្រឹមត្រូវ។

សរុបមក ដីកាបង្គាប់ឲ្យចាប់ខ្លួនជាវិធានការបង្ខំដោយចៅក្រមស៊ើបសួរចេញដីកានេះ ដើម្បីឲ្យមន្ត្រីអនុវត្តច្បាប់ចាប់ខ្លួនជនត្រូវចោទ ដើម្បីយកមកបង្ហាញខ្លួននៅចំពោះមុខចៅក្រមស៊ើបសួរ។ ការចេញដីកានេះដោយផ្អែកលើស្ថានភាពមួយចំនួន គឺករណីដែលបទល្មើសត្រូវចោទប្រកាន់ពីបទឧក្រិដ្ឋ ឬបទមជ្ឈិម ដែលជាបទល្មើសត្រូវផ្ដន្ទាទោសដាក់ពន្ធធនាគារ និងករណីដែលជនត្រូវចោទ ឬជនជាប់ពាក់ព័ន្ធបានរត់គេចមិនដឹងស្ថិតនៅទីកន្លែងណា។

ចំពោះដីកាបង្គាប់ឱ្យចាប់ខ្លួន ចៅក្រមស៊ើបសួរត្រូវចេញដីកាដោយកំណត់ពីនិទ្ទេសឲ្យបានត្រឹមត្រូវដើម្បីប្រាស់ចាកពីមោឃភាពនៃដីកា។ ហើយនិទ្ទេសទាំងនោះរួមមានដូចខាងក្រោម ៖

- កំណត់អត្តសញ្ញាណនៃបុគ្គលដែលពាក់ព័ន្ធ

[46] មាត្រា ១៩៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

- កំណត់បទល្មើសដែលចោទប្រកាន់ និងអត្ថបទច្បាប់ដែលកំណត់បង្ក្រាបបទល្មើស
- កំណត់ឈ្មោះ ឋានៈរបស់ចៅក្រមស៊ើបសួរដែលបានចេញដីកា។

ដីកាបង្គាប់ឲ្យចាប់ខ្លួន ត្រូវមានចុះពីកាលបរិច្ឆេទ និង ចុះហត្ថលេខាដោយចៅក្រមស៊ើបសួរ និង ត្រូវបោះត្រាផង[47]។

**គ. ការអនុវត្តដីកាបង្គាប់ឲ្យចាប់ខ្លួន**

ការអនុវត្តដីកាបង្គាប់ឲ្យចាប់ខ្លួនត្រូវប្រគល់ឱ្យមន្ត្រីនគរបាលយុត្តិធម៌[48]។ ហេតុដូចនេះដើមដីកា ត្រូវប្រគល់ក្នុងរយៈពេលយ៉ាងខ្លីបំផុតទៅឲ្យមន្ត្រីនគរបាលយុត្តិធម៌ដែលទទួលបន្ទុកអនុវត្តដីកានេះ។ ក្នុងករណីបន្ទាន់ ដីកាបង្គាប់ឱ្យចាប់ខ្លួនត្រូវផ្សព្វផ្សាយជាសាធារណៈតាមរយៈវិធីសាស្ត្រជាច្រើនរួមមានដូចជា តាមរយៈកាសែត ទូរទស្សន៍ វិទ្យុ ឬ ប្រព័ន្ធអ៊ីនធើណេត ជាអាទ៍។ ដីកាបង្គាប់ឱ្យចាប់ខ្លួន មិនត្រឹមតែអាចផ្សព្វផ្សាយជាសាធារណៈក្នុងដែនដីព្រះរាជាណាចក្រកម្ពុជាប៉ុណ្ណោះទេ។ នៅក្នុងករណីចាំបាច់ ដីកាបង្គាប់ឱ្យចាប់ខ្លួន អាចផ្សព្វផ្សាយជាអន្តរជាតិបានតាមរយៈក្រសួងយុត្តិធម៌ដោយប្រើយន្តការនានាដែលមានប្រសិទ្ធិភាព[49]។ នេះបញ្ជាក់បានថា ការអនុវត្តដីកាបង្គាប់ឱ្យចាប់ខ្លួនអាចធ្វើឡើងលើដែនវិសាលភាពជាអន្តរជាតិបាន។ ដោយការអនុវត្តដីកានេះ គឺតម្រូវឱ្យមន្ត្រីនគរបាលយុត្តិធម៌នៃព្រះរាជាណាចក្រកម្ពុជា ចូលរួមសហការជាមួយប៉ូលីសអន្តរជាតិដែលមានសមត្ថកិច្ចដើម្បីស្រាវជ្រាវ ចាប់ខ្លួនជនត្រូវចោទ ហើយមន្ត្រីនគរបាលយុត្តិធម៌ត្រូវតែនាំខ្លួនជននោះមកកាន់ចំពោះមុខចៅក្រមស៊ើបសួរដើម្បីធ្វើការសាកសួរចម្លើយរកការពិត។

ក្រោយពីមន្ត្រីនគរបាលយុត្តិធម៌ទទួលបានសិទ្ធិចាប់ខ្លួនជនត្រូវចោទ ឬ ជនដែលជាប់ពាក់ព័ន្ធតាមរយៈដីកាបង្គាប់ឱ្យចាប់ខ្លួនហើយ មន្ត្រីនគរបាលយុត្តិធម៌អាចចូលចាប់ខ្លួនជនដែលមានអត្តសញ្ញាណដូចដែលដីកាបានកំណត់គ្រប់ពេលវេលា។ ប៉ុន្តែការចាប់ខ្លួនមិនត្រូវបំពានសិទ្ធិលំនៅដ្ឋានបានទេ។ មានន័យថា ទោះបីដីកាមានអនុភាពយ៉ាងណាក៏ដោយ តែអភ័យឯកសិទ្ធិនៃលំនៅដ្ឋានត្រូវតែគោរព។ មន្ត្រីនគរបាលយុត្តិធម៌ មិនអាចចូលទៅក្នុងលំនៅដ្ឋានរបស់បុគ្គលដូចដែលបានកំណត់ឈ្មោះក្នុងដីកាមុនម៉ោង ៦ (ប្រាំមួយ) ព្រឹក និង ក្រោយម៉ោង ១៨ (ដប់ប្រាំបី) ល្ងាចបានឡើយ។ មន្ត្រីនគរបាលយុត្តិធម៌ ត្រូវជូនដំណឹងរាល់ការលំបាករបស់ខ្លួនក្នុងពេលបំពេញបេសកកម្មទៅកាន់ចៅក្រមស៊ើបសួរ។

---

[47] មាត្រា ១៩៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

[48] មាត្រា ១៩៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

[49] មាត្រា ២០០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

ដីកាបង្គាប់ឱ្យចាប់ខ្លួន គឺជាលិខិតបញ្ជាឱ្យឃុំខ្លួនស្របច្បាប់របស់អាជ្ញាធរតុលាការ។ ដូចនេះប្រធានពន្ធនាគារ ឬ មណ្ឌលឃុំខ្លួនត្រូវទទួល និង ឃុំខ្លួនជនត្រូវចោទដែលជាកម្មវត្ថុនៃដីកាបង្គាប់ឲ្យចាប់ខ្លួន ដោយតម្រូវឲ្យប្រធានពន្ធនាគារ ឬ មណ្ឌលឃុំខ្លួននោះរក្សាទុកដើមដីកា ឬ ចុងដីកាដែលមានបញ្ជាក់ថាត្រឹមត្រូវតាមច្បាប់ដើម។ កាលណាបុគ្គលដែលត្រូវបានចាប់ខ្លួនដោយអនុវត្តតាមដីកាបង្គាប់ឲ្យចាប់ខ្លួនត្រូវបានឃុំខ្លួននោះ ថិរវេលានៃការឃុំខ្លួនត្រូវតែបានរាប់បញ្ចូលទៅក្នុងថិរវេលានៃការឃុំខ្លួនបណ្ដោះអាសន្នប្រសិនបើមាន។ បុគ្គលដែលពាក់ព័ន្ធ ត្រូវនាំទៅបង្ហាញដល់ចៅក្រមស៊ើបសួរ ឬ អ្នកជំនួសចៅក្រមស៊ើបសួរក្នុងរយៈពេលខ្លីបំផុត ប្រសិនបើស្ថិតក្នុងដំណាក់កាលស៊ើបសួរនៅឡើយ។ ប៉ុន្តែករណីជនត្រូវចោទ ឬ ជនដែលជាប់ពាក់ព័ន្ធមិនត្រូវបាននាំខ្លួនទៅបង្ហាញដល់ចៅក្រមស៊ើបសួរ ឬ អ្នកជំនួសចៅក្រមស៊ើបសួរ នៅថ្ងៃបន្ទាប់ពីការចាប់ខ្លួន ព្រះរាជអាជ្ញានៅទីកន្លែងឃុំខ្លួននោះ ត្រូវទទួលភារកិច្ចស្ដាប់ចម្លើយ ឬ សួរយកចម្លើយពិតប្រាកដពីជនត្រូវចោទ ឬ ជនជាប់ពាក់ព័ន្ធដែលក្នុងដីកាបង្គាប់ឲ្យចាប់ខ្លួនបានកំណត់ឈ្មោះ។ ក្រោយពីធ្វើកិច្ចស៊ើបសួររកចម្លើយដើម្បីបញ្ជាក់ការពិតហើយ ព្រះរាជអាជ្ញានោះ ត្រូវធ្វើកំណត់ហេតុស្ដីពីការស្ដាប់ចម្លើយបញ្ជូនទៅចៅក្រមស៊ើបសួរដែលទទួលបន្ទុកស៊ើបសួរលើសំណុំរឿង។ ម្យ៉ាងវិញទៀត ប្រសិនបើមានការផ្ទេរបុគ្គលពាក់ព័ន្ធទៅពន្ធនាគារផ្សេងទៀត ការផ្ទេរនេះជាតួនាទីរបស់ព្រះរាជអាជ្ញាក្នុងការចាត់ចែង។ ជានីតិវិធីដែលត្រូវសំគាល់ផងដែរថា នៅពេលខ្លះជនត្រូវចោទដែលជាកម្មវត្ថុនៃដីកាបង្គាប់ឱ្យចាប់ខ្លួននោះ មិនត្រូវបានបញ្ជូនទៅបង្ហាញខ្លួននៅចំពោះមុខចៅក្រមស៊ើបសួរទេ។ មូលហេតុព្រោះថា នៅពេលចៅក្រមស៊ើបសួរចេញដីកាបង្គាប់ឲ្យចាប់ខ្លួនហើយ គាត់បានសម្រេចបិទបញ្ចប់ការស៊ើបសួររបស់គាត់ដោយបញ្ជូនសុំណុំរឿងនោះមកជំនុំជម្រះដែលស្ថិតនៅក្រោមសមត្ថកិច្ចរបស់អគ្គាធិកាជំនុំជម្រះ (ចៅក្រមជំនុំជម្រះ) ។ ក្នុងករណីនេះ បុគ្គលនោះត្រូវតែបញ្ជូនខ្លួនទៅចំពោះមុខចៅក្រមជំនុំជម្រះ ដើម្បីបើកសវនាការអង្គសេចក្ដីជំនុំជម្រះសម្រេចអំពីរឿងឃុំខ្លួន ឬ មិនឃុំខ្លួនជននោះប្រសិនបើពុំទាន់ដល់ការកំណត់នៃសវនាអង្គសេចក្ដី។

## កថាខណ្ឌទី៤ ដីកាបង្គាប់ឲ្យឃុំខ្លួន

### ក. អត្ថន័យនៃដីកាបង្គាប់ឲ្យឃុំខ្លួន

ចៅក្រមស៊ើបសួរ អាចចេញដីកាបង្គាប់ឱ្យឃុំខ្លួនបាន[50]។ ដីកាបង្គាប់អោយឃុំខ្លួន គឺជាបញ្ជាដល់ប្រធានពន្ធនាគារ ឬ មណ្ឌលឃុំខ្លួនឲ្យទទួល និងឃុំខ្លួនជនត្រូវចោទ។ ចៅក្រមស៊ើបសួរ អាចចេញដីកាបង្គាប់ឲ្យឃុំខ្លួនបានលុះត្រាតែបន្ទាប់ពីចេញដីកាសម្រេចឱ្យឃុំខ្លួនបណ្ដោះអាសន្ន[51]។

[50] មាត្រា ២១៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

[51] មាត្រា ២២០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

**ខ. លក្ខខណ្ឌនៃការចេញដីកាបង្គាប់ឲ្យឃុំខ្លួន**

ចៅក្រមសើបសួរ សម្រេចចេញដីកាបង្គាប់ឱ្យឃុំខ្លួន លុះត្រាតែជនត្រូវចោទជាកម្មវត្ថុនៃដីកាសម្រេចឱ្យឃុំខ្លួនបណ្តោះអាសន្ន។ បានន័យថា លក្ខខណ្ឌនៃការចេញដីកាបង្គាប់ឲ្យឃុំខ្លួន គឺអាចប្រព្រឹត្តទៅបាន បន្ទាប់ពីចៅក្រមស៊ើបសួរបានសម្រេចធ្វើការឃុំខ្លួនជនណាម្នាក់តាមរយៈដីកាសម្រេចឱ្យឃុំខ្លួនបណ្តោះអាសន្ន។ ផ្ទុយទៅវិញ ចៅក្រមស៊ើបសួរមិនអាចចេញដីកាបង្គាប់ឱ្យឃុំខ្លួនជនត្រូវចោទមុនការសម្រេចឃុំខ្លួនបណ្តោះអាសន្នបានទេ។ ហើយចៅក្រមស៊ើបសួរ អាចសម្រេចចេញដីកាបង្គាប់ឱ្យឃុំខ្លួនបាន ដោយកំណត់ពីនិទ្ទេសដែលត្រូវចុះក្នុងដីកាបង្គាប់ឱ្យឃុំខ្លួនដូចខាងក្រោម ៖

- លេខ ថ្ងៃ ខែ ឆ្នាំ សំណុំរឿង
- អត្តសញ្ញាណរបស់ជនត្រូវចោទ
- ប្រភេទបទល្មើសដែលបានចោទប្រកាន់ និង អត្ថបទច្បាប់ដែលកំណត់ និង បង្ក្រាបបទល្មើស
- ឈ្មោះ និង ឋានៈរបស់ចៅក្រមដែលចេញដីកា
- ដីកានេះត្រូវមានចុះលេខនៃការចេញដីកា ស្របតាមលំដាប់លេខរៀងនៃសៀវភៅចុះលេខដីកាបង្គាប់ឲ្យឃុំខ្លួន។

ដីកាបង្គាប់ឲ្យឃុំខ្លួន ត្រូវចុះកាលបរិច្ឆេទ និង ចុះហត្ថលេខាដោយចៅក្រមស៊ើបសួរ និងមានបោះត្រាផង[52]។

**គ. ការអនុវត្តដីកាបង្គាប់ឲ្យឃុំខ្លួន**

ចំពោះការអនុវត្តដីកាបង្គាប់ឱ្យឃុំខ្លួន ដីកានេះត្រូវយកទៅអនុវត្តដោយប្រធានពន្ធនាគារ ឬមណ្ឌលឃុំខ្លួននៅកន្លែងដែលបុគ្គលនោះឃុំខ្លួន។ ប៉ុន្តែក្នុងលក្ខខណ្ឌដែលបុគ្គលដែលត្រូវឃុំខ្លួនកំពុងស្ថិតនៅក្រោមការឃុំខ្លួនរបស់មន្ត្រីនគរបាលយុត្តិធម៌នៅឡើយមន្ត្រីនគរបាលយុត្តិធម៌ ត្រូវធ្វើការបញ្ជូនជនត្រូវចោទ ឬ ជានជាប់ពាក់ព័ន្ធនោះទៅកាន់ពន្ធនាគារ ឬ មណ្ឌលឃុំខ្លួនដូចមានបញ្ជាក់ចង្អុលបង្ហាញតាមរយៈដីកាបង្គាប់ឱ្យឃុំខ្លួន។

ប្រធានពន្ធនាគារ ឬ មណ្ឌលឃុំខ្លួនត្រូវទទួល និងឃុំខ្លួនបុគ្គលដែលមានដីកាបង្គាប់ឲ្យឃុំខ្លួនរហូតទាល់តែមានការទទួលដំណឹងអំពីការដោះលែងឲ្យមានសេរីភាពវិញ[53]។ ម្យ៉ាងវិញទៀត ប្រធានពន្ធនាគារ ឬមណ្ឌលឃុំខ្លួន ត្រូវរក្សាទុកដើមដីកាបង្គាប់អោយឃុំខ្លួន ឬចុងដីកានេះដែល

[52] មាត្រា ២២១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ
[53] មាត្រា ២២២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

បញ្ជាក់ថាត្រឹមត្រូវតាមច្បាប់។

## ផ្នែកទី២ ការកំណត់សិទ្ធិទៅកាន់ជនត្រូវចោទ

ការកំណត់សិទ្ធិទៅកាន់ជនត្រូវចោទ គឺជាសមត្ថកិច្ចរបស់ចៅក្រមស៊ើបសួរក្នុងដំណាក់កាលស៊ើបសួរស្វែងរកការពិត។ ជាក់ស្តែង ចៅក្រមស៊ើបសួរមានសិទ្ធិអំណាចពេញទីដើម្បីរកសាជនត្រូវចោទជូនតុលាការឲ្យចាត់វិធានការ និងអនុវត្តអោយស្របនឹងច្បាប់នៃដែនដីព្រះរាជាណាចក្រកម្ពុជា តាមរយៈ ការឃុំខ្លួនបណ្តោះអាសន្ន ការដាក់ជនត្រូវចោទឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ និង ការធានាជនត្រូវចោទឲ្យនៅក្រៅឃុំ។

ចំពោះការឃុំខ្លួនបណ្តោះអាសន្ន គឺជាការដកហូតនូវសិទ្ធិសេរីភាពក្នុងការដើរហើរ ដោយជនត្រូវចោទត្រូវបានឃុំខ្លួណក្នុងមណ្ឌលឃុំខ្លួន ឬពន្ធនាគារ។

ការត្រួតពិនិត្យតាមផ្លូវតុលាការ គឺសំដៅលើករណីដកហូតសិទ្ធិខ្លះតែប៉ុណ្ណោះ ដោយជនត្រូវចោទមានសេរីភាពនៅក្រៅឃុំ ប៉ុន្តែជននោះត្រូវមានកាតព្វកិច្ចត្រូវបំពេញមួយចំនួន។

ការធានាជនត្រូវចោទឲ្យនៅក្រៅឃុំ គឺជាដីកាសម្រេចមិនឃុំខ្លួនជនត្រូវចោទ ប្រសិនបើចៅក្រមស៊ើបសួរយល់ឃើញថាលក្ខខណ្ឌនៃការឃុំខ្លួនមិនមែនជាវិធានការចាំបាច់។

### កថាខណ្ឌទី១ ការឃុំខ្លួនបណ្តោះអាសន្ន

បុគ្គលគ្រប់ៗរូប សុទ្ធតែមានសិទ្ធិសេរីភាព និងសន្តិសុខផ្ទាល់ខ្លួន។ គ្មានជនណាម្នាក់ត្រូវបានចាប់ខ្លួន ឬ ឃុំខ្លួនតាមអំពើចិត្តបានឡើយ។ មានន័យថា គ្មានបុគ្គលណាម្នាក់ ត្រូវបានដកហូតសេរីភាពបានឡើយ លើកលែងតែមានហេតុផលត្រឹមត្រូវ និង ស្របតាមនីតិវិធីដែលមានចែងក្នុងច្បាប់។ ប៉ុន្តែការឃុំខ្លួនបណ្តោះអាសន្ត គឺជាករណីពិសេស ហើយមានអំណាចធំបំផុតដែលក្រមនីតិវិធីព្រហ្មទណ្ឌបានផ្តល់សិទ្ធិនេះជូនចៅក្រមស៊ើបសួរដើម្បីអនុវត្តច្បាប់។ ដីកាក្នុងការសម្រេចឱ្យឃុំខ្លួនបណ្តោះអាសន្ន គឺជាប្រភេទសេចក្តីសម្រេចរបស់ចៅក្រមស៊ើបសួរ ក្នុងការឃុំខ្លួនជនត្រូវចោទជាបណ្តោះអាសន្ន ដើម្បីធានារក្សានូវកិច្ចស៊ើបសួរស្វែងរកការពិតនៃរឿងព្រហ្មទណ្ឌ។ ប៉ុន្តែអាចអនុវត្តក្នុងការឃុំខ្លួនជនដែលជាកម្មវត្ថុនៃការសម្រេចឃុំខ្លួនបណ្តោះអាសន្ន បានលុះត្រាតែចៅក្រមស៊ើបសួរចេញដីកាបង្គាប់ឱ្យឃុំខ្លួនមួយផ្សេងបន្ថែមទៀត។

#### ក. លក្ខខណ្ឌនៃការឃុំខ្លួនបណ្តោះអាសន្ន

ការឃុំខ្លួនបណ្តោះអាសន្ន អនុវត្តបានតែក្នុងករណីចោទប្រកាន់ពីបទឧក្រិដ្ឋ ឬបទមជ្ឈិមដែលច្បាប់កំណត់ឲ្យផ្តន្ទាទោសដាក់ពន្ធនាគារស្មើ ឬ លើសពី ១ (មួយ) ឆ្នាំ[54]។ ហើយដីកាសម្រេចឱ្យឃុំខ្លួនបណ្តោះអាសន្ន ចៅក្រមស៊ើបសួរអាចសម្រេចបានដោយយោងតាមហេតុផលដូចខាងក្រោម៖

[54] មាត្រា ២០៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

- ដើម្បីបញ្ចប់បទល្មើស ឬ បង្ការបទល្មើសកុំឱ្យកើតជាថ្មី
- ដើម្បីរារាំងកុំឲ្យមានការគាបសង្កត់លើសាក្សី ឬ ជនរងគ្រោះ ឬ ដើម្បីទប់ស្កាត់កុំឲ្យមានការត្រូវរ៉ូវគ្នារវាងជនត្រូវចោទ និង អ្នកផ្សំគំនិត
- ដើម្បីរក្សាភស្តុតាង ឬ តម្រុយជាសម្ភារៈ
- ដើម្បីធានារក្សាជនត្រូវចោទ ទុកជូនតុលាការចាត់ការតាមនីតិវិធី
- ដើម្បីការពារសន្តិសុខឱ្យជនត្រូវចោទ
- ដើម្បីងាយស្រួលក្នុងការស៊ើបសួរ
- ដើម្បីធានារក្សាសណ្តាប់ធ្នាប់សាធារណៈ កុំឱ្យច្របូកច្របល់ដែលបណ្តាលមកពីបទល្មើស[55]។

ខាងលើ ជាមូលហេតុចាំបាច់ ដែលចៅក្រមស៊ើបសួរសម្រេចធ្វើការឃុំខ្លួនជនត្រូវចោទ។

ជាគោលការណ៍ ចៅក្រមស៊ើបសួរអាចសម្រេចឃុំខ្លួនបណ្តោះអាសន្នចំពោះជនត្រូវចោទ ឬ ជនដែលបានប្រព្រឹត្តបទល្មើសទៅតាមនីតិវិធីនៃច្បាប់។ ប៉ុន្តែមានករណីមួយដែលចៅក្រមស៊ើបសួរមិនអាចធ្វើការសម្រេចប្រកាសទោសទណ្ឌកម្មទៅលើអនីតិជនដែលមានអាយុតិចជាង ១៤ (ដប់បួន) ឆ្នាំបានទេ បានន័យថាតុលាការអាចប្រកាសទោសទណ្ឌកម្មព្រហ្មទណ្ឌទៅលើអនីតិជនអាយុចាប់ពី ១៤ (ដប់បួន) ឆ្នាំឡើងទៅ ប្រសិនបើកាលៈទេសៈនៃបទល្មើស ឬ បុគ្គលិកលក្ខណៈតម្រូវ។ ហេតុដូចនេះ ចំពោះអនីតិជនដែលមានអាយុក្រោម ១៤ (ដប់បួន) ឆ្នាំ មិនទទួលខុសត្រូវព្រហ្មទណ្ឌចំពោះទង្វើរបស់ខ្លួនឡើយ ហើយវិធានការសម្រេចឃុំខ្លួនបណ្តោះអាសន្នរបស់ចៅក្រមស៊ើបសួរទៅលើអនីតិជនដែលមានអាយុស្ថិតក្នុងលក្ខខណ្ឌនេះ គឺមិនអាចធ្វើឡើយបានទេ។ ចៅក្រមស៊ើបសួរ អាចសម្រេចប្រគល់អនីតិជននេះឲ្យឪពុកម្តាយ ឬ អាណាព្យាបាល ឬ ប្រគល់ទៅមណ្ឌលមណ្ឌលអប់រំកែប្រែ ក្នុងករណីគ្មានអាណាព្យាបាល ដើម្បីរក្សាបណ្តោះអាសន្នរោងចាំសេចក្តីសម្រេចរបស់តុលាការ។

ក្នុងករណីជនត្រូវចោទមានអាយុចាប់ពី ១៤ (ដប់បួន) ឆ្នាំឡើងទៅ ចៅក្រមស៊ើបសួរអាចចេញដីកាសម្រេចឱ្យឃុំខ្លួនបណ្តោះអាសន្នបាន ប៉ុន្តែតម្រូវឲ្យមាននិទ្ទេសសំខាន់ៗដូចខាងក្រោម ៖

- ឈ្មោះចៅក្រមស៊ើបសួរ
- ឈ្មោះក្រឡាបញ្ជី
- លេខ ថ្ងៃ ខែ ឆ្នាំ សំណុំរឿង
- កាលបរិច្ឆេទនៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ

[55] មាត្រា ២០៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

- អត្តសញ្ញាណនៃជនត្រូវចោទ ថ្ងៃ ខែ ឆ្នាំ និង ទីកន្លែងកំណើត លំនៅដ្ឋានរបស់ជនត្រូវចោទ ប្រសិនបើមានពិរុទ្ធកម្មត្រូវប្រកាស (ធ្លាប់មានទោស ឬ គ្មាន)
- លេខ និងកាលបរិច្ឆេទនៃដីកា។

ក្រៅពីបញ្ជាក់ពីមូលហេតុពីការឃុំខ្លួនបណ្ដោះអាសន្នខាងលើ ចៅក្រមស៊ើបសួរត្រូវកំណត់ឲ្យបានច្បាស់នូវមាត្រានៃនីតិវិធីព្រហ្មទណ្ឌ ដែលចែងពីចិរវេលាអតិបរិមានៃការឃុំខ្លួនបណ្ដោះអាសន្នដែលចិរវេលានេះអាស្រ័យលើចរិតលក្ខណៈនៃបទល្មើស និង អាយុរបស់ជនត្រូវចោទ។

បន្ទាប់ពីមូលហេតុខាងលើ ចៅក្រមស៊ើបសួរក៏អាចសម្រេចឃុំខ្លួនជនត្រូវចោទបណ្ដោះអាសន្នបានដែរ ប្រសិនបើជនត្រូវចោទព្យាយាមគេចវេះដោយចេទនានៃកាតព្វកិច្ចត្រួតពិនិត្យតាមផ្លូវតុលាការ។ កាលណាចៅក្រមស៊ើបសួរសម្រេចថានឹងឃុំខ្លួនបណ្ដោះអាសន្ន ដោយមូលហេតុខាងលើនេះ ចៅក្រមស៊ើបសួរត្រូវចាត់នីតិវិធី ដូចមានចែងក្នុងមាត្រា ២០៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ដោយត្រូវជូនដំណឹងដល់ជនត្រូវចោទដើម្បីទទួលការកត់សំគាល់របស់ជននេះ និងមធ្យោបាយការពារខ្លួនដែលធ្វើឡើងដោយមេធាវីរបស់ជននោះ។ ចៅក្រមស៊ើបសួរសម្រេចឃុំខ្លួនជនត្រូវចោទតាមដីកាដែលមានសំអាងហេតុច្បាស់លាស់។ ដីកានេះត្រូវជូនដំណឹងភ្លាមដល់ព្រះរាជអាជ្ញា និងជនត្រូវចោទ។ ករណីចៅក្រមស៊ើបសួរអាចសម្រេចឃុំខ្លួនបណ្ដោះអាសន្ន មិនឲ្យលើសពី ៤ (បួន) ខែ ចំពោះនីតិជន និង ២ (ពីរ) ខែ ចំពោះអនីតិជន។

**ខ. នីតិវិធីនៃការឃុំខ្លួនបណ្ដោះអាសន្ន**

ចៅក្រមស៊ើបសួរ អាចសម្រេចអំពីវិធាន នៃការឃុំខ្លួនបណ្ដោះអាសន្ននេះដោយគំនិតរបស់ខ្លួនផ្ទាល់ ឬតាមសេចក្ដីសន្និដ្ឋានរបស់ព្រះរាជអាជ្ញា។ មុននឹងសម្រេចឃុំខ្លួនបណ្ដោះអាសន្ន ចៅក្រមស៊ើបសួរត្រូវជូនដំណឹងដល់ជនត្រូវចោទ ហើយទទួលការកត់សម្គាល់នានារបស់ជនត្រូវចោទ។ ករណីជនត្រូវចោទមានមេធាវីអមនោះ មេធាវីត្រូវបង្ហាញមធ្យោបាយការពារខ្លួន។ ដីកាបង្គាប់ឱ្យឃុំខ្លួនបណ្ដោះអាសន្នត្រូវជូនដំណឹងភ្លាមដល់ព្រះរាជអាជ្ញា និងជនត្រូវចោទ[56]។ បន្ទាប់ពីចៅក្រមស៊ើបសួរចេញដីកាសម្រេចឃុំខ្លួនបណ្ដោះអាសន្ន គឺត្រូវចេញដីកាមួយទៀតហៅថាដីកាបង្គាប់ឱ្យឃុំខ្លួន។ ដីកានេះគឺបញ្ជាក់ដល់ប្រធានពន្ធនាគារ ឬ មណ្ឌលឃុំខ្លួនឲ្យទទួល និងឃុំខ្លួនជនត្រូវចោទដែលមានកំណត់ក្នុងដីកាសម្រេចឲ្យឃុំខ្លួនបណ្ដោះអាសន្ន។

ការឃុំខ្លួនបណ្ដោះអាសន្នអាចធ្វើឡើងតាមសេចក្ដីសន្និដ្ឋានរបស់ព្រះរាជអាជ្ញា ករណីនេះបន្ទាប់ពីទទួលបណ្ដឹងតាមសេចក្ដីសន្និដ្ឋានរបស់ព្រះរាជអាជ្ញា សុំឲ្យឃុំខ្លួនបណ្ដោះអាសន្ន។ ប្រសិនបើចៅក្រមស៊ើបសួរសម្រេចឃុំខ្លួនបណ្ដោះអាសន្នជនត្រូវចោទ តាមការស្នើសុំរបស់ព្រះរាជ

[56] មាត្រា ២០៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

អាជ្ញានោះ ចៅក្រមស៊ើបសួរត្រូវចាត់វិធានការតាមនីតិវិធីដូចមានចែងក្នុងមាត្រា ២០៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា។ ប៉ុន្តែបើចៅក្រមស៊ើបសួរមិនព្រមសម្រេចឃុំខ្លួនបណ្ដោះអាសន្នតាមការស្នើសុំនេះ ចៅក្រមត្រូវចេញដីកាសម្រេចមិនឃុំខ្លួនក្នុងរយៈពេល ៥ (ប្រាំ) ថ្ងៃដោយមិនចាំបាច់មានសំអាងហេតុទេ ហើយត្រូវជូនដំណឹងនេះជាបន្ទាន់ដល់ព្រះរាជអាជ្ញា។

ក្នុងករណីចៅក្រមស៊ើបសួរ សម្រេចថានឹងឃុំខ្លួនបណ្ដោះអាសន្នដោយគំនិតផ្ដើមរបស់ខ្លួនគាត់ត្រូវជូនដំណឹងអំពីការឃុំខ្លួននេះភ្លាមដល់ព្រះរាជអាជ្ញា និងប្រាប់ទៅជនត្រូវចោទ ដែលត្រូវធ្វើឡើងតាមរយៈកំណត់ហេតុស្ដីពីការពិភាក្សាដេញដោលចំពោះមុខ។ ការជូនដំណឹងទៅកាន់ព្រះរាជអាជ្ញាត្រូវធ្វើឡើងក្នុងកំឡុងពេល ៥ (ប្រាំ) ថ្ងៃយ៉ាងយូរបំផុត។

### គ. ថិរវេលានៃការឃុំខ្លួនបណ្ដោះអាសន្ន

ថិរវេលានៃការឃុំខ្លួនបណ្ដោះអាសន្ន ត្រូវបានបញ្ញត្តិនៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌដែលមានលក្ខណៈខុសគ្នាអាស្រ័យទៅលើ ប្រភេទនៃបទល្មើស ( បទឧក្រិដ ឬ បទមជ្ឈឹម) ហើយជនត្រូវចោទគឺស្ថិតនៅក្នុងអាយុប៉ុន្មាន? តើគាត់គឺជានីតិជន ឬ អនីតិជន? ចំពោះអនីតិជនដែលមានអាយុតិចជាង ១៤ (ដប់បួន) ឆ្នាំ ចៅក្រមស៊ើបសួរមិនអាចសម្រេចចេញដីកាបង្គាប់ឲ្យឃុំខ្លួនបណ្ដោះអាសន្នបានទេ។ ករណីនេះចៅក្រមស៊ើបសួរ ត្រូវសម្រេចប្រគល់គាត់ទៅកាន់ ឪពុកម្ដាយ ឬអាណាព្យាបាល ឬមណ្ឌលអប់រំថែរក្សាបណ្ដោះអាសន្នដើម្បីធ្វើការរងចាំសេចក្ដីសម្រេចរបស់តុលាការ។

#### ករណីជនត្រូវចោទជានីតិជនត្រូវបានចោទប្រកាន់ពីបទឧក្រិដ្ឋ[57]

ចំពោះនីតិជនដែលត្រូវបានចោទប្រកាន់ពីបទឧក្រិដ្ឋ ការឃុំខ្លួនបណ្ដោះអាសន្នមិនអាចលើសពី ៦ (ប្រាំមួយ) ខែបានឡើយ។ ប៉ុន្តែបន្ទាប់ពីថិរវេលានោះ ចៅក្រមស៊ើបសួរអាចពន្យាការឃុំខ្លួនបណ្ដោះអាសន្នបានម្ដងរយៈពេល ៦ (ប្រាំមួយ) ខែ ដោយមានដីកាសំអាងហេតុត្រឹមត្រូវ និងច្បាស់លាស់ដែលដីកាសុំពន្យាពេលនោះ ហៅថា *(ដីកាសម្រេចពន្យាពេលឃុំខ្លួនបណ្ដោះអាសន្ន)*។ ការសុំពន្យាពេលនៃការឃុំខ្លួនបណ្ដោះអាសន្ននេះ ចៅក្រមស៊ើបសួរអាចសម្រេចពន្យាពេលឃុំខ្លួនបានតែចំនួន ២ (ពីរ) ដងប៉ុណ្ណោះ។

#### ករណីជនត្រូវចោទជានីតិជនត្រូវបានចោទប្រកាន់ពីបទមជ្ឈឹម[58]

ចំពោះនីតិជនដែលត្រូវបានចោទប្រកាន់ពីបទមជ្ឈឹម ការឃុំខ្លួនបណ្ដោះអាសន្នមិនអាចលើសពី ៤ (បួន) ខែបានឡើយ។ នៅក្នុងថិរវេលានេះ ចៅក្រមស៊ើបសួរអាចធ្វើការសម្រេចពន្យាពេលនៃការឃុំខ្លួនបណ្ដោះអាសន្នបានម្ដងគត់មិនឲ្យលើសពី ២ (ពីរ) ខែ ដោយមានសំអាងហេតុ

[57] មាត្រា ២០៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

[58] មាត្រា ២០៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

ត្រឹមត្រូវ និងច្បាស់លាស់ក្នុងដីកានេះ។ ថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្ននេះ មិនអាចលើសពីពាក់កណ្តាលនៃអប្បរិមានៃទោសដែលច្បាប់បានកំណត់ឡើយ។ ចំពោះដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្នក្នុងករណីនេះ មិនមែនជាការឃុំខ្លួនដែលកើតចេញពីអនុភាពផ្ទាល់នៃដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្នទេ ប៉ុន្តែវាជាអនុភាពដែលកើតចេញពីដីកាសម្រេចឲ្យពន្យាពេលឃុំខ្លួនបណ្តោះអាសន្នទៅវិញ។

**ករណីជនត្រូវចោទត្រូវបានចោទប្រកាន់ពីបទឧក្រិដ្ឋប្រឆាំងមនុស្សជាតិ ប្រល័យពូជសាសន៍ និង បទឧក្រិដ្ឋកម្មសង្គ្រាម**[59]

ប្រសិនបើមានការចោទប្រកាន់ពីបទឧក្រិដ្ឋប្រឆាំងមនុស្សជាតិក្តី ប្រល័យពូជសាសន៍ក្តី និងបទឧក្រិដ្ឋកម្មសង្គ្រាមក្តី ការឃុំខ្លួនបណ្តោះអាសន្នមិនអាចលើសពី ១ (មួយ) ឆ្នាំបានទេចំពោះបទល្មើសទាំងនេះ។ ក្រោយពីផុតថិរវេលាការឃុំខ្លួនបណ្តោះអាសន្ននេះ ប្រសិនបើចៅក្រមស៊ើបសួរមានសំអាងហេតុត្រឹមត្រូវ និងច្បាស់លាស់ នោះចៅក្រមរូបនេះអាចធ្វើការពន្យាការឃុំខ្លួនបណ្តោះអាសន្នម្តងបាន ១ (មួយ) ឆ្នាំ ហើយដីកាបង្គាប់ឲ្យពន្យាការឃុំខ្លួនបណ្តោះអាសន្ននេះបានតែ ២ (ពីរ) ដងគត់។

**ករណីជនត្រូវចោទជាអនីតិជនត្រូវបានចោទប្រកាន់ពីបទឧក្រិដ្ឋ**[60]

ចំពោះអនីតិជនដែលមានអាយុចាប់ពី ១៤ (ដប់បួន) ឆ្នាំ ដល់ក្រោម ១៨ (ដប់ប្រាំបី) ឆ្នាំ ដែលត្រូវបានចោទប្រកាន់ពីបទឧក្រិដ្ឋ ថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្នគឺ ៖

- ដីកាបង្គាប់ឲ្យឃុំខ្លួនបណ្តោះអាសន្នមិនអាចលើសពី ៤ (បួន) ខែបានទេ បើសិនអនីតិជននោះមានអាយុតិចជាង ១៦ (ដប់ប្រាំមួយ) ឆ្នាំ។
- ដីកាបង្គាប់ឲ្យឃុំខ្លួនបណ្តោះអាសន្នមិនអាចលើសពី ៦ (ប្រាំមួយ) ខែបានទេ បើសិនអនីតិជននោះមានអាយុពី ១៦ (ដប់ប្រាំមួយ) ឆ្នាំដល់ក្រោម ១៨ (ដប់ប្រាំបី) ឆ្នាំ។

ថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្នខាងលើនេះ មិនត្រូវលើសពីពាក់កណ្តាលនៃអប្បបរមានៃទោសដែលច្បាប់បានកំណត់សម្រាប់អនីតិជនឡើយ។

**ករណីជនត្រូវចោទជាអនីតិជនត្រូវបានចោទប្រកាន់ពីបទមជ្ឈិម**[61]

ចំពោះអនីតិជនដែលមានអាយុចាប់ពី ១៤ (ដប់បួន) ឆ្នាំ ដល់ក្រោម ១៨ (ដប់ប្រាំបី) ឆ្នាំ ត្រូវបានចៅក្រមស៊ើបសួរចេញដីកាបង្គាប់ឲ្យឃុំខ្លួនបណ្តោះអាសន្នពីបទមជ្ឈិម ហេតុនេះថិរវេលានៃការឃុំ

[59] មាត្រា ២១០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ
[60] មាត្រា ២១៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ
[61] មាត្រា ២១៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

ខ្លួនបណ្តោះអាសន្នគឺ ៖

- ការឃុំខ្លួនបណ្តោះអាសន្ន មិនអាចលើសពី ២ (ពីរ) ខែបានទេ កាលណាអនីតិជននោះមានអាយុតិចជាង ១៦ (ដប់ប្រាំមួយ) ឆ្នាំ។
- ការឃុំខ្លួនបណ្តោះអាសន្ន មិនអាចលើសពី ៤ (បួន) ខែទេកាលណាអនីតិជននោះមានអាយុចាប់ពី ១៦ (ដប់ប្រាំមួយ) ឆ្នាំ ដល់ក្រោម ១៨ (ដប់ប្រាំបី) ឆ្នាំ។

ថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្នខាងលើនេះ មិនត្រូវលើសពីពាក់កណ្តាលនៃអប្បបរមានៃទោសដែលច្បាប់បានកំណត់សម្រាប់អនីតិជនឡើយ។

**ឃ. ការធានាជនត្រូវចោទឲ្យនៅក្រៅឃុំ**

ចៅក្រមស៊ើបសួរ មានសិទ្ធិអំណាចយ៉ាងពេញលេញក្នុងការសម្រេចចិត្តបង្គាប់ឲ្យដោះលែងជនត្រូវចោទឲ្យនៅក្រៅឃុំបានគ្រប់ពេលវេលានៅក្នុងដំណាក់កាលស៊ើបសួរ[62]។ ការដោះលែងជនត្រូវចោទឲ្យនៅក្រៅឃុំ អាចតាមរយៈបណ្តឹងរបស់ព្រះរាជអាជ្ញា របស់ជនត្រូវចោទ ឬ តាមគំនិតរបស់ចៅក្រមស៊ើបសួរផ្ទាល់។ ជាទូទៅ ការចេញដីកាសម្រេចធានាជនត្រូវចោទឲ្យនៅក្រៅឃុំ មិនចាំបាច់តម្រូវឲ្យចៅក្រមស៊ើបសួរ បញ្ជាក់ពីមូលហេតុនោះទេ។ ប៉ុន្តែតាមរយៈការអនុវត្តជាក់ស្តែង ចៅក្រមស៊ើបសួរចេញដីកាសម្រេចមិនធ្វើការឃុំខ្លួនជនណាម្នាក់ គឺដោយសារតែមិនមានមូលហេតុចាំបាច់នៃការឃុំខ្លួនបណ្តោះអាសន្ន ដូចមានចែងក្នុងមាត្រា ២០៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

នៅពេលចៅក្រមស៊ើបសួរសម្រេចចេញដីកាធានាជនត្រូវចោទឲ្យនៅក្រៅឃុំ ចៅក្រមស៊ើបសួរត្រូវបំពេញនិទ្ទេសដែលត្រូវចុះក្នុងដីកាសម្រេចដូចតទៅ ៖

- ឈ្មោះរបស់ចៅក្រមស៊ើបសួរ
- ឈ្មោះក្រឡាបញ្ជី
- លេខ ថ្ងៃ ខែ ឆ្នាំ សំណុំរឿង
- អត្តសញ្ញាណរបស់ជនត្រូវចោទ
- ប្រភេទនៃបទល្មើសដែលបានចោទប្រកាន់ និង អត្ថបទច្បាប់ដែលកំណត់ និងបង្ក្រាបបទល្មើស

ដីកានេះ ត្រូវចុះលេខរៀង កាលបរិច្ឆេទ ហត្ថលេខារបស់ចៅក្រមស៊ើបសួរ និងក្រឡាបញ្ជី និងមានបោះត្រាផង។

[62] មាត្រា ២១៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

ការដោះលែងជនត្រូវចោទឱ្យនៅក្រៅឃុំ តាមបណ្តឹងរបស់ជនត្រូវចោទ[63]។ ចំពោះពាក្យសុំឲ្យដោះលែងនៅក្រៅឃុំដែលធ្វើឡើងដោយជនត្រូវចោទ គឺចៅក្រមស៊ើបសួរត្រូវបញ្ជូនពាក្យសុំនោះភ្លាមទៅកាន់ព្រះរាជអាជ្ញាដើម្បីផ្តល់យោបល់ និង បញ្ជូនសំណុំរឿងទៅកាន់ព្រះរាជអាជ្ញាធ្វើការពិនិត្យ។ ព្រះរាជអាជ្ញាត្រូវធ្វើការផ្តល់យោបល់ក្នុងរយៈពេលយ៉ាងឆាប់រហ័សបំផុត។ ហើយចៅក្រមស៊ើបសួរ ត្រូវសម្រេចយ៉ាងយូរបំផុតរយៈពេល ៥ (ប្រាំ) ថ្ងៃបន្ទាប់ពីមានការបញ្ជូនសំណុំរឿងទៅព្រះរាជអាជ្ញា។ ប៉ុន្តែប្រសិនបើ ពាក្យសុំដោះលែងនៅក្រៅឃុំនេះ ជាពាក្យសុំដែលធ្វើឡើងសាជាថ្មីទៅកាន់ចៅក្រមស៊ើបសួរ ឬ សភាស៊ើបសួរ ក្នុងរយៈពេល ១ (មួយ) ខែ បន្ទាប់ពីមានសេចក្តីបដិសេធពាក្យសុំលើកមុន ចៅក្រមស៊ើបសួរ ឬ សភាស៊ើបសួរត្រូវសម្រេចលើពាក្យសុំជាថ្មីក្នុងរយៈពេល ៥ (ប្រាំ) ថ្ងៃបន្ទាប់ពីបានទទួលពាក្យសុំ។ ប្រសិនបើចៅក្រមស៊ើបសួរ មិនបានសម្រេចក្នុងរយៈពេល ៥ (ប្រាំ) ថ្ងៃទេ ជនត្រូវចោទអាចធ្វើការដាក់ពាក្យប្តឹងផ្ទាល់ទៅសភាស៊ើបសួរ ដែលមានសិទ្ធិសម្រេចជំនួសចៅក្រមស៊ើបសួរ។

ការដោះលែងឱ្យនៅក្រៅឃុំ តាមបណ្តឹងព្រះរាជអាជ្ញា[64]។ ចំពោះព្រះរាជអាជ្ញាវិញ គឺព្រះរាជអាជ្ញាក៏អាចសុំឲ្យចៅក្រមស៊ើបសួរដោះលែងជនត្រូវចោទ បានគ្រប់ពេលវេលាផងដែរតាមរយៈបណ្តឹងសុំដោះលែងឲ្យនៅក្រៅឃុំ។ ក្រោយពេលទទួលបានពាក្យបណ្តឹងសុំដោះលែងឲ្យនៅក្រៅឃុំ ចៅក្រមត្រូវសម្រេចក្នុងរយៈពេល ៥ (ប្រាំ) ថ្ងៃ។ បើសិនចៅក្រមស៊ើបសួរមិនបានសម្រេចក្នុងរយៈពេល ៥ (ប្រាំ) ថ្ងៃទេ ព្រះរាជអាជ្ញាអាចប្តឹងសុំតាមរយៈពាក្យសុំទៅសភាស៊ើបសួរដែលសម្រេចជំនួសចៅក្រមស៊ើបសួរ។

នៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌ ជនត្រូវចោទត្រូវបានរក្សាទុកក្នុងពន្ធនាគាររហូតដល់ផុតរយៈពេលសម្រាប់ប្តឹងឧទ្ធរណ៍របស់ព្រះរាជអាជ្ញា លើកលែងតែព្រះរាជអាជ្ញាយល់ព្រមឲ្យដោះលែងជនត្រូវចោទនោះភ្លាមតាមរយៈលាយលក្ខណ៍អក្សរ។ ក្នុងករណីមានបណ្តឹងឧទ្ធរណ៍របស់ព្រះរាជអាជ្ញាអំពីដីកាដោះលែងឲ្យនៅក្រៅឃុំ ជនត្រូវចោទដែលនៅជាប់ឃុំ ត្រូវបានរក្សានៅក្នុងពន្ធនាគាររហូតទាល់តែសភាស៊ើបសួរបានសម្រេចអំពីបណ្តឹងឧទ្ធរណ៍។ ប៉ុន្តែការអនុវត្តជាក់ស្តែង កាលណាជនត្រូវចោទបានបង្ហាញខ្លួននៅចំពោះមុខចៅក្រមស៊ើបសួរ នោះចៅក្រមស៊ើបសួរនឹងសម្រេចថាឃុំខ្លួន ឬមិនឃុំខ្លួន។ ករណីដែលចៅក្រមស៊ើបសួរចេញដីកាសម្រេចមិនឃុំខ្លួន មានន័យថាចៅក្រមស៊ើបសួរធានាជនត្រូវចោទឲ្យរស់នៅក្រៅឃុំ។ ដីកានេះនឹងត្រូវយកទៅប្រតិបត្តិផ្ទាល់ដោយមន្ត្រីនគរបាលយុត្តិធម៌ដែលបានធ្វើការឃាត់ខ្លួនបុគ្គលត្រូវចោទ។ នៅក្នុងពេលទទួលដីកានេះ មន្ត្រី

[63] មាត្រា ២១៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ
[64] មាត្រា ២១៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

នគរបាលយុត្តិធម៌ត្រូវដោះលែងជនត្រូវចោទឱ្យត្រឡប់ទៅលំនៅដ្ឋានវិញភ្លាម ដោយមិនអាចបន្តការឃាត់ខ្លួនជនត្រូវចោទទៀតនោះទេ ទោះបីជាមានបណ្តឹងឧទ្ធរណ៍របស់ព្រះរាជអាជ្ញា ឬ ព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ទៅចំពោះមុខសភាស៊ើបសួរនៃសាលាឧទ្ធរណ៍ក៏ដោយ។

### កថាខណ្ឌទី២ ការត្រួតពិនិត្យតាមផ្លូវតុលាការ

ចៅក្រមស៊ើបសួរ អាចធ្វើការសម្រេចដោយចេញដីកាសម្រេចដាក់ជនត្រូវចោទឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការក្នុងលក្ខខណ្ឌ ដែលជនត្រូវចោទត្រូវបានចោទប្រកាន់ពីបទល្មើសដែលផ្តន្ទាទោសដាក់ពន្ធនាគារ និង ករណីជនត្រូវចោទត្រូវបានចៅក្រមស៊ើបសួរសម្រេចមិនឃុំខ្លួន។ វិធានការនេះ គឺអនុញ្ញាតឲ្យជនត្រូវចោទមានសេរីភាពរស់នៅក្រៅឃុំ ប៉ុន្តែត្រូវបំពេញនូវកាតព្វកិច្ចមួយចំនួនដែលតុលាការបានកំណត់ឲ្យបំពេញ។

#### ក. លក្ខខណ្ឌសម្រេចដាក់ឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ

ចៅក្រមស៊ើបសួរ អាចសម្រេចដាក់ជនត្រូវចោទរូបណាឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ ដោយតាមរយៈគំនិតផ្ទាល់របស់ខ្លួន ឬ តាមរយៈដីកាសេចក្តីសន្និដ្ឋានរបស់ព្រះរាជអាជ្ញា។

ចៅក្រមស៊ើបសួរ អាចសម្រេចដាក់ជនត្រូវចោទណាម្នាក់ឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការបានក្នុងលក្ខខណ្ឌដែលជនត្រូវចោទ ត្រូវបានចោទប្រកាន់អំពីបទល្មើសដែលត្រូវផ្តន្ទាទោសដាក់ពន្ធនាគារ និង ករណីដែលជននេះត្រូវបានចៅក្រមស៊ើបសួរសម្រេចមិនឃុំខ្លួន។ នេះបានន័យថា ចៅក្រមស៊ើបសួរមិនអាច ជ្រើសរើសយកវិធានការនៃការដាក់ឱ្យជនត្រូវចោទស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការបានឡើយ ក្នុងករណីបណ្តឹងអាជ្ញាមិនត្រូវបានចោទប្រកាន់ពីបទល្មើសព្រហ្មទណ្ឌដែលត្រូវកំណត់ផ្តន្ទាទោសដាក់ពន្ធនាគារ។ លើសពីនេះ ចៅក្រមស៊ើបក៏មិនអាចចេញដីកាសម្រេចដាក់ឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ ចំពោះអនីតិជនដែលមានអាយុក្រោម ១៤ (ដប់បួន) ឆ្នាំ[65]។

នៅក្នុងដីកានេះ ចៅក្រមស៊ើបសួរត្រូវចុះពីនិទ្ទេស និង បញ្ជាក់ពីកាតព្វកិច្ចជាចាំបាច់ ហើយច្បាស់លាស់ដើម្បីអោយជនត្រូវចោទអនុវត្ត។

ចំពោះនិទ្ទេស ដែលចៅក្រមត្រូវចុះមុនពេលសម្រេចដាក់ឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការរួមមាន ៖

- ឈ្មោះចៅក្រមស៊ើបសួរ
- ឈ្មោះក្រឡាបញ្ជី

[65] មាត្រា ២២៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

- លេខ ថ្ងៃ ខែ ឆ្នាំ សំណុំរឿង
- លេខ ថ្ងៃ ខែ ឆ្នាំ នៃដីកាបញ្ជូនរឿងឱ្យស៊ើបសួរ
- លេខ ថ្ងៃ ខែ ឆ្នាំ នៃដីកាសម្រេចមិនឃុំខ្លួនបណ្តោះអាសន្ន
- អត្តសញ្ញាណរបស់ជនត្រូវចោទ
- សំអាងហេតុ
- ប្រភេទនៃបទល្មើសដែលចោទប្រកាន់ និង អត្ថបទច្បាប់ស្តីពីការជំណាត់ និង បង្ក្រាបបទល្មើស
- ផ្នែកនៃសេចក្តីសម្រេចរបស់ដីកា

ក្នុងដីកានេះ ត្រូវបញ្ជាក់អំពីចំណាត់ការបន្តលើការឃុំខ្លួនជនត្រូវចោទ ប្រសិនបើជនត្រូវចោទបានគេចវេសមិនគោរពកាតព្វកិច្ចដែលបានកំណត់ក្នុងសេចក្តីសម្រេចនៃដីកា។

ចំពោះកាតព្វកិច្ចដែលចៅក្រមស៊ើបសួរ មានអនុភាពបង្គាប់ឲ្យជនត្រូវចោទដែលស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ គឺ៖

- មិនត្រូវចេញក្រៅពីព្រំប្រទល់ដែនដីកំណត់ដោយចៅក្រមស៊ើបសួរ។
- មិនត្រូវផ្លាស់ប្តូរទីលំនៅឋានដោយគ្មានការអនុញ្ញាតពីចៅក្រមស៊ើបសួរ។
- មិនត្រូវទៅកាន់ទីកន្លែងខ្លះដែលកំណត់ដោយចៅក្រមស៊ើបសួរ។
- ត្រូវចូលបង្ហាញខ្លួនតាមការកំណត់នៅអង្គភាពនគរបាល ឬ កងរាជអាវុធហត្ថដែលចាត់តាំងដោយចៅក្រមស៊ើបសួរ។
- ប្រគល់ជូនដល់ការិយាល័យក្រឡាបញ្ជីគ្រប់បកសារបញ្ជាក់អំពីអត្តសញ្ញាណ។
- មិនអនុញ្ញាតឲ្យបើកបររថយន្ត។
- មិនត្រូវទទួល ឬ ជួបជាមួយបុគ្គលដែលចង្អុលបង្ហាញដោយចៅក្រមស៊ើបសួរ។
- ដាក់ប្រាក់ធានាដែលចំនួនប្រាក់ធានា និងចិរវេលាបង់ប្រាក់នេះ ត្រូវកំណត់ដោយចៅក្រមស៊ើបសួរ តាមការផ្អែកលើធនធានរបស់ជនត្រូវចោទ។
- មិនត្រូវកាន់កាប់ ឬយកតាមខ្លួននូវអាវុធ។ ត្រូវប្រគល់ជូនដល់ការិយាល័យក្រឡាបញ្ជីនូវអាវុធដែលជនត្រូវចោទកាន់កាប់។
- មិនត្រូវធ្វើសកម្មភាពវិជ្ជាជីវៈខ្លះ។ ករណីនេះចៅក្រមស៊ើបសួរមិនអាចហាមឃាត់ការអនុញ្ញាតនូវអណត្តិបោះឆ្នោត សកម្មភាពសហជីពបានទេ[66]។

[66] មាត្រា ២២៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

ដីកានេះត្រូវបានចុះកាលបរិច្ឆេទ ចុះហត្ថលេខាដោយចៅក្រមស៊ើបសួរ និងក្រឡាបញ្ជី និងបោះត្រាផង។

**ខ. នីតិវិធីនៃការដាក់ឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ**

បន្ទាប់ពីមន្ត្រីនគរបាលយុត្តិធម៌ បានធ្វើការបញ្ជូនជនសង្ស័យមកកាន់ចៅក្រមស៊ើបសួរដើម្បីធ្វើការស៊ើបសួរស្វែងរកការពិតហើយ។ ចៅក្រមស៊ើបសួរត្រូវធ្វើការសម្រេចចិត្តថា គួរឃុំខ្លួន ឬ មិនឃុំខ្លួន? ប្រសិនបើចៅក្រមសម្រេចមិនឃុំខ្លួន នោះចៅក្រមស៊ើបសួរត្រូវចេញដីកាសម្រេចដាក់ជនត្រូវចោទឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការដែលជាវិធានជំនួសឲ្យការឃុំខ្លួនបណ្តោះអាសន្ន ហើយជាវិធានការមួយនេះមិនសួរជាបិទសិទ្ធិសេរីភាពរបស់ជនត្រូវចោទទាំងស្រុងនោះទេ ប្រសិនបើចៅក្រមយល់ឃើញថាករណីនេះមិនចាំបាច់ត្រូវធ្វើការឃុំខ្លួនបណ្តោះអាសន្ន។

កាលណាចៅក្រមស៊ើបសួរ យល់ឃើញថាត្រូវចេញដីកាសម្រេចដាក់ជនត្រូវចោទឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ ត្រូវជូនដំណឹងក្នុងរយៈពេលយ៉ាងខ្លីបំផុតដល់ព្រះរាជអាជ្ញា និងជនត្រូវចោទ។

ករណីប្រសិនបើ ចៅក្រមស៊ើបសួរបានទទួលបណ្តឹងរបស់ព្រះរាជអាជ្ញាសម្រេចសុំដាក់ជនត្រូវចោទឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ ប៉ុន្តែមិនព្រមសម្រេចតាមការសុំនេះទេ ចៅគ្រមស៊ើបសួរត្រូវចេញដីកាបដិសេធក្នុងរយៈពេល ៥ (ប្រាំ) ថ្ងៃ ។ ដីកាសម្រេចនេះត្រូវជូនដំណឹងក្នុងរយៈពេលខ្លីបំផុតទៅកាន់ព្រះរាជអាជ្ញា។ ប្រសិនបើចៅក្រមស៊ើបសួរមិនបានសម្រេចក្នុងរយៈពេល ៥ (ប្រាំ) ថ្ងៃទេ ព្រះរាជអាជ្ញាអាចធ្វើការដាក់ពាក្យប្តឹងទៅកាន់សភាស៊ើបសួរដើម្បីសម្រេចជំនួស[67]។

នៅពេលចេញដីកានេះ ចៅក្រមស៊ើបសួរអាចបង្គាប់ឱ្យជនត្រូវចោទអនុវត្តកាតព្វកិច្ចទាំងអស់ដែលចៅក្រមបានដាក់ឲ្យ ហើយក្រឡាបញ្ជីត្រូវសរសេរបង្កាន់ដៃទទួលសំណុំឯកសារទាំងនោះដែលបានកំណត់ដោយចៅក្រមស៊ើបសួរដោយមានចុះហត្ថលេខារួមដោយប្រធានតុលាការ ព្រះរាជអាជ្ញា និង ក្រឡាបញ្ជី។

ក្នុងករណីជនត្រូវចោទគេចវេសពីកាតព្វកិច្ចនៃការត្រួតពិនិត្យតាមផ្លូវតុលាការ ចៅក្រមស៊ើបសួរអាចសម្រេចកែប្រែវិធានការខាងលើ មកជំនួសដោយវិធានការឃុំខ្លួនបណ្តោះអាសន្នវិញបាន។

កាលណាចៅក្រមស៊ើបសួរ សម្រេចថានឹងឃុំខ្លួនបណ្តោះអាសន្ន ដោយមានមូលហេតុខាងលើនេះ ចៅគ្រមស៊ើបសួរត្រូវជូនដំណឹងដល់ជនត្រូវចោទ និង ទទួលការកត់សំគាល់របស់ជននេះ។ ប្រសិនបើជនត្រូវចោទមានមេធាវីអម នោះមេធាវីត្រូវជូនមធ្យោបាយការពារកូនក្តីរបស់ខ្លួន។

[67] មាត្រា ២២៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

ការសម្រេចរបស់ចៅក្រមស៊ើបសួរ អាចកែប្រែខ្លឹមសារនៃកាតព្វកិច្ច ឬ អាចលុបចោល ឬ បន្ថែមកាតព្វកិច្ចថ្មីបានគ្រប់ពេលវេលា។ ហើយចៅក្រមស៊ើបសួរក៏អាចបញ្ចប់ការត្រួតពិនិត្យតាមផ្លូវតុលាការបានដែរ ប្រសិនបើយល់ឃើញថាជាការគួរ។

**គ. ការអនុវត្តនីតិវិធីដាក់ឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ**

យោងតាមសារាចរណ៍ ០១ កយ. សរ / ១៤ ចុះថ្ងៃទី ២២ ខែមករា ឆ្នាំ ២០១៤ ស្តីអំពីការអនុវត្តបទបញ្ញត្តិដាក់ជនត្រូវចោទឲ្យនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ បានបញ្ជាក់ដូចខាងក្រោម:

ចៅក្រមស៊ើបសួរមានតួនាទីធានាឲ្យបាននូវការអនុវត្តតាមគោលការណ៍នេះ ដោយយកចិត្តទុកដាក់ឲ្យបានហ្មត់ចត់អំពីកាលៈទេសៈ នៃបទល្មើស ឬ បុគ្គលិកលក្ខណៈរបស់ជនត្រូវចោទឲ្យបានសមស្រប និង ឲ្យមានតុល្យភាពទៅនឹងស្ថានភាពសង្គម ក្នុងការសម្រេចមិនឃុំខ្លួនជនត្រូវចោទ ហើយដាក់ជនត្រូវចោទឲ្យនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ។

ចៅក្រមស៊ើបសួរ ត្រូវតែគិតអមពីវិធានការនៃការត្រួតពិនិត្យតាមផ្លូវតុលាការ និង ឃ្លាំមើលដើម្បីធានាថា ជនត្រូវចោទនឹងអនុវត្តកាតព្វកិច្ចដូចមានចែងក្នុងមាត្រា ២២៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌបានត្រឹមត្រូវ។ ករណីនេះចៅក្រមស៊ើបសួរ គប្បីចាត់តាំងបុគ្គលណាម្នាក់ដែលមានសមត្ថភាពអាចជួយតាមឃ្លាំមើល និង ធ្វើរបាយការណ៍ជូនព្រះរាជអាជ្ញាតាមការកំណត់។

ក្នុងករណីចាំបាច់ដើម្បីធានាដល់ការឃ្លាំមើលជនត្រូវចោទ ចៅក្រមស៊ើបសួរគួរតែគប្បីដាក់កាតព្វកិច្ចឲ្យជនត្រូវចោទចូលបង្ហាញខ្លួនតាមការកំណត់នៅក្នុងអង្គភាពនគរបាល ឬ កងរាជអាវុធហត្ថ ដែលស្ថិតនៅជិតលំនៅដ្ឋានស្នាក់នៅជាក់លាក់ណាមួយរបស់ជនត្រូវចោទ។

ចៅក្រមស៊ើបសួរ ត្រូវផ្តល់ដីកាសម្រេចដាក់ជនត្រូវចោទនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ ឲ្យដល់អង្គភាពនគរបាល ឬ កងរាជអាវុធហត្ថ ដែលស្ថិតនៅជិតលំនៅដ្ឋានដែលជនត្រូវចោទរស់នៅ ដើម្បីអនុវត្តកាតព្វកិច្ចក្រៅពីការជូលដំណឹងដល់ព្រះរាជអាជ្ញា។

ចៅក្រមស៊ើបសួរត្រូវតែណែនាំជនត្រូវចោទ ដែលបានដាក់ឲ្យនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការឲ្យយកដីកាសម្រេចនេះទៅបង្ហាញដល់ប្រធានអង្គភាពនគរបាល ឬ កងរាជអាវុធហត្ថ ឬ បុគ្គលដែលត្រូវបានចាត់តាំង ក្នុងមូលដ្ឋានដែលខ្លួនរស់នៅ។

ចៅក្រមស៊ើបសួរត្រូវពិចារណាលើរបាយការណ៍ ឬ ពត៌មានរបស់អង្គភាព ឬ បុគ្គលដែលត្រូវបានចាត់តាំងពាក់ព័ន្ធនឹងជនត្រូវចោទ ដើម្បីជាមូលដ្ឋានក្នុងការសម្រេចតាមបញ្ញត្តិនៃមាត្រា២២៧ ២២៨ ២២៩ និង ២៣០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

**ឃ. តួនាទីចៅក្រមស៊ើបសួរក្នុងដំណាក់កាលត្រួតពិនិត្យតាមផ្លូវតុលាការ**

នៅក្នុងដំណាក់កាល ការដាក់ឲ្យជនត្រូវចោទ ឬជនដែលជាប់ពាក់ព័ន្ធស្ថិតនៅក្រោមការត្រួត

ពិនិត្យតាមផ្លូវតុលាការ ចៅក្រមស៊ើបសួរអាចកែប្រែខ្លឹមសារនៃកាតព្វកិច្ច អាចលុបចោល ឬ បញ្ចូលកាតព្វកិច្ចថ្មីបានគ្រប់ពេលវេលា ហើយក៏អាចបញ្ចប់ការត្រួតពិនិត្យតាមផ្លូវតុលាការបានដែរ[68]។ ករណីនេះចៅក្រមស៊ើបសួរសម្រេចតាមដីកា ដែលត្រូវជូនដំណឹងក្នុងរយៈពេលដ៏ខ្លីបំផុតដល់ព្រះរាជអាជ្ញា និង ជនត្រូវចោទ។

ជាការពិតណាស់ក្នុងអំឡុងពេលដាក់ជនត្រូវចោទ ឲ្យស្ថិតក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ នោះចៅក្រមស៊ើបសួរយល់ឃើញថាជនត្រូវចោទគោរពកាតព្វកិច្ចបានត្រឹមត្រូវ មានការកែប្រែខ្លួនក្លាយជាពលរដ្ឋល្អវិញនោះ គឺចៅក្រមស៊ើបសួរអាចសម្រេចធ្វើការលុបចោល ឬដកកាតព្វកិច្ចមួយចំនួននូវកាតព្វកិច្ចដែលបានដាក់លើជនត្រូវចោទបាន។ ប៉ុន្តែក៏មានករណីផ្សេងទៀតដែលចៅក្រមស៊ើបសួរយល់ឃើញថា មានកាតព្វកិច្ចខ្លះចៅក្រមមិនបានហាមឃាត់ ហើយចៅក្រមស៊ើបសួរចង់បន្ថែមកាតព្វកិច្ចនោះដើម្បីឲ្យជនត្រូវចោទបំពេញ ដូច្នេះជនត្រូវចោទត្រូវតែអនុវត្តតាមការសម្រេចរបស់ចៅក្រមស៊ើបសួរដាច់ខាត។

ក្នុងករណីព្រះរាជអាជ្ញា សុំឲ្យលើកលែង ឬ កែប្រែការត្រួតពិនិត្យតាមផ្លូវតុលាការ។ ចៅក្រមស៊ើបសួរត្រូវសម្រេចក្នុងរយៈពេល ៥ (ប្រាំ) ថ្ងៃ។ ដីកាសម្រេចនេះ ត្រូវជូនដំណឹងក្នុងរយៈពេលខ្លីបំផុតជូនព្រះរាជអាជ្ញា។ ប៉ុន្តែប្រសិនបើ ចៅក្រមស៊ើបសួរមិនបានសម្រេចក្នុងរយៈពេល ៥ (ប្រាំ) ថ្ងៃទេ ព្រះរាជអាជ្ញាអាចធ្វើការដាក់ពាក្យដើម្បីឲ្យសភាស៊ើបសួរសម្រេចជំនួសចៅក្រមស៊ើបសួរ។ គួរបញ្ជាក់ផងដែរថា រាល់ដីកាសម្រេចមិនព្រមធ្វើតាមពាក្យបណ្តឹងសុំរបស់ព្រះរាជអាជ្ញា ត្រូវតែមានសំអាងហេតុ[69]។

ចំពោះជនត្រូវចោទវិញក៏អាចស្នើសុំតាមរយៈការធ្វើពាក្យសុំឲ្យលើកលែង ឬ កែប្រែការដាក់ឲ្យត្រួតពិនិត្យតាមផ្លូវតុលាការបានគ្រប់ពេលវេលា។ ចៅក្រមស៊ើបសួរត្រូវបញ្ជូនរឿងនេះភ្លាមទៅកាន់ព្រះរាជអាជ្ញាដើម្បីសុំយោបល់ និងជូនសំណុំរឿងទៅកាន់ព្រះរាជអាជ្ញាពិនិត្យ។ ចៅក្រមស៊ើបសួរសម្រេចដីកានេះយ៉ាងយូរបំផុត ៥ (ប្រាំ) ថ្ងៃ គិតពីថ្ងៃបញ្ជូនសំណុំរឿងទៅព្រះរាជអាជ្ញា។ ដីកាសម្រេចនេះ ត្រូវជូនដំណឹងក្នុងរយៈពេលខ្លីបំផុតជូនព្រះរាជអាជ្ញា។ ប៉ុន្តែប្រសិនបើ ចៅក្រមស៊ើបសួរមិនបានសម្រេចក្នុងរយៈពេល ៥ (ប្រាំ) ថ្ងៃទេ ជនត្រូវចោទអាចធ្វើការដាក់ពាក្យដើម្បីឲ្យសភាស៊ើបសួរសម្រេចជំនួសចៅក្រមស៊ើបសួរ[70]។ ដីកាសម្រេចមិនព្រមធ្វើតាមពាក្យបណ្តឹងសុំរបស់ជនត្រូវចោទ ត្រូវតែមានសំអាងហេតុ។

[68] មាត្រា ២២៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

[69] មាត្រា ២២៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

[70] មាត្រា ២២៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

ប្រសិនបើជនត្រូវចោទគេចវេស ដោយចេតនាពីកាតព្វកិច្ចត្រួតពិនិត្យតាមផ្លូវតុលាការ ចៅក្រមស៊ើបសួរអាចសម្រេចឃុំខ្លួនបណ្តោះអាសន្នបាន ទោះបីទោសជាប់ពន្ធនាគារដែលរងនោះមានថិរវេលាប៉ុន្មានក៏ដោយ[71]។ ហើយទោះបីជាជនត្រូវចោទត្រូវបានឃុំខ្លួនបណ្តោះអាសន្នអស់រយពេលអតិបរិមាដែលមានចែងក្នុងមាត្រា ២០៨ ២០៩ ២១០ ២១៣ ២០១៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌក៏ដោយ។ ករណីនេះកាលណាចៅក្រមស៊ើបសួរ សម្រេចថានឹងធ្វើការឃុំខ្លួនបណ្តោះអាសន្នដោយមូលហេតុខាងលើ ចៅក្រមស៊ើបសួរត្រូវជូនដំណឹងទៅជនត្រូវចោទ ។ ប្រសិនបើជនត្រូវចោទមានមេធាវីអមនោះ មេធាវីត្រូវរកមធ្យោបាយការពារកូនក្តីរបស់ខ្លួន។ ចំពោះការសម្រេចឃុំខ្លួនបណ្តោះអាសន្ន ត្រូវតែមានសំអាងហេតុ។ ដីកាសម្រេចនេះ ត្រូវជូនដំណឹងភ្លាមដល់ព្រះរាជអាជ្ញា និង ជនត្រូវចោទ។ ការឃុំខ្លួនបណ្តោះអាសន្នក្នុងករណីនេះ គឺមានថិរវេលាមិនលើសពី ៤ (បួន) ខែ ចំពោះនីតិជន និង ២ (ពីរ) ខែ ចំពោះអនីតិជនដែលមានអាយុចាប់ពី ១៤ (ដប់បួន) ឆ្នាំ ទៅដល់ ១៨ (ដប់ប្រាំបី) ឆ្នាំ។

[71] មាត្រា ២៣០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

# ជំពូកទី៣
# ការបិទការស៊ើបសួរ

# ជំពូកទី៣

# ការបិទការស៊ើបសួរ

ប្រសិនបើចៅក្រមស៊ើបសួរ យល់ឃើញថាដំណាក់កាលស្រាវជ្រាវរបស់ខ្លួនមានលក្ខណៈគ្រប់គ្រាន់សមស្របសម្រាប់បញ្ចប់ នោះចៅក្រមស៊ើបសួរនឹងធ្វើការបិទការស៊ើបសួរដើម្បីបិទសំណុំរឿងក្រោមកិច្ចមួយហៅថា ដីកាដោះស្រាយ។ តាមរយៈដីកានោះ ជាដីកាបញ្ជូនទៅពិនិត្យ ឬ ដីកាលើកលែងការចោទប្រកាន់។ ចំពោះដីកាលើកលែងការចោទប្រកាន់ តុលាការត្រូវជូនដំណឹងជូនគូក្តីដើមរយៈពេល ២៤ (ម្ភៃបួន) ម៉ោងមុនលើកលែងចោទប្រកាន់។

## ផ្នែកទី១ នីតិវិធីនៃការបិទការស៊ើបសួរ

ចំពោះនីតិវិធីនៃការបិទការស៊ើបសួរ ត្រូវបានធ្វើឡើងដោយមានទំនាក់ទំនងរវាងព្រះរាជអាជ្ញា ចៅក្រមស៊ើបសួរ ជនត្រូវចោទ ដើមបណ្តឹងរដ្ឋប្បវេណី និងមេធាវីព្រមទាំងត្រូវឆ្លងកាត់ការបញ្ជូនសំណុំរឿងទៅវិញទៅមកដើម្បីបញ្ជាក់ពីការស្រាវជ្រាវកន្លងមកប្រកបដោយភាពយុត្តិធម៌ និងសុច្ចរិត។

គួរអោយកត់សំគាល់ នីតិវិធីនៃការជូនពត៌មានដោយចៅក្រមស៊ើបសួរ និងការបញ្ជូនសំណុំរឿងដោយព្រះរាជអាជ្ញា ត្រូវបានយកមកអនុវត្តដើម្បីធ្វើការបិទសំណុំរឿងជម្រះក្តី។

### កថាខណ្ឌទី១ ការជូនពត៌មានដោយចៅក្រមស៊ើបសួរ

កាលណាបើចៅក្រមស៊ើបសួរយល់ឃើញថា ការស៊ើបសួរត្រូវបានបញ្ចប់ នោះចៅក្រមស៊ើបសួរមានតួនាទីបញ្ជូនពត៌មាននេះដល់ព្រះរាជអាជ្ញា ជនត្រូវចោទ ដើមបណ្តឹងរដ្ឋប្បវេណី និងមេធាវីឱ្យបានដឹង[72]។ ការជូនដំណឹងនេះ គឺដើម្បីឲ្យព្រះរាជអាជ្ញា ជនត្រូវចោទ ដើមបណ្តឹងរដ្ឋប្បវេណី និងមេធាវីជ្រាបជាដំណឹងថាការស៊ើបសួររបស់ខ្លួនត្រូវបានបញ្ចប់សព្វគ្រប់។

ជាក់ស្តែងនៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ពុំបានបញ្ជាក់អំពីបែបបទនៃការផ្តល់ពត៌មានទាំងនេះទេ។ ករណីនេះជាទូទៅចៅក្រមស៊ើបសួរ ត្រូវបានតម្រូវឱ្យមានលិខិតជូនដំណឹងដោយភ្ជាប់ជាមួយនឹងការចុះលេខក្នុងសំណុំរឿង។

រយៈពេល២ (ពីរ) ថ្ងៃ ក្រោយមកចៅក្រមស៊ើបសួរនឹងបញ្ជូនសំណុំរឿងទៅព្រះរាជអាជ្ញាដើម្បីពិនិត្យ។

### កថាខណ្ឌទី២ ការបញ្ជូនសំណុំរឿងដោយព្រះរាជអាជ្ញា

ក្រោយពេលព្រះរាជអាជ្ញាទទួលបានសំណុំរឿងពីចៅក្រមស៊ើបសួរហើយ ប្រសិនបើព្រះរាជអាជ្ញាយល់ឃើញថាមានកត្តាចាំបាច់ត្រូវធ្វើកិច្ចស៊ើបសួរថ្មីទៀត ព្រះរាជអាជ្ញាមានសិទ្ធិស្នើសុំឲ្យ

[72] មាត្រា ២៤៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

ចៅក្រមស៊ើបសួរធ្វើកិច្ចស៊ើបសួរបន្ថែមដើម្បីបំពេញការស៊ើបសួរដែលធ្វើរួចទៅតាមមាត្រា១៣២ (ការស្នើសុំឲ្យបំពេញកិច្ចដោយព្រះរាជអាជ្ញា) នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា។

ក្នុងករណីដែលចៅក្រមស៊ើបសួរ មិនព្រមធ្វើតាមសេចក្តីសន្និដ្ឋានរបស់ព្រះរាជអាជ្ញាទេ ចៅក្រមស៊ើបសួរត្រូវចេញដីកាបដិសេធក្នុងថិរវេលា ១៥ (ដប់ប្រាំ) ថ្ងៃ បន្ទាប់ពីខ្លួនទទួលបាន។ ហើយដីកាដែលចៅក្រមស៊ើបសួរសម្រេចចេញត្រូវមានសំអាងហេតុ និងត្រូវជូនដំណឹងជាបន្ទាន់ទៅកាន់ព្រះរាជអាជ្ញា។ ប៉ុន្តែក្នុងករណី ដែលចៅក្រមស៊ើបសួរមិនបានធ្វើការសម្រេចនៅក្នុងថិរវេលា ១៥ (ដប់ប្រាំ) ថ្ងៃទេ ព្រះរាជអាជ្ញាមានសិទ្ធិប្តឹងទៅសភាស៊ើបសួរដើម្បីឲ្យសភាស៊ើបសួរសម្រេចជំនួស។

ក្រោយពីបានពិនិត្យសំណុំរឿងដែលចៅក្រមស៊ើបសួរបានបញ្ជូនមកចប់សព្វគ្រប់ ព្រះរាជអាជ្ញាមានតួនាទីមួយគឺ ត្រូវបង្វិលសំណុំរឿងទៅកាន់ចៅក្រមស៊ើបសួរវិញដោយមានដីកាសន្និដ្ឋានជាស្ថាពរភ្ជាប់ជាមួយផង។ចំពោះការត្រួតពិនិត្យសំណុំរឿងរបស់ជនត្រូវចោទនៅក្នុងឃុំ គឺមានរយៈពេល ១៥ (ដប់ប្រាំ) ថ្ងៃ និងរយៈពេល ១ (មួយ) ខែ សម្រាប់ជនត្រូវចោទនៅក្រៅឃុំ។ ថិរវេលានេះត្រូវគិតពីថ្ងៃដែលព្រះរាជអាជ្ញាបានទទួលសំណុំរឿង។ ប្រសិនព្រះរាជអាជ្ញាយល់ឃើញដូចចៅក្រមស៊ើបសួរដែរ ការស៊ើបសួរត្រូវបានបញ្ចប់ព្រះរាជអាជ្ញាត្រូវចេញដីកាជាស្ថាពរជាលាយលក្ខណ៍អក្សរដោយមានសំអាងហេតុដើម្បីបញ្ជូនខ្លួនជនត្រូវចោទទៅកាន់តុលាការជំនុំជម្រះ ឬក៏លើកលែងចោទប្រកាន់។

## ផ្នែកទី២ ប្រភេទនៃដីកាដោះស្រាយ

ពេលដែលចៅក្រមស៊ើបសួរយល់ឃើញថា ការស៊ើបសួររបស់ខ្លួនត្រូវបានបញ្ចប់សព្វគ្រប់នោះ ចៅក្រមស៊ើបសួរនឹងចេញដីកាដោះស្រាយ។ នៅក្នុងដីកាដោះស្រាយ ចៅក្រមស៊ើបសួរត្រូវតែសម្រេចអំពីការប្រគល់សងទៅឲ្យម្ចាស់ដើមនូវរាល់វត្ថុដែលបានចាប់យកទៅកាន់ម្ចាស់ដើមវិញ[73]។

ដីកាដោះស្រាយបញ្ចប់ការឃុំខ្លួនបណ្តោះអាសន្ន ក្នុងករណីនេះការដោះលែងជនត្រូវចោទដែលជាប់ឃុំឲ្យមានសេរីភាពត្រូវយកមកអនុវត្ត។ ប៉ុន្តែចំពោះសេចក្តីសម្រេចដោយឡែកទាក់ទងនឹងការឃុំខ្លួនបណ្តោះអាសន្ន និងការត្រួតពិនិត្យតាមផ្លូវតុលាការនៃដីកាដោះស្រាយរបស់ចៅក្រមស៊ើបសួរ គឺអាចរក្សាជនត្រូវចោទឲ្យជាប់ឃុំខ្លួនបណ្តោះអាសន្ន រហូតដល់ពេលចូលបង្ហាញខ្លួននៅមុខតុលាការ។ នៅក្នុងដីកានេះចៅក្រមស៊ើបសួរត្រូវយោងតាមលក្ខខណ្ឌដោយបញ្ជាក់ពីមូលហេតុនៃការឃុំខ្លួនបណ្តោះអាសន្នច្បាស់លាស់។ ហើយសេចក្តីសម្រេចទុកជនត្រូវចោទក្នុងឃុំជាបណ្តោះអាសន្ននឹងលែងមានអនុភាពក្នុងរយៈពេល ៤ (បួន) ខែ។ ប្រសិនបើជនត្រូវចោទមិនបានចូល

[73] មាត្រា ២៤៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

បង្ហាញខ្លួននៅមុខតុលាការក្នុងរយៈពេល ៤ (បួន) ខែនោះទេ មានន័យថាជនត្រូវចោទត្រូវបានដោះលែងឲ្យនៅក្រៅឃុំដោយឯកឯង។ ម្យ៉ាងវិញទៀត តាមរយៈដីកាដោះស្រាយដោយឡែករបស់ចៅក្រមស៊ើបសួរ មានសិទ្ធិអាចរក្សាជនត្រូវចោទឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការរហូតដល់ពេលចូលបង្ហាញខ្លួននៅចំពោះមុខតុលាការ។

ការចេញដីកាដោះស្រាយ គឺជាសមត្ថកិច្ចរបស់ចៅក្រមស៊ើបសួរផ្តាច់មុខ ក្រោយពេលដែលចៅក្រមស៊ើបសួរ ទទួលបានសេចក្តីសម្រេចជាស្ថាពរពីអយ្យការនោះចៅក្រមស៊ើបសួរត្រូវធ្វើចំណាត់ការលើសំណុំរឿងដោយធ្វើសេចក្តីសន្និដ្ឋានតាមរយៈ ដោយដីកានេះអាចជាដីកាបញ្ជូនទៅជំនុំជម្រះ ឬដីកាលើកលែងការចោទប្រកាន់[74]។

**កថាខណ្ឌទិ១ ដីកាបញ្ជូនទៅពិនិត្យរឿងមូល**

នៅពេលចៅក្រមស៊ើបសួរយល់ឃើញថា ជនត្រូវចោទមានពិរុទ្ធភាពគ្រប់គ្រាន់ ស៊ីសង្វាក់នឹងអង្គហេតុ ក៏ដូចជាភស្តុតាងដាក់បន្ទុកគ្រប់គ្រាន់លើជនត្រូវចោទដែលអំពើរបស់ជនត្រូវចោទបង្កបានជាបទល្មើសព្រហ្មទណ្ឌ ចៅក្រមស៊ើបសួរបញ្ជូនសំណុំរឿង និង ជនជាប់ចោទទៅជំនុំជម្រះ។ ករណីចៅក្រមស៊ើបសួរ សម្រេចចេញដីកាបញ្ជូនសំណុំរឿងទៅជំនុំជម្រះចៅក្រមស៊ើបសួរបញ្ជូនសំណុំរឿង និងភស្តុតាងដែលមានទៅកាន់ប្រធានតុលាការ ដើម្បីកំណត់ពេលសវនាការជំនុំជម្រះ[75]។ ចៅក្រមស៊ើបសួរអាចរក្សាជនជាប់ចោទឲ្យនៅជាប់ឃុំបណ្តោះអាសន្ន រហូតដល់ពេលចូលបង្ហាញខ្លួននៅមុខតុលាការ។ នៅក្នុងដីកាបញ្ជូនទៅពិនិត្យរឿងមូលត្រូវរៀបរាប់អំពីអំពើដែលត្រូវចោទប្រកាន់ និង ឈ្មោះបទល្មើសតាមច្បាប់។

**កថាខណ្ឌទី២ ដីកាលើកលែងការចោទប្រកាន់**

ប្រសិនបើចៅក្រមស៊ើបសួរយល់ឃើញថា អង្គហេតុដែលមាននៅក្នុងសំណុំរឿងមិនមែនជាបទល្មើសឧក្រិដ្ឋ ឬ បទមជ្ឈិម ឬ បទល្មើសលហុទេ ឬ ជនប្រព្រឹត្តបទល្មើសនៅតែគេមិនស្គាល់ ឬ ប្រសិនបើពុំមានបន្ទុកគ្រប់គ្រាន់ ដែលបញ្ជាក់ថាជនជាប់ចោទមានពិរុទ្ធភាពនោះចៅក្រមស៊ើបសួរនឹងសម្រេចលើកលែងការចោទប្រកាន់។ ការលើកលែងការចោទប្រកាន់ត្រូវមានមូលហេតុច្បាស់លាស់ និងត្រូវជូនដំណឹងទៅភាគីទាំងអស់ ដើម្បីឲ្យភាគីដែលមិនសុខចិត្តនឹងការសម្រេចនោះធ្វើការតវ៉ានៅសាលាឧទ្ធរណ៍។ លើសពីនេះទៅទៀត ចៅក្រមស៊ើបសួរអាចចេញដីកាលើកលែងចោទប្រកាន់ ក្នុងករណីបណ្តឹងអាជ្ញាផុតអាជ្ញាយុកាល និងមរណភាពនៃចារី។

---

[74] មាត្រា ២៣៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

[75] មាត្រា ២៥០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

សេចក្តីសម្រេចលើកលែងការចោទប្រកាន់មិនរលត់បណ្តឹងអាជ្ញាទេ ព្រោះប្រសិនបើការលើកលែងចោទប្រកាន់មានហេតុផលមកពីអវត្តមាននៃបន្ទុកគ្រប់គ្រាន់ប្រឆាំងនឹងជនត្រូវចោទ ឬមកពីការមិនស្គាល់ចារី ដូចច្នេះនៅពេលមានបន្ទុកថ្មីកើតឡើង គឺអនុញ្ញាតឲ្យបើកការស៊ើបសួរទៅលើអង្គហេតុនោះជាថ្មីម្តងទៀត។ ហេតុដូច្នេះ ដើមបណ្តឹងរដ្ឋប្បវេណីដែលមិនសុខចិត្តនឹងសេចក្តីសម្រេចលើកលែងចោទប្រកាន់នេះ អាចធ្វើការប្តឹងឧទ្ធរណ៍ចំពោះដីកានេះ។

# សេចក្តីសន្និដ្ឋាន
# និង
# អនុសាសន៍

# សេចក្តីសន្និដ្ឋាន

ក្រោយពីបានធ្វើការស្រាវជ្រាវយ៉ាងលំអិតទាក់ទងនឹងប្រធានបទស្តីពី "**តួនាទីរបស់ចៅក្រមស៊ើបសួរ**" រួចមក ពិតជាបានឆ្លុះបញ្ចាំងយ៉ាងច្បាស់ថា កិច្ចស៊ើបសួរត្រូវបានអនុវត្ត និង ដឹកនាំផ្ទាល់ដោយចៅក្រមស៊ើបសួរដើម្បីប្រមូលភស្តុតាងទាំងអស់ដែលពាក់ព័ន្ធ ដែលបញ្ជាក់ពីការពិតនៃអង្គហេតុព្រហ្មទណ្ឌចាប់តាំងពីការចាប់ផ្តើមស្រាវជ្រាវរហូតដល់បញ្ចប់ការស៊ើបសួរ។ ចំពោះបទល្មើសឧក្រិដ្ឋ ការបើកការស៊ើបសួរត្រូវធ្វើដោយខានពុំបាន ចំណែកឯបទល្មើសមជ្ឈិមវិញ ការស៊ើបសួរអាចធ្វើក៏បាន មិនធ្វើក៏បាន។ ប៉ុន្តែរាល់ការចូលរួមស្រាវជ្រាវរឿងក្តីព្រហ្មទណ្ឌរបស់ចៅក្រមស៊ើបសួរ ក្នុងដំណាក់កាលស៊ើបសួរត្រូវតែរក្សាការសម្ងាត់។ នៅក្នុងដំណាក់កាលស៊ើបសួរ ចៅក្រមមានតួនាទីបើកការស៊ើបសួរដើម្បីស្វែងរកការពិតទាំងភស្តុតាងដាក់បន្ទុក និង ភស្តុតាងដោះបន្ទុកដើម្បីផ្តល់ភាពយុត្តិធម៌ដល់ជនល្មើស និងជនរងគ្រោះ។ ម្យ៉ាងវិញទៀត កិច្ចស្រាវជ្រាវនេះ មានដូចជាកិច្ចស្រាវជ្រាវចំពោះអង្គហេតុ និងកិច្ចស្រាវជ្រាវទៅនឹងបុគ្គលិកលក្ខណៈរបស់ជនត្រូវចោទ។

ចំពោះដំណាក់កាលបើកការស៊ើបសួរ វិធីសាស្ត្រស្រាវជ្រាវរបស់ចៅក្រមស៊ើបសួរ ដើម្បីស្វែងរកការពិតឱ្យបានច្បាស់ក្នុងនោះរួមមានដូចជា ការជូនដំណឹងអំពីការដាក់ឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យ ការសួរចម្លើយជនត្រូវចោទ ការស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី ការស្តាប់ចម្លើយសាក្សី ការឆែកឆេរ និងការចាប់យកវត្ថុតាង ការធ្វើកុសលវិច័យ ការស្តាប់ទូរស័ព្ទ។ ក្នុងនីតិវិធីស៊ើបសួរ ព្រះរាជអាជ្ញា ជនត្រូវចោទ និងដើមបណ្តឹងរដ្ឋប្បវេណី អាចធ្វើការស្នើរសុំបំពេញកិច្ចដល់ចៅក្រមស៊ើបសួរណាមួយដែលយល់ឃើញថាមានប្រយោជន៍ដើម្បីបង្ហាញពីការពិត។ ប្រសិនបើនៅការបំពេញកិច្ចរបស់ខ្លួន មានមូលហេតុមួយចំនួនដែលជាហេតុបណ្តាលឱចៅក្រមស៊ើបសួរមិនអាចបំពេញតួនាទីរបស់ខ្លួនបាន ដូចជាបញ្ហាជម្ងឺ ឬ មានធុរៈចាំបាច់ផ្សេងៗ ការធ្វើដំណើរផ្លូវឆ្ងាយចៅក្រមស៊ើបសួរមានសិទ្ធិពេញលេញសម្រេចចេញដីកាចាត់ឱ្យស៊ើបសួរជំនួស។ ដីកាចាត់ឱ្យស៊ើបសួរជំនួសនេះ គឺជាការសុំរបស់ចៅក្រមស៊ើបសួរដើម្បីឲ្យចៅក្រមស៊ើបសួរផ្សេង ឬ មន្ត្រីនគរបាលយុត្តិធម៌ ឬ អង្គភាពនគរបាលយុត្តិធម៌បំពេញកិច្ចមួយចំនួនតាមរយៈដីកាចាត់ឲ្យស៊ើបសួរជំនួស។ ហើយក្នុងដីកាចាត់ឱ្យស៊ើបសួរជំនួស ត្រូវបញ្ជាក់អំពីប្រភេទនៃកិច្ចដែលត្រូវធ្វើ ដែលកិច្ចនោះត្រូវតែមានទំនាក់ទំនងដោយផ្ទាល់ជាមួយបទល្មើសដែលបានចោទប្រកាន់។

ចំពោះវិធានការនិរន្តរាយ សំដៅដល់ការចេញដីកាចាប់ខ្លួន ការចោទប្រកាន់ ការឃុំខ្លួន ឬការដាក់ឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការដោយចៅក្រមស៊ើបសួរ។ វិធានការនេះត្រូវបាន ចៅក្រមស៊ើបសួរអនុវត្តដើម្បីជាការងាយស្រួលស្វែងរកភស្តុតាងពិតប្រាកដសម្រាប់ដាក់បន្ទុក និងដោះបន្ទុកនៅក្នុងរឿងក្តីព្រហ្មទណ្ឌ។ វិធានការនេះ ចៅក្រមស៊ើបសួរអាចចេញដីកាបង្គាប់ឲ្យ

ចូលខ្លួន ដីកាបង្គាប់ឲ្យនាំខ្លួន ដីកាបង្គាប់ឲ្យចាប់ខ្លួន និងដីកាបង្គាប់ឲ្យឃុំខ្លួន។ ដោយកម្មវត្ថុនៃដីកាបង្គាប់ឲ្យចូលខ្លួន គឺដើម្បីបញ្ជូនដល់បុគ្គលណាម្នាក់ ឬ ច្រើននាក់ឲ្យចូលទៅបង្ហាញខ្លួននៅចំពោះមុខចៅក្រមស៊ើបសួរ។ ប្រសិនបើជននោះមិនបានចូលខ្លួនតាមដីកាបង្គាប់ឲ្យចូលខ្លួនទេ ហេតុនេះចៅក្រមស៊ើបសួរអាចចេញដីកាបង្គាប់ឱ្យនាំខ្លួន។ ក្នុងករណីជនត្រូវចោទរត់គេចខ្លួន ចៅក្រមស៊ើបសួរនឹងចេញដីកាបង្គាប់ឲ្យចាប់ខ្លួនដែលជាបញ្ជាបង្គាប់ឲ្យកងកម្លាំងសាធារណៈទាំងអស់ស្រាវជ្រាវរកចាប់ជនត្រូវចោទមកចំពោះមុខចៅក្រមស៊ើបសួរ។ ហើយចៅក្រមស៊ើបសួរ អាចចេញដីកាបង្គាប់ឲ្យឃុំខ្លួនបាន ដែលដីកានេះគឺបញ្ជាដល់ប្រធានពន្ធនាគារ ឬ មណ្ឌលឃុំខ្លួនទទួល និង ឃុំខ្លួនជនត្រូវចោទ។ ចៅក្រមអាចចេញដីកាបង្គាប់ឲ្យឃុំខ្លួនបានលុះត្រាតែបន្ទាប់ពីចេញដីកាសម្រេចឲ្យឃុំខ្លួនបណ្ដោះអាសន្ន។

បន្ទាប់ពីវិធានការនិរន្តរាយត្រូវបានអនុវត្ត ចៅក្រមស៊ើបសួរមានសិទ្ធិពេញទីក្នុងការកំណត់សិទ្ធិជនត្រូវចោទក្នុងដំណាក់កាលស៊ើបសួររកការពិត។ ការកំណត់សិទ្ធិនេះដែរ ចៅក្រមស៊ើបសួរអាចសម្រេចចិត្តឃុំខ្លួនជននោះបណ្ដោះអាសន្ន ឬ ដាក់ឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ ឬ ធានាជនត្រូវចោទឲ្យនៅក្រៅឃុំ។ ប៉ុន្តែការអនុវត្តនីតិវិធីនេះ ចៅក្រមស៊ើបសួរត្រូវគោរពនូវសិទ្ធិមនុស្ស និង អាយុរបស់បុគ្គល ហើយត្រូវពិនិត្យមើលប្រភេទនៃបទល្មើសដើម្បីកំណត់សិទ្ធិ។

បើចៅក្រមស៊ើបសួរ យល់ឃើញថាដំណាក់កាលស្រាវជ្រាវរបស់ខ្លួនមានលក្ខណៈគ្រប់គ្រាន់សមស្របសម្រាប់បញ្ចប់ នោះចៅក្រមនឹងធ្វើការបិទការស៊ើបសួរដើម្បីបិទសំណុំរឿងក្រោមកិច្ចមួយហៅថាដីកាដោះស្រាយ។ តាមរយៈដីកានោះ អាចជាដីកាបញ្ជូនទៅជំនុំជម្រះ ឬ ដីកាលើកលែងការចោទប្រកាន់។

# អនុសាសន៍

ក្នុងនាមយើងជានិស្សិតបញ្ចប់ថ្នាក់បរិញ្ញាត្រនីតិសាស្ត្រ យើងយល់ឃើញថាដើម្បីបង្ការបទល្មើស និងផ្តល់ភាពយុត្តិធម៌ដល់ជនល្មើស និង ជនរងគ្រោះ ក្នុងដំណាក់កាលស៊ើបសួរដែលអនុវត្តដោយចៅក្រមស៊ើបសួរ ក៏ដូចជាការធានាការអនុវត្តក្រមនីតិវិធីព្រហ្មទណ្ឌថ្មីនេះ ឱ្យមានប្រសិទ្ធិភាព រដ្ឋគួរតែពង្រឹងកត្តាមួយចំនួនដូចខាងក្រោមនេះ ៖

- ត្រូវបន្ត និងបង្កើនការផ្សព្វផ្សាយក្រមនីតិវិធីព្រហ្មទណ្ឌថ្មីឲ្យបានទូលំទូលាយ ដល់មជ្ឈដ្ឋានទូទៅនិងទូទាំងប្រទេស។
- ជ្រើសរើសមន្ត្រីតុលាការដែលមានសមត្ថភាពពិតប្រាកដ និងឲ្យបានគ្រប់គ្រាន់តាមតម្រូវការជាក់ស្តែង។
- ត្រូវពង្រឹងការអនុវត្តក្រមសីលធម៌វិជ្ជាជីវៈតាមរយៈការឃ្លាំមើល និងដាក់ពិន័យរាល់ការបំពានក្រមសីលធម៌ដល់ចៅក្រម ព្រះរាជអាជ្ញា និងក្រឡាបញ្ជី ឬមេធាវីអគតិ។
- ត្រូវគោរពគោលការណ៍សិទ្ធិមនុស្សជាមូលដ្ឋាន ជាពិសេសត្រូវយកចិត្តទុកដាក់លើការគោរពសិទ្ធិទទួលបានការជំនុំជម្រះតាមបែបយុត្តិធម៌ថ្នាក់ជាតិ និង អន្តរជាតិ។
- សូមឲ្យចៅក្រមស៊ើបសួរគោរពឲ្យបានមត់ចត់នូវការហាមឃាត់ទាំងឡាយដែលមានចែងក្នុងក្រមនីតិវិធីព្រហ្មទណ្ឌនេះ ពិសេសគឺរក្សាការសម្ងាត់។
- សូមឱ្យចៅក្រមស៊ើបសួរ គោរពឱ្យបានហ្មត់ចត់នូវគោលការណ៍ទាំងឡាយណាដែលចែងដោយក្រមនីតិវិធីព្រហ្មទណ្ឌ ចំពោះការបំពេញបេសកកម្មរបស់ខ្លួនក្នុងដំណាក់កាលទាំងឡាយនៃនីតិវិធីព្រហ្មទណ្ឌ ព្រោះបើមានតែច្បាប់ ផ្ទុយទៅវិញគ្មានការអនុវត្តឱ្យបានល្អ នោះវានឹងបណ្តាលឲ្យមានភាពអនាធិបតេយ្យ។

ក្រៅពីនេះ គួរពន្លឿននីតិវិធី បានន័យថាចៅក្រមស៊ើបសួរគួរផ្តល់អទិភាពចំពោះសំណុំរឿងព្រហ្មទណ្ឌទាំងឡាយណាដែលជនត្រូវចោទ ដែលនៅក្នុងការឃុំខ្លួនបណ្តោះអាសន្នជាពិសេស គឺសុំណុំរឿងដែលមានជនត្រូវចោទជាអនីតិជនជាដើម។

## ឯកសារពិគ្រោះ

- រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣។
- ក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩។
- ក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៩។
- សេចក្តីសម្រេចលេខ០៤កយ.សសរ/១២ ចុះថ្ងៃទី២០ ខែមេសា ឆ្នាំ២០១២ ស្តីពីការទទួលមន្ត្រីជំនាញក្នុងការធ្វើកោសលវិច័យគ្រឿងញៀន និងសារធាតុញៀន។
- ដីកាសម្រេចបែងចែករឿងក្តីព្រហ្មទណ្ឌ ឆ្នាំ២០១២ លេខ ២២៣៨ រប.៩២១.១១ ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០១១របស់សាលាដំបូងរាជធានីភ្នំពេញ។
- សៀវភៅនីតិវិធីសង្ខេប រដ្ឋប្បវេណី និងព្រហ្មទណ្ឌ បោះពុម្ភលើកទី១ ក្នុងឆ្នាំ២០០៩ និង លើកទី២ ក្នុងឆ្នាំ២០១១ (សម្រាប់អនុវត្តនៅតាមសាលាជម្រះក្តីនានា) ដែលសេសេរឡើងដោយ លោកសាស្ត្រាចារ្យ **ជួន សុរាសី** និងចៅក្រមសាលាដំបូងរាជធានីភ្នំពេញ។
- វចនានុក្រមខ្មែរភាគ១-ភាគ២ របស់សម្តេចមហាសុមេធាធិបតី **ជួន ណាត** ។
- វីឌីអូឃ្លិបស្តីពី "ការផ្សព្វផ្សាយក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៩" ។

# ឧបសម្ព័ន

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងរាជធានីភ្នំពេញ**

លេខ: ២៧៣៨ / បេ.៩២១.១១

រាជធានីភ្នំពេញ, ថ្ងៃទី...០..ខែ ធ្នូ ឆ្នាំ ២០១១

## ដីកាសំរេច

## បែងចែករឿងក្ត[redacted]ឆ្នាំ ២០១២

### យើង ជីវ កេង ប្រធានសាលាដំបូងរាជធានីភ្នំពេញ

-បានឃើញមាត្រា ៥១,៥២,៥៣ និង ២៤៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ដែលប្រកាសឲ្យប្រើតាមព្រះរាជក្រម លេខ នស/រកម/០៨០៧/០២៤ ចុះថ្ងៃទី ១០-០៨-២០០៧។

-បានឃើញស្ថានភាពចាំបាច់ និងជាក់ស្តែងនៅសាលាដំបូងរាជធានីភ្នំពេញ ។

### សំ រេ ច

**ប្រការ ១** : បែងចែកសំណុំរឿងព្រហ្មទណ្ឌស៊ើបសួរនៅសាលាដំបូងរាជធានីភ្នំពេញឲ្យទៅក្រមស៊ើបសួរម្នាក់ៗចាត់ការតាមលំដាប់ លេខរៀងដូចខាងក្រោម:

| | | | |
|---|---|---|---|
| លំដាប់លេខរៀងទី ១ : | ឯកឧត្តម | ជីវ | កេង |
| លំដាប់លេខរៀងទី ២ : | លោក | អឿង | សៀង |
| លំដាប់លេខរៀងទី ៣ : | លោកស្រី | សែម | សក្តិឥទ្ធល្លា |
| លំដាប់លេខរៀងទី ៤ : | លោក | សេង | នាង |
| លំដាប់លេខរៀងទី ៥ : | លោក | សួស | សំអាត |
| លំដាប់លេខរៀងទី ៦ : | លោក | លាង | សំណាត់ |
| លំដាប់លេខរៀងទី ៧ : | លោក | ឌុច | គីមសន |
| លំដាប់លេខរៀងទី ៨ : | លោក | យូ | ប៊ុនណា |
| លំដាប់លេខរៀងទី ៩ : | លោក | ម៉ួន | ស្ទុរាសី |
| លំដាប់លេខរៀងទី ១០: | លោក | ភោ | ចណ្ណី |
| លំដាប់លេខរៀងទី ១១: | លោកស្រី | ចាំង | ស៊ីណាត |
| លំដាប់លេខរៀងទី ១២: | លោក | តែ | សំអាង |
| លំដាប់លេខរៀងទី ១៣: | លោក | នូ | ពៅស៊ួន |
| លំដាប់លេខរៀងទី ១៤: | លោក | កែង | មុនី |



អាសយដ្ឋាន: អាគារលេខ ២៥-២៧ ផ្លូវលេខ ២១៧.២១៣ សង្កាត់វាលវង់ ខណ្ឌ ៧ មករា, ភ្នំពេញ ទូរសារ-ទូរស័ព្ទ: (៨៥៥)-២៣ ៨៨៥ ៩៦១ / ២៣ ៨៨៥ ៩៦២
Adress : #25-27, Street 217-213, Sangkat Vealvong, Khan 7makara, Phnom Penh, Cambodia. Fax-Phone : (855) 23 885 961 / 23 885 962

| | | | |
|---|---|---|---|
| លំដាប់លេខរៀងទី ១៥: | លោក | អ៊ុំ | ម៉ាចរៈ |
| លំដាប់លេខរៀងទី ១៦: | លោក | ជា | សុខហៀង |
| លំដាប់លេខរៀងទី ១៧: | លោកជំទាវ | ពេជ | ម៉ារីន |
| លំដាប់លេខរៀងទី ១៨: | លោកជំទាវ | យ៉េត | ម៉ូលីន |
| លំដាប់លេខរៀងទី ១៩: | លោក | លី | លីបម៉េង |
| លំដាប់លេខរៀងទី ២០: | លោក | ឆែ | ធីរៈ |
| លំដាប់លេខរៀងទី ២១: | លោកជំទាវ | គីម | ដានី |
| លំដាប់លេខរៀងទី ២២: | លោក | លឹម | មគរន្ធ |
| លំដាប់លេខរៀងទី ២៣: | លោក | ស៊ិន | ខិសាល |
| លំដាប់លេខរៀងទី ២៤: | លោក | ហេង | សុខណា |
| លំដាប់លេខរៀងទី ២៥: | លោក | គីម | វិត្ថុណារិន |

<u>**ប្រការ ២**</u> : របៀបបែងចែកលំដាប់សំណុំរឿងត្រូវតែម្តងមួយរឿងតាមលំដាប់លេខរៀងទី ១ ចុះមកលេខរៀងទី ២៥ ហើយវិលទៅលេខរៀងទី ១ វិញ ។ លេខរៀងសំណុំរឿងនិងលេខរៀងលំដាប់ចៅក្រមស៊ើបសួរ មិនអាចត្រួតគ្នាឬផ្លោះលេខទេ លើកលែងតែ :

-ចៅក្រមណាម្នាក់ដែលមានការងារច្រើនពេក មានធុរៈ ឈប់ ឬ ទៅសាលាដំបូងផ្សេងឬសំរាកក្នុងរយៈពេលវែងជាអាទិ៍ដែលត្រូវបែងចែកឲ្យចៅក្រមលេខរៀងបន្ទាប់ចាត់ការជំនួស ។

-សំណុំរឿងច្រើនដែលមានជនល្មើសម្នាក់ឬច្រើននាក់ រួមគ្នាប្រព្រឹត្តបទល្មើសច្រើនដែលមន្ត្រីនគរបាលយុត្តិធម៌ ឬតំណាងអយ្យការបានបំបែកសំណុំរឿងត្រូវចាត់ឲ្យចៅក្រមតែម្នាក់ស៊ើបសួរ ។

-ចំពោះចៅក្រមណាដែលមានសំណុំរឿងលើសពីពីរដងនៃសំណុំរឿងរបស់ចៅក្រមដែលមានសំណុំរឿងតិចបំផុត មិនត្រូវបែងចែកទៀតទេ រហូតដល់សំណុំរឿងរបស់ចៅក្រមនោះចុះមកនៅត្រឹមប្រហាក់ប្រហែល ចៅក្រមដែលមានសំណុំរឿងតិចបំផុត ។

-សំណុំរឿងស៊ើបសួរដែលត្រូវបានចោទប្រកាន់ និងបញ្ជូនខ្លួនជនត្រូវចោទមកជាមួយផងបើប៉ះលើវេនចៅក្រមណាដែលអវត្តមានពេលសំណុំរឿងមកដល់ ត្រូវផ្លោះទៅលេខរៀងចៅក្រមបន្ទាប់ដើម្បីកុំឲ្យការឃាត់ខ្លួនហួសរយៈពេលកំណត់ ។

-ចៅក្រមណាដែលត្រូវយាមប្រចាំការថ្ងៃឈប់ និងថ្ងៃបុណ្យត្រូវបានចាត់ឲ្យបំពេញនីតិវិធីស៊ើបសួរជំនួសចៅក្រមដែលត្រូវទទួលតាមលំដាប់លេខរៀង ហើយត្រូវប្រគល់សំណុំរឿងនេះ ជូនចៅក្រមតាមលេខរៀងវិញនៅថ្ងៃចូលធ្វើការដំបូង ។

**ប្រការ ៣** : ចាត់តាំងក្រុមប្រឹក្សាជំនុំជំរះចំនួន ៦ ក្រុមដើម្បីជំនុំជំរះនូវរឿងព្រហ្មទណ្ឌបទឧក្រិដ្ឋដូចខាងក្រោម:

-ក្រុមប្រឹក្សាជំនុំជំរះទី ១ :

| | | | |
|---|---|---|---|
| ១-លោក | **អឿច** | **សៀច** | ជាប្រធាន |
| ២-លោក | **ហេច** | **សុខណា** | ជាសមាជិក |
| ៣-លោក | **ជា** | **សុខហៀច** | ជាសមាជិក |

-ក្រុមប្រឹក្សាជំនុំជំរះទី ២ :

| | | | |
|---|---|---|---|
| ១-លោក | **សួស** | **សំអាត** | ជាប្រធាន |
| ២-លោក | **លី** | **លីបម៉េង** | ជាសមាជិក |
| ៣-លោក | **កែវ** | **មុនី** | ជាសមាជិក |

-ក្រុមប្រឹក្សាជំនុំជំរះទី ៣ :

| | | | |
|---|---|---|---|
| ១-លោក | **កោ** | **វណ្ណី** | ជាប្រធាន |
| ២-លោក | **យូ** | **ប៊ុនណា** | ជាសមាជិក |
| ៣-លោក | **តូ** | **ពៅស៊ុន** | ជាសមាជិក |

-ក្រុមប្រឹក្សាជំនុំជំរះទី ៤ :

| | | | |
|---|---|---|---|
| ១-លោក | **ឌុច** | **គមសន** | ជាប្រធាន |
| ២-លោក | **សេច** | **ឆាច** | ជាសមាជិក |
| ៣-លោក | **តែ** | **សំអាច** | ជាសមាជិក |

-ក្រុមប្រឹក្សាជំនុំជំរះទី ៥ :

| | | | |
|---|---|---|---|
| ១-លោកស្រី | **ចាំង** | **ស៊ីណាត** | ជាប្រធាន |
| ២-លោកស្រី | **សែម** | **សក្កុទ្បា** | ជាសមាជិក |
| ៣-លោក | **លាច** | **សំណាត់** | ជាសមាជិក |

-ក្រុមប្រឹក្សាជំនុំជំរះទី ៦ :

| | | | |
|---|---|---|---|
| ១-លោក | **ស៊ិន** | **ចសារឿ** | ជាប្រធាន |
| ២-លោក | **លឹម** | **មករដ្ឋ** | ជាសមាជិក |
| ៣-លោកជំទាវ | **នម** | **ដានី** | ជាសមាជិក |

**ប្រការ ៤** : ចៅក្រមដែលពុំមានឈ្មោះក្នុងក្រុមប្រឹក្សាជំនុំជំរះ ហើយដែលត្រូវមានរឿងព្រហ្មទណ្ឌបទឧក្រិដ្ឋត្រូវវិនិច្ឆ័យ និងជំនុំជំរះដោយក្រុមប្រឹក្សា ត្រូវជំនួសដូចតទៅ៖

ក-លោកជំទាវ **ពេជ ម៉ារីន** ត្រូវជំនួសលោក **លី លីបម៉េង** ក្នុងក្រុមប្រឹក្សាជំនុំជំរះទី ២ ក្នុងនាមជាសមាជិក។

ខ-លោកជំទាវ **យ៉េត ម៉ូលីន** ត្រូវជំនួសលោក **តូ ពៅស៊ុន** ក្នុងក្រុមប្រឹក្សាជំនុំជំរះទី ៣ ក្នុងនាមជាសមាជិក ។

**ប្រការ ៥** : ចៅក្រមកម្មសិក្សាត្រូវចាត់ឲ្យចូលជំនុំជំរះរឿងព្រហ្មទណ្ឌបទឧក្រិដ្ឋក្នុងក្រុមប្រឹក្សាជំនុំជំរះ របស់សាលាដំបូងរាជធានីភ្នំពេញ តាមលំដាប់ជំនួសដូចខាងក្រោម ៖

ក-លោក **ឆែ ទីរៈ** ត្រូវជំនួសលោក **តែ សំអាច** ក្នុងក្រុមប្រឹក្សាជំនុំជំរះទី ៤ ក្នុងនាមជាសមាជិក ។

ខ-លោក **អ៊ីចាំងទរៈ** ត្រូវជំនួសលោក **លាច សំណាត់** ក្នុងក្រុមប្រឹក្សាជំនុំជំរះទី ៥ ក្នុងនាមជាសមាជិក។

គ-លោក [illegible] ត្រូវជំនួសលោកជំទាវ **នម ដានី** ក្នុងក្រុមប្រឹក្សាជំនុំជំរះទី ៦ ក្នុងនាមជាសមាជិក។

ឃ-លោក **គីម វិន្ទនារិន** ត្រូវជំនួសលោក **ជា សុខហៀច** ក្នុងក្រុមប្រឹក្សាជំនុំជំរះទី ១ ក្នុងនាមជាសមាជិក ។

**ប្រការ ៦** : សំណុំរឿងឧក្រិដ្ឋទាំងអស់ដែលជូនទៅជំនុំជំរះត្រូវចាត់តាំងក្រុមប្រឹក្សាជំនុំជំរះតាមលំដាប់លេខរៀង ពីលេខរៀងទី ១ ដល់ទី ៦ តាមចំនួនសំណុំរឿងដែលក្រុមប្រឹក្សានិមួយៗអាចជំនុំជំរះបានតាមកាលបរិច្ឆេទដែលបានចាត់តាំងបែងចែករួចហើយតាមតារាងចុះថ្ងៃទី ១៥ ខែ ធ្នូ ឆ្នាំ ២០១១ (សំរាប់សវនាការឆ្នាំ ២០១២) លើកលែងតែក្រុមប្រឹក្សាណាមួយមានសំណុំរឿងច្រើនលើសពី ២ដងធៀបនឹងក្រុមប្រឹក្សាដែលមានសំណុំរឿងតិចជាងគេ ត្រូវផ្លោះលេខរៀង ។

**ប្រការ ៧** : ក្នុងករណីដែលប្រធានក្រុម ឬសមាជិកក្រុមប្រឹក្សាជំនុំជំរះណាម្នាក់មិនអាចចូលរួមជំនុំជំរះបានដោយមូលហេតុ ឈឺ មានធុរៈ ផ្លាស់ចេញ សំរាក ដកខ្លួន ត្រូវបានប្តឹងជំទាស់ ឬដកហូតឬជាចៅក្រមស៊ើបសួរហើយនោះ ប្រធានក្រុមប្រឹក្សា ឬសមាជិកក្រុមប្រឹក្សាណាម្នាក់ដែលនៅក្នុងក្រុមប្រឹក្សាជាប់លំដាប់គ្នា ជំនួសតាមលំដាប់លេខរៀងក្នុងក្រុមប្រឹក្សាទាំងពីរនោះ ។

**ប្រការ ៨** : ប្រធានសាលាដំបូងអាចជំនួសប្រធាន ឬសមាជិកក្រុមប្រឹក្សាជំនុំជំរះណាមួយដែលមិនអាចជំនុំជំរះបានក្នុងនាមជាប្រធានក្រុមប្រឹក្សាជំនុំជំរះ ។

**ប្រការ ៩** : សំណុំរឿងព្រហ្មទណ្ឌដែលត្រូវជំនុំជំរះដោយចៅក្រមទោល ត្រូវយកលំដាប់លេខរៀងចៅក្រមជំនុំជំរះតាមលំដាប់លេខរៀងចៅក្រមស៊ើបសួរដែលមានចែងក្នុងប្រការ១ នៃដីកាសម្រេចនេះ លើកលែងតែ:

-លំដាប់លេខរៀងឯកឧត្តម **ខឹម គេង** ប្រធានសាលាដំបូង ក្នុងកាលៈទេសៈដែលមានការងារមមាញឹកច្រើនពេក ។

-កាលណាវេនចៅក្រមជំនុំជំរះ ប៉ះលើចៅក្រមស៊ើបសួរ ចៅក្រមដកខ្លួន ចៅក្រមត្រូវដកហូត ឬត្រូវបានប្តឹងជំទាស់ ឈឺ មានធុរៈ ផ្ទេរចេញ ឈប់សំរាករយៈពេលយូរ ឬចៅក្រមមានសំណុំរឿងច្រើនលើសពី ២ដង នៃសំណុំរឿងចៅក្រមដែលមានសំណុំរឿងតិចជាងគេត្រូវផ្លោះទៅចៅក្រមលំដាប់លេខរៀងបន្ទាប់ ។

-ចៅក្រមដែលត្រូវវេនយាមថ្ងៃឈប់ ឬថ្ងៃបុណ្យត្រូវទទួលបន្ទុកជំនុំជំរះរឿងដែលនាំមកបង្ហាញខ្លួនភ្លាម (តាមមាត្រា ៤៧នៃក្រមនីតិវិធីព្រហ្មទណ្ឌ) លើកលែងតែចៅក្រមកម្មសិក្សាដែលមិនអាចជំនុំជំរះបាន ត្រូវជូនដំណឹងទៅក្រឡាបញ្ជីដែលកាន់សៀវភៅរឿង ឲ្យជំរាបចៅក្រមក្នុងលំដាប់វេនជំនុំជំរះ ឲ្យមកទទួលចាត់ការរឿងនេះភ្លាម ។ ក្រៅពីថ្ងៃឈប់សំរាក ថ្ងៃបុណ្យ ចំពោះរឿងដែលនាំមកបង្ហាញខ្លួនភ្លាម បើចំលើវេនចៅក្រមដែលអវត្តមាន ត្រូវផ្លោះទៅវេនចៅក្រមដែលនៅលេខរៀងបន្ទាប់ដើម្បីកុំឲ្យការឃាត់ខ្លួនលើសរយៈពេលកំណត់ ។

-បើវេនយាមចំលើចៅក្រមដែលមានធុរៈចាំបាច់មិនអាចមកយាមបាន ចៅក្រមសាម៉ីត្រូវជូនដំណឹងជាមុនដល់ប្រធានសាលាដំបូង ដើម្បីសំរបសំរួលឲ្យចៅក្រមណាម្នាក់ដែលនៅលេខរៀងបន្តបន្ទាប់មកយាមជំនួស ហើយចៅក្រមដែលអវត្តមាននេះ ត្រូវយាមសងចៅក្រមជំនួសវិញ ។

**ប្រការ ១០** : សំណុំរឿងព្រហ្មទណ្ឌទាំងអស់ដែលប្រធានសាលាដំបូងបានចាត់តាំងចៅក្រមជំនុំជំរះរួចហើយមុនក្រមនីតិវិធីព្រហ្មទណ្ឌចូលជាធរមានត្រូវបែងចែកដូចខាងក្រោម:

ក-<u>រឿងព្រហ្មទណ្ឌដែលមិនមែនជាបទឧក្រិដ្ឋ</u>:

ត្រូវជំនុំជំរះដោយចៅក្រមទោលតាមការចាត់តាំងរួចហើយ ។

ខ-រឿងព្រហ្មទណ្ឌដែលជាបទឧក្រិដ្ឋ:

ចៅក្រមដែលបានទទួលសំណុំរឿងរួចហើយត្រូវដាក់សំណុំរឿងជូនក្រុមប្រឹក្សាជំនុំជំរះដែលខ្លួនជាសមាជិក ដើម្បីជំនុំជំរះ ។

គ-កាលបរិច្ឆេទនៃការជំនុំជំរះ :

ត្រូវយកកាលបរិច្ឆេទសវនាការឆ្នាំ ២០១២ ដែលប្រធានសាលាដំបូងបានចាត់តាំងតាមតារាងចុះថ្ងៃទី ១៥ ខែ ធ្នូ ឆ្នាំ ២០១១ ។

ប្រការ ១១ : សំណុំរឿងដែលត្រូវជំនុំជំរះដោយចៅក្រមទោល ឬដោយក្រុមប្រឹក្សា បើកាលណាសំណុំរឿងនោះមានអង្គហេតុតែមួយ ហើយមានជនល្មើសម្នាក់ ឬច្រើននាក់ និងដើមបណ្តឹងរដ្ឋប្បវេណីម្នាក់ ឬច្រើននាក់ ដែលត្រូវបំបែកជាច្រើនសំណុំរឿង ត្រូវចាត់ឲ្យចៅក្រមទោលតែម្នាក់ ឬក្រុមប្រឹក្សាតែមួយតាមករណីបទល្មើសមជ្ឈិម ឬឧក្រិដ្ឋ ។

ប្រការ ១២ : ក្នុងករណីដែលចៅក្រមផ្ទេរចេញ ឬផ្ទេរចូលក្រោយដីកាសំរេចនេះចូលជាធរមាន ប្រធានសាលាដំបូងអាចកែសំរួលលំដាប់លេខរៀងចៅក្រមស៊ើបសួរ និងសមាសភាពក្រុមប្រឹក្សាជំនុំជំរះតាមដីកាសម្រេចមួយថ្មី ។

ប្រការ ១៣ : លោកអនុប្រធានសាលាដំបូង លោកជំទាវ លោក-លោកស្រីចៅក្រម និងក្រឡាបញ្ជីត្រូវអនុវត្តតាមដីកាសំរេចនេះឲ្យមានប្រសិទ្ធភាព ។

ប្រការ ១៤ : ដីកាសំរេចនេះ មានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃទី ០១ ខែ មករា ឆ្នាំ ២០១២ រហូតដល់ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១២ ។

ប្រធានសាលាដំបូង

ជឹង កេង

សូមចម្លងជូន
-ឯកឧត្តមប្រធានតុលាការកំពូល
-ឯកឧត្តមរដ្ឋមន្ត្រីក្រសួងយុត្តិធម៌

សូមគោរពជូនជ្រាប
-អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលារាជធានីភ្នំពេញ
ចូល លេខ ... ថ្ងៃទី ... ខែ ... ឆ្នាំ ... ម៉ោង ... នាទី

ក្រសួងយុត្តិធម៌

លេខ: ០៤៤ គយ.សសន/១២

រាជធានីភ្នំពេញ ថ្ងៃទី២០ ខែមេសា ឆ្នាំ២០១២

# សេចក្ដីសម្រេច
## ស្ដីពី
## ការទទួលស្គាល់មន្ត្រីជំនាញ ក្នុងការធ្វើកោសល្យវិច័យគ្រឿងញៀន និងសារធាតុញៀន

## រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៤ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលបានប្រកាសឱ្យប្រើច្បាប់ ស្ដីពីការបង្កើតក្រសួងយុត្តិធម៌
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៧/០១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៧ ដែលបានប្រកាសឱ្យប្រើច្បាប់ ស្ដីពីការត្រួតពិនិត្យគ្រឿងញៀនកម្ពុជា
- យោងលិខិតលេខ ០៧៨/ល.ស.អ.ជ.ប.គ.ញ ចុះថ្ងៃទី ០៦ ខែ មីនា ឆ្នាំ ២០១២ របស់អគ្គលេខាធិការដ្ឋាន នៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន។

## ស ម្រេ ច

**ប្រការ១:**

ត្រូវបានទទួលស្គាល់ជាអ្នកជំនាញធ្វើកោសល្យវិច័យគ្រឿងញៀន និងសារធាតុញៀនដល់មន្ត្រីដែលកំពុងបំពេញការងារនៅមន្ទីរពិសោធន៍គ្រឿងញៀននៃអគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ ចំនួន ០៤ រូប ដែលមានរាយនាមដូចខាងក្រោម:

១- ឯកឧត្តម ឧត្តមសេនីយ៍ទោ វេជ្ជបណ្ឌិត មាស ទរិទ្ធ ប្រធានមន្ទីរពិសោធន៍គ្រឿងញៀន នៃអគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន

២- លោកស្រី វិស្វករគីមី ឈឹម សិទ្ធិបុណ្យរិទ្ធ អនុប្រធានមន្ទីរពិសោធន៍គ្រឿងញៀន

នៃអគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន

៣- លោក វេជ្ជបណ្ឌិត ជុន ហុចពាន ប្រធានការិយាល័យបច្ចេកទេស មន្ទីរពិសោធន៍គ្រឿងញៀន នៃអគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន

៤- លោក ឱសថការីឧត្តម ទែត មោនីនោ មន្ត្រីមន្ទីរពិសោធន៍គ្រឿងញៀន នៃអគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ។

**ប្រការ២:**

ការទទួលស្គាល់នេះ ត្រូវបានផ្តល់សម្រាប់រយៈពេល ១ ឆ្នាំ ហើយអាចបន្តជាថ្មីបាន តាមការស្នើសុំ ។ ការស្នើសុំបន្តជាថ្មី ត្រូវធ្វើយ៉ាងយឺតបំផុត ១ ខែ មុនអស់សុពលភាព នៃការទទួលស្គាល់ ។

ការទទួលស្គាល់នេះ អាចដកហូតវិញ ក្នុងករណីសាមីខ្លួនមិនបានបំពេញល័ក្ខខ័ណ្ឌសមត្ថភាពវិជ្ជាជីវៈសំភារៈបច្ចេកទេសការងារ អព្យាក្រឹត្យភាព និងសីលធម៌ ដូចដែលមានកំណត់ដោយស្មារតីនៃកិច្ចប្រជុំអន្តរក្រសួង ថ្ងៃទី ២៣ ខែ កញ្ញា ឆ្នាំ ២០០២ ស្តីពីការទទួលស្គាល់អ្នកជំនាញធ្វើកោសល្យវិច័យគ្រឿងញៀន និងសារធាតុញៀន ។

**ប្រការ៣:**

ឯកឧត្តម លោក លោកស្រី ដែលមានឈ្មោះក្នុងប្រការ ១ ត្រូវអនុវត្តសេចក្តីសំរេចនេះឱ្យមានប្រសិទ្ធិភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

[illegible]

[illegible]

**ចម្លងជូន**

- អគ្គលេខាធិកាដ្ឋាន អ.ជ.ប.គ.ញ
- សាលាជំរះក្តីគ្រប់ជាន់ថ្នាក់

«ដើម្បីជូនជ្រាប»

- សាមីខ្លួន (ដើម្បីអនុវត្ត)
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

អយ្យការ

អមសាលាដំបូងរាជធានីភ្នំពេញ

សំណុំរឿងព្រហ្មទណ្ឌលេខ: .............

ចុះថ្ងៃទី ១១ ខែ មិថុនា ឆ្នាំ ២០១២

លេ.........................អ.យ.

# ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ

យើង ឆ តំណាងអយ្យការ អមសាលាដំបូងរាជធានីភ្នំពេញ

-បានឃើញ របាយការណ៍សំយោគលេខ: ........................... រ.ប.ក ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០១២ របស់អធិការដ្ឋាននគរបាលខណ្ឌមានជ័យ។

-បានឃើញ មាត្រា ៤៤ និងមាត្រា ១២៤ នៃ ក្រមនីតិវិធីព្រហ្មទណ្ឌ។

ក្រោយពីបានពិនិត្យឯកសារខាងលើ

យល់ឃើញថា

១. ឈ្មោះ សៅ ភេទប្រុស អាយុ១៩ឆ្នាំ (នៅលីវ) ជាតិខ្មែរ មុខរបរកម្មករ ទីកន្លែងកំណើត ភូមិព្រៃប្រង់ ស្រុកបាភ្នំ ខេត្តព្រៃវែង , ទីលំនៅបច្ចុប្បន្ន ផ្ទះជួល ផ្លូវលេខ៣៥៧ ភូមិដើមស្លែង សង្កាត់ចោមចៅ២ ខណ្ឌមានជ័យ រាជធានីភ្នំពេញ ឪពុកឈ្មោះ សំ សៅ "ក" ម្ដាយឈ្មោះ ធឿន សុះ "ក" , ទោសពីមុនគ្មាន , ជានីតិជន ។

២. ឈ្មោះ សុខ ភេទប្រុស អាយុ២២ឆ្នាំ ជាតិខ្មែរ ទីលំនៅបច្ចុប្បន្ន ផ្ទះជួល ផ្លូវលេខ៣៥៧ ភូមិដើមស្លែង សង្កាត់ចោមចៅ២ ខណ្ឌមានជ័យ រាជធានីភ្នំពេញ ជានីតិជន។

-បានប្រព្រឹត្តអំពើដូចតទៅ[1] ៖ កាលពីថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០១២ វេលាម៉ោងប្រហែល១១និង00នាទី នៅចំណុច ផ្ទះជួល ផ្លូវលេខ៣៥៧ ភូមិដើមស្លែង សង្កាត់ចោមចៅ២ ខណ្ឌមានជ័យ រាជធានីភ្នំពេញ មានឈ្មោះ សែម ហៅ សេត (ជនរងគ្រោះ) និងឈ្មោះ សៅ និងឈ្មោះ សុខ (ជនសង្ស័យ) ព្រមទាំងមិត្តភក្តិពីរនាក់ទៀត នាំគ្នាផឹកស៊ី ពេលនោះជនរងគ្រោះ និងជនសង្ស័យឈ្មោះ សុខ មានទំនាស់ពាក្យសំដីគ្នាហើយជនសង្ស័យឈ្មោះ សៅ បានដាល់ទៅលើជនរងគ្រោះចំនួន០៤ដៃបណ្ដាលឱ្យមានរបួសភ្នែកខាងឆ្វេងហើមប៉ោង ហើយជនសង្ស័យឈ្មោះ សុខ បានយកដំបងឈើផ្អុងវាយទៅលើជនរងគ្រោះចំក្បាលពីក្រោយ បណ្ដាលឱ្យរបួស ហើយទំលាក់ឈើផ្អុងចោលរួចនាំគ្នារត់គេចខ្លួន ចំណែកជនរងគ្រោះបានក្រុមគ្រួសារបញ្ជូនទៅសង្គ្រោះនៅមន្ទីរពេទ្យ។ លុះដល់វេលាម៉ោង ១៦និង៣០នាទីថ្ងៃខែឆ្នាំដដែល ក្រុមគ្រួសារជនរងគ្រោះបានឃើញជនសង្ស័យឈ្មោះ សៅ ក៏ឃាត់ខ្លួនយកទៅប្រគល់ ឱ្យនគរបាលប៉ុស្តិ៍ចោមចៅ២តែម្ដង ចំណែកជនសង្ស័យឈ្មោះ សុខ គេចខ្លួនបាត់។

អំពើរបស់ឈ្មោះ សៅ ភេទប្រុស អាយុ១៩ឆ្នាំ (មានខ្លួន) , ឈ្មោះ សុខ ភេទប្រុស អាយុ២១ឆ្នាំ (គេចខ្លួន) ជាបទល្មើស ៖ ហិង្សាដោយចេតនាមានស្ថានទម្ងន់ ប្រព្រឹត្តនៅចំណុច ផ្ទះជួល ផ្លូវលេខ៣៥៧ ភូមិដើមស្លែង

---

[1] សេចក្ដីសង្ខេបអង្គហេតុ

សង្កាត់ច្បារអំពៅ២ ខណ្ឌមានជ័យ រាជធានីភ្នំពេញ កាលពីថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០១២ តាមបញ្ញត្តិមាត្រា ២១៨ នៃក្រមព្រហ្មទណ្ឌ ។

## ហេតុដូច្នេះ

បើកការស៊ើបសួរលើអង្គហេតុខាងលើ និង ៖

☑ ដាក់ឲ្យស្ថិតក្រោមការពិនិត្យ[២] ៖

១.ឈ្មោះ សៅ ភេទប្រុស អាយុ១៩ឆ្នាំ (មានខ្លួន)
២. ឈ្មោះ សុខ ភេទប្រុស អាយុ២១ឆ្នាំ (គេចខ្លួន)

☐ ដាក់ឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ[៣]៖.....................................................................................

☑ ដាក់ឱ្យស្ថិតនៅក្រោមការឃុំខ្លួនបណ្តោះអាសន្ន លើឈ្មោះខាងលើដើម្បីបង្ការ ឬបញ្ចប់បទល្មើស កុំឱ្យកើតឡើងជាថ្មី និងធានារក្សាជនត្រូវចោទទុកជូនតុលាការចាត់ការតាមនីតិវិធី៕

ធ្វើនៅរាជធានីភ្នំពេញ , ថ្ងៃទី....... ខែមិថុនា ឆ្នាំ២០១២

**តំណាងអយ្យការ**

---

[២]ឈ្មោះជនត្រូវចោទ

[៣] កាតព្វកិច្ចណាមួយដែលបានចែងក្នុងមាត្រា ២២៣

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

សាលាដំបូងរាជធានីភ្នំពេញ

បន្ទប់ស៊ើបសួរ "ក"
លេខ........................... តព្រ

## <u>ដីកាបង្គាប់ឱ្យចូលខ្លួន</u>

យើង ក ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ

បានឃើញមាត្រា ១៨៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

បានឃើញសំណុំរឿងព្រហ្មទណ្ឌលេខ .......... ចុះថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០១១ ។

បានឃើញដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលេខ ..................ចុះថ្ងៃទី២០ ខែឧសភា ឆ្នាំ២០១១។

ចោទប្រកាន់លើឈ្មោះ សៅ ហៅ វែង ភេទ ប្រុស អាយុ ២៣ឆ្នាំ ពីបទ អំពើលួច ដែលបានប្រព្រឹត្តនៅផ្ទះលេខ១២ ផ្លូវ១២៣ សង្កាត់បឹងត្របែក ខណ្ឌចំការមន រាជធានីភ្នំពេញ កាលពីខែមិថុនា ឆ្នាំ ២០១០ តាមមាត្រា ៣៥៣, ៣៥៦ នៃក្រមព្រហ្មទណ្ឌ។

បង្គាប់មកឈ្មោះ សៅ ហៅ វែង ភេទ ប្រុស អាយុ ២៣ឆ្នាំ សញ្ជាតិ ខ្មែរ ទីលំនៅផ្លូវលំ ក្រុម ១ភូមិ១ ឃុំទំនប់រលក ស្រុកស្ទឹងហាវ ខេត្តព្រះសីហនុ មុខរបរ បើកបររថយន្តក្រុមហ៊ុនវីង។

ឱ្យចូលខ្លួនមកកាន់សាលាដំបូងរាជធានីភ្នំពេញ បន្ទប់ស៊ើបសួរ "ក" នៅថ្ងៃទី.........ខែកញ្ញា ឆ្នាំ២០១១ វេលាម៉ោង ៨: ៣០ ព្រឹក ដើម្បីសួរចម្លើយ ពីដំណើររឿង អំពើលួច ។

សាមីខ្លួនត្រូវយកលិខិតផ្សេងៗ ដែលទាក់ទងនឹងរឿងខាងលើនេះមកជាមួយផង ប្រសិនបើមាន ។

ក្នុងករណីមិនចូលខ្លួនតាមកាលកំណត់ខាងលើនេះទេ <u>**យើងនឹងចេញដីកាបង្គាប់ឱ្យនាំខ្លួន**</u> ។

រាជធានីភ្នំពេញ. ថ្ងៃទី ........ខែ សីហា ឆ្នាំ ២០១១

**ចៅក្រមស៊ើបសួរ**

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងរាជធានីភ្នំពេញ

បន្ទប់ស៊ើបសួរ "ភ"

លខ .................. តព្រ

# ដីកាបង្គាប់ឱ្យនាំខ្លួន

យើង ភ ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ

បានឃើញមាត្រា ១៨៩ និងមាត្រាបន្តបន្ទាប់នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

បានឃើញសំណុំរឿងព្រហ្មទណ្ឌលេខ............... ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ២០១០ ។

បានឃើញដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលេខ........... ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១០ ។

ដែលចោទប្រកាន់លើឈ្មោះ សាន់ ភេទប្រុស អាយុ ៤១ឆ្នាំ សញ្ជាតិខ្មែរ មុខរបរ នាយកក្រុមហ៊ុនចំរើនកសិឧស្សាហកម្ម អភិវឌ្ឍន៍ (កម្ពុជា) អ៊ីមផត អិចផត ទីលំនៅបច្ចុប្បន្ន ផ្ទះលេខ ២២B ផ្លូវលេខ ០១ សង្កាត់ចោមចៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ ។

ពីបទ ឆបោក ប្រព្រឹត្តនៅ រាជធានីភ្នំពេញ កាលពីថ្ងៃទី២៣ ខែតុលា ឆ្នាំ២០០៩ តាមមាត្រា ៤៥ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

បានឃើញ ចំណារលើដីកាបង្គាប់ឱ្យចូលខ្លួន លើកទី៤ លេខ.......... ត.ព្រ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០១១ របស់លោក ខ នាយរងប៉ុស្តិ៍ចោមចៅ ។

យល់ឃើញថា :
- ជនត្រូវចោទ គេចវេសមិនព្រមទទួល ដីកាបង្គាប់ឱ្យចូលខ្លួនរបស់ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ ចំនួន ៤ លើកមកហើយ ។
- ជនត្រូវចោទមានអត្តសញ្ញាណច្បាស់លាស់ ។
- ជនត្រូវចោទរឹងទទឹង មិនព្រមចូលខ្លួនមកតុលាការ តាមដីកាបង្គាប់ឱ្យចូលខ្លួន ។

ដើម្បីធានាដល់ការស៊ើបសួរឱ្យបានពេញលេញ គប្បីសម្រេចនាំខ្លួនឈ្មោះ សាន់ ភេទប្រុស អាយុ ៤១ឆ្នាំ មកចំពោះមុខចៅក្រមស៊ើបសួរដើម្បីបំភ្លឺការពិត ។

## ហេតុដូច្នេះសម្រេច

១. ឱ្យនាំខ្លួនឈ្មោះ សាន់ ដែលមានអត្តសញ្ញាណខាងលើនេះ ។

២. បង្គាប់មកកងកម្លាំងសាធារណៈ ឱ្យចាប់ និងនាំខ្លួនឈ្មោះខាងលើនេះមកប្រគល់ជូន សាលាដំបូងរាជធានីភ្នំពេញ ដើម្បីចាត់ការតាមច្បាប់ ។

រាជធានីភ្នំពេញ, ថ្ងៃទី ......ខែកុម្ភៈ ឆ្នាំ២០១២

**ចៅក្រមស៊ើបសួរ**

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងរាជធានីភ្នំពេញ

បន្ទប់ស៊ើបសួរ "ភ"

លេខ .................. តព្រ

## ដីកាបញ្ជូនឱ្យឆ្លើយ

យើង ...............ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ

បានឃើញសំណុំរឿងព្រហ្មទណ្ឌលេខ............... ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ២០១០ ។

បានឃើញដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលេខ................ ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១០ ។

បានឃើញដីកាបង្គាប់ឱ្យចូលខ្លួនលេខ.................. ត.ព្រ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០១១ ។

បានឃើញចំណារ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១១ លើដីការបង្គាប់ឱ្យចូលខ្លួនលេខ............ ត.ព្រ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០១១ របស់ លោក ................ នាយរងប៉ុស្តិ៍ចោមចៅ ។

បញ្ជូនសំណុំរឿងទាក់ទងនឹងជនត្រូវចោទ៖

ឈ្មោះ .......... ភេទប្រុស អាយុ ៤១ឆ្នាំ សញ្ជាតិខ្មែរ មុខរបរ នាយកក្រុមហ៊ុនចំរើនកសិឧស្សាហកម្មអភិវឌ្ឍន៍ (កម្ពុជា) អ៊ីមផត អិចផត ទីលំនៅបច្ចុប្បន្ន ផ្ទះលេខ ២២ B ផ្លូវលេខ ០១ សង្កាត់ចោមចៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ ។

ដែលត្រូវដាក់ឱ្យនៅក្រោមការពិនិត្យពីបទ ឆបោក ប្រព្រឹត្តនៅ រាជធានីភ្នំពេញ កាលពីថ្ងៃទី២៣ ខែតុលា ឆ្នាំ ២០០៩ ទៅលោកព្រះរាជអាជ្ញា ដើម្បីផ្តល់យោបល់ ចេញដីកាបង្គាប់ឱ្យចាប់ខ្លួនជនត្រូវចោទខាងលើ ។

រាជធានីភ្នំពេញ, ថ្ងៃទី....... ខែមករា ឆ្នាំ២០១២

បានទទួលអនុវត្ត

**ក្រឡាបញ្ជី**

**ចៅក្រមស៊ើបសួរ**

## បណ្តឹងរបស់ព្រះរាជអាជ្ញា

យើង ........................................... ព្រះរាជអាជ្ញានៃអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ

បានឃើញដីកាបញ្ជូនឱ្យឆ្លើយខាងលើ

បានឃើញសំណុំរឿងស៊ើបសួរទាក់ទងនឹងឈ្មោះ ...................................................... ។

ក្រោយពីបានពិនិត្យសំណុំរឿងចប់សព្វគ្រប់ ស្នើសុំ ៖

☐..........................................................................................................

......................................................................................................... ។

រាជធានីភ្នំពេញ, ថ្ងៃទី ........ខែធ្នូ ឆ្នាំ២០១១

**ព្រះរាជអាជ្ញា**

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងរាជធានីភ្នំពេញ

បន្ទប់ស៊ើបសួរ "ភ"

លេខ .................... តព្រ

# ដីកាបង្គាប់ឱ្យចាប់ខ្លួន

យើង ឥ ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ

បានឃើញមាត្រា ១៩៥ និងមាត្រាបន្តបន្ទាប់នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

បានឃើញសំណុំរឿងព្រហ្មទណ្ឌលេខ ........... ចុះថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០១១ ។

បានឃើញដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលេខ.................... ចុះថ្ងៃទី២០ ខែឧសភា ឆ្នាំ២០១១។

បានឃើញដីកាបញ្ជូនឱ្យឆ្លើយលេខ............... តព្រ ចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១១ ដោយមានការឯកភាពពីលោកព្រះរាជអាជ្ញារងអមសាលាដំបូងរាជធានីភ្នំពេញ ។

ក្រោយពីបានពិនិត្យលើសំណុំរឿងចប់សព្វគ្រប់ យល់ឃើញថា :

នាមត្រកូល សុខ នាមខ្លួន សាន ហៅ វែង ភេទ ប្រុស អាយុ ២៣ឆ្នាំ សញ្ជាតិខ្មែរ ទីកន្លែងកំណើត សង្កាត់មិត្តភាព ខណ្ឌ៧មករា រាជធានីភ្នំពេញ ទីលំនៅបច្ចុប្បន្ន ផ្លូវលំ ក្រុម១ ភូមិ១ ឃុំទំនប់រលក ស្រុកស្ទឹងហាវ ខេត្តព្រះសីហនុ មុខរបរ បើកបររថយន្តក្រុមហ៊ុនវីង ឪពុកឈ្មោះ សុខ (រ) ម្តាយឈ្មោះ សៅ (រ)នៅលីវ ។

ត្រូវចោទប្រកាន់ពីបទ អំពើលួច ដែលបានប្រព្រឹត្តនៅផ្ទះលេខ១២ ផ្លូវ១២៣ សង្កាត់បឹងត្របែក ខណ្ឌចំការមន រាជធានីភ្នំពេញ កាលពី ខែមិថុនា ឆ្នាំ២០១០ តាមមាត្រា ៣៥៣, ៣៥៦ នៃក្រមព្រហ្មទណ្ឌ។

**យល់ឃើញថា** : -បទល្មើសខាងលើជាបទមជ្ឈិម ដែលច្បាប់តម្រូវឱ្យផ្តន្ទាទោស ពី៦ខែ ទៅ៣ឆ្នាំ ។

-ជនត្រូវចោទមិនព្រមចូលបង្ហាញខ្លួនតាមដីកាបង្គាប់ឱ្យចូលខ្លួនលេខ .......... ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០១១ របស់ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ ។

## ហេតុដូច្នេះសម្រេច

១. ឱ្យចាប់ខ្លួនឈ្មោះសុខ សាន ហៅ វែង ភេទ ប្រុស អាយុ ២៣ឆ្នាំ ដែលមានអត្តសញ្ញាណខាងលើនេះ ។

២. បញ្ជាដល់កងកម្លាំងសាធារណៈ ឱ្យស្រាវជ្រាវរកចាប់ និងនាំខ្លួនឈ្មោះខាងលើនេះ មកប្រគល់ជូនសាលាដំបូងរាជធានីភ្នំពេញ ដើម្បីចាត់ការតាមច្បាប់ ។

រាជធានីភ្នំពេញ, ថ្ងៃទី........ ខែមករា ឆ្នាំ២០១២

**ចៅក្រមស៊ើបសួរ**

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូង

.......................................

មន្ទីរស៊ើបសួរ

សំណុំរឿងលេខ.............................

លេខស៊ើបសួរ...............................

# កំណត់ហេតុស្តីពីការបង្ហាញខ្លួនលើកដំបូង

(មាត្រា ១៤៣, ១៤៤, ២៤០ និងមាត្រា ២៤១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ)

ឆ្នាំពីរពាន់............... ខែ.............. ថ្ងៃទី............ វេលាម៉ោង...................................

យើង.................................................................ចៅក្រមស៊ើបសួរនៃសាលាដំបូង

...........................អមដោយលោក/លោកស្រី........................................ ជាក្រឡាបញ្ជី។

និងដោយមានវត្តមានលោក/លោកស្រី........................................ ជាអ្នកបកប្រែ ។

បុគ្គលដែលនៅចំពោះមុខយើង បានផ្តល់ព័ត៌មានអំពីអត្តសញ្ញាណដូច ខាងក្រោម ៖

នាមត្រកូល ៖ ............................ នាមខ្លួន ៖ ..........................................................

កើតថ្ងៃទី ៖ ......................................................................................................

ទីកន្លែងកំណើត ៖ ..............................................................................................

អាសយដ្ឋាន ៖ ...................................................................................................

មុខរបរ ៖ .........................................................................................................

នៅលីវ ☐ ឬរៀបការ ☐ ឈ្មោះប្តី ឬប្រពន្ធ.............................................. កូន..........

សញ្ជាតិ ៖ .........................................................................................................

ឪពុកឈ្មោះ........................................."រ-ស" ម្តាយឈ្មោះ......................................... "រ-ស"

អនីតិជន ☐ ឬនីតិជន ☐

☐ជននេះបានប្រកាសប្រាប់ថា ខ្លួនមានអំណាចមេបាលើក្មេងអាយុ ក្រោម ១០ (ដប់) ឆ្នាំ ដែលស្ថិតនៅលំនៅបច្ចុប្បន្ន។

ប្រវត្តិនៃការផ្តន្ទាទោសដោយតុលាការ....................................................................

☐ជននេះ ៖ ☐ចេះនិយាយ ☐ ចេះអាន ☐ចេះសរសេរអក្សរខ្មែរ

☐ជននេះ[1] ៖ ☐មិនចេះនិយាយ ☐មិនចេះអាន ☐មិនចេះសរសេរអក្សរខ្មែរ

បន្ទាប់ពីបានផ្ទៀងផ្ទាត់អត្តសញ្ញាណរបស់ជននេះ យើងបានប្រាប់ដល់ជននេះឲ្យដឹងយ៉ាងច្បាស់អំពីរឿងក្តីដែលព្រះរាជអាជ្ញាបានប្តឹងមកយើង តាមរយៈដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលេខ................. ចុះថ្ងៃទី........ខែ............ឆ្នាំ................ ដែលជាហេតុនាំឲ្យមានការបង្ហាញខ្លួនជននេះនៅចំពោះមុខយើង ព្រមទាំងប្រាប់ជននេះឲ្យដឹងអំពីបទចោទប្រកាន់ចំពោះរឿងក្តីដូចខាងក្រោម[2] ៖

.........................................................................................................................

.........................................................................................................................

.........................................................................................................................

☐យើងបានជូនដំណឹងដល់ជននេះថា យើងគ្រោងនឹងដាក់ជននេះឲ្យស្ថិតនៅក្រោមការពិនិត្យចំពោះរឿងក្តីដែលយើងទើបនឹងរៀបរាប់ឲ្យជននេះដឹងយ៉ាងច្បាស់។

☐លោក/លោកស្រី........................................................ មេធាវី[3]នៃជនត្រូវចោទ ដែលត្រូវបានកោះហៅនៅថ្ងៃទី........ខែ............ឆ្នាំ.............. ហើយដើម្បីឲ្យលោក/លោកស្រីមេធាវីអាចត្រៀមរៀបចំការពារកូនក្តីខ្លួនបាន។

☐យើងបានប្រាប់ដល់ជននេះអំពីសិទ្ធិទទួលបានជំនួយមេធាវី ដែលជននេះអាចជ្រើសរើសពឹងមេធាវីដោយខ្លួនឯង ឬអាចសុំឲ្យគេចាត់តាំងមេធាវីណាម្នាក់ឲ្យបគាត់។

☐យើងបានប្រាប់ផងដែរដល់លើជននេះថា ប្រសិនបើមិនធ្វើការជ្រើសរើសពឹងមេធាវីដោយខ្លួនឯងទេ មេធាវីមួយរូបនឹងត្រូវចាត់តាំងដោយឯកឯង ដោយសារតែជននេះជាអនីតិជន។

ជននេះបានប្រកាសប្រាប់ថា ៖

☐ ខ្ញុំជ្រើសរើសមេធាវីដោយខ្លួនឯង

☐ ខ្ញុំស្នើសុំឲ្យចាត់តាំងមេធាវីមួយរូបឲ្យបខ្ញុំ

☐ ខ្ញុំបដិសេធជំនួយពីមេធាវី

យើងបានប្រាប់ដល់ជនត្រូវចោទថា គាត់មានសិទ្ធិអាចនៅស្ងៀមមិនផ្តល់ចម្លើយក៏បាន ឬអាចធ្វើសេចក្តីប្រកាសផ្សេងៗ ឬអាចឲ្យយើងសួរចម្លើយក៏បាន។

ជននេះ បានប្រកាសប្រាប់ថា ៖ ..........................................................................................

.........................................................................................................................

.........................................................................................................................

---

[1] ក្នុងករណីដែលជននេះមិនចេះភាសាខ្មែរ ត្រូវសរសេរអត្តសញ្ញាណរបស់អ្នកបកប្រែចូលក្នុងកំណត់ហេតុ

[2] រឿងហេតុដែលចោទប្រកាន់ និងបទល្មើស

[3] ករណីមានមេធាវី

លោក/លោកស្រីមេធាវី.................................................................... បានផ្ដល់សេចក្ដីកត់សម្គាល់ការពារថា ...........................................................................................
.............................................................................................................................
.............................................................................................................................

□យើងបានជូនដំណឹងដល់ជននេះថា យើងសម្រេចដាក់គាត់ឲ្យស្ថិតនៅក្រោមការពិនិត្យ ៖

□ ចំពោះអង្គហេតុទាំងអស់ដែលយើងបានប្រាប់ឲ្យដឹង។

□ចំពោះតែអង្គហេតុដែលរៀបរាប់ខាងក្រោម ដែលយើងបញ្ជាក់ប្រាប់ជននេះអំពីឈ្មោះនៃបទល្មើស ៖ ...........................................................................................
.............................................................................................................................
.............................................................................................................................

□យើងបានប្រាប់ដល់ជនត្រូវចោទ អំពីសិទ្ធិក្នុងការសុំឲ្យយើងធ្វើកិច្ចស៊ើបសួរមួយ ឬច្រើន ឬក៏អាចធ្វើពាក្យប្ដឹងសុំមោឃភាពនៃកិច្ចស៊ើបសួរដោយផ្អែកតាមមូលដ្ឋាននៃមាត្រា ២៥៣ ប្ដឹងឧទ្ធរណ៍តាមបញ្ញត្តិមាត្រា ២៦៧ នៅក្នុងពេលនៃដំណើរការនៃការស៊ើបសួរក្នុងលក្ខខណ្ឌដែលមានចែងក្នុងមាត្រា ២៧០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

□យើងបានប្រាប់ដល់ជនត្រូវចោទ អំពីសិទ្ធិក្នុងការជ្រើសរើសមេធាវីសម្រាប់នីតិវិធីបន្ទាប់មកទៀត ហើយប្រសិនបើមិនបានធ្វើការជ្រើសរើសមេធាវីដោយខ្លួនឯងទេ និងបើសិនជាមានសំណើសុំ យើងនឹងចាត់តាំងមេធាវីមួយរូបជូន (សម្រាប់តែក្នុងករណីដែលជនត្រូវចោទមិនបានជ្រើសរើសពឹងពាក់មេធាវីដោយខ្លួនឯង និងមិនបានស្នើសុំឲ្យចាត់តាំងមេធាវីឲ្យ)។

ជនត្រូវចោទ បានប្រកាសប្រាប់ថា ៖

□ ខ្ញុំជ្រើសរើសពឹងពាក់មេធាវីដោយខ្លួនឯង

□ ខ្ញុំស្នើសុំឲ្យចាត់តាំងមេធាវីមួយរូបឲ្យខ្ញុំ

□ ខ្ញុំបដិសេធជំនួយពីមេធាវី

□យើងបានប្រាប់ដល់ជនត្រូវចោទថា គាត់អាចសុំឲ្យបិទការស៊ើបសួរបាននៅ ក្រោយពេលផុតរយៈពេលមួយឆ្នាំ ដោយអនុវត្តតាមបទប្បញ្ញត្តិនៃមាត្រា ២៨៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

□យើងបានប្រាប់ដល់ជនត្រូវចោទថា នៅថ្ងៃនេះយើងសម្រេចឃុំខ្លួនគាត់បណ្ដោះអាសន្ន។

□យើងបានប្រាប់ដល់ជនត្រូវចោទថា នៅថ្ងៃនេះយើងសម្រេចដាក់គាត់ឲ្យនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ និងប្រាប់ឲ្យគាត់អំពីកាតព្វកិច្ចទាំងឡាយដែលគាត់ត្រូវគោរព។

☐យើងបានប្រាប់ដល់ជនត្រូវចោទថា យើងសម្រេចមិនឃុំខ្លួន (ឲ្យនៅ ក្រៅឃុំ)។

☐យើងបានប្រាប់ដល់ជនត្រូវចោទថា ៖

- គាត់ត្រូវប្រកាសអំពីអាសយដ្ឋានដែលអាចជាអាសយដ្ឋានផ្ទាល់ ខ្លួន ឬជាអាសយដ្ឋានរបស់តតិយជនណាម្នាក់ ដែលទទួលបន្ទុក ទទួលយកលិខិតដែលបញ្ជូនទៅឲ្យគាត់ ប្រសិនបើគាត់អាចផ្តល់ឲ្យភ្លាមនូវការព្រមព្រៀងជាលាយល័ក្ខណ៍អក្សររបស់តតិយជននោះ
- អាសយដ្ឋានដែលត្រូវប្រកាសប្រាប់ត្រូវមានទីតាំងស្ថិតនៅ.............................................
..................................................................................................................

អាសយដ្ឋាននេះ ជា ☐ អាសយដ្ឋានផ្ទាល់ខ្លួន

☐ អាសយដ្ឋានរបស់ ៖ ..........................................

☐យើងបានប្រាប់ដល់ជនត្រូវចោទបន្ថែមថា ៖

- រហូតដល់ការបិទការស៊ើបសួរ គាត់ត្រូវប្រាប់ដល់យើងគ្រប់ការផ្លាស់ប្តូរអាសយដ្ឋានដែលត្រូវបានប្រកាសប្រាប់ខាងលើ ដោយការប្រកាសជាថ្មី ឬដោយលិខិតអនុសិដ្ឋ
- គ្រប់ការជូនដំណឹង ឬការឲ្យដំណឹងដែលបញ្ជូនទៅអាសយដ្ឋានដែលបានប្រកាសប្រាប់ចុងក្រោយបង្អស់ត្រូវចាត់ទុកថា ជូនដំណឹងដល់បុគ្គលជនត្រូវចោទ

☐យើងបានឲ្យជនត្រូវចោទឲ្យអានឡើងវិញ នូវសេចក្តីប្រកាសទាំងអស់របស់ខ្លួនដែលយើងបានកត់ចម្លងចូលក្នុងកំណត់ហេតុនេះ ហើយបើមិនបដិសេធត្រង់ចំណុចណាទេឲ្យចុះហត្ថលេខាលើកំណត់ហេតុនេះ។

☐បានអានឲ្យស្តាប់ចប់សព្វគ្រប់ ហើយជនត្រូវចោទមិនមានបដិសេធចំណុចណាទេ និងបានចុះហត្ថលេខាជាមួយយើង និងក្រឡាបញ្ជី។

☐បានអានចប់សព្វគ្រប់ដោយអ្នកបកប្រែ ហើយជនត្រូវចោទមិនមានបដិសេធចំណុចណាទេ និងបានចុះហត្ថលេខាជាមួយយើង ក្រឡាបញ្ជី និងអ្នកបកប្រែ។[4]

**អ្នកបកប្រែ ជនត្រូវចោទ មេធាវី ក្រឡាបញ្ជី ចៅក្រមស៊ើបសួរ**

---

[4] គ្រប់ទំព័រត្រូវអនុវត្តតាមមាត្រា ២៤១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងខេត្ត**
.........................
**មន្ទីរស៊ើបសួរ**

សំណុំរឿងលេខ:.................................
លេខស៊ើបសួរ:....................................

## កំណត់ហេតុស្តីពីការពិភាក្សាដេញដោលចំពោះមុខ[1]

(មាត្រា ២០៣ និងមាត្រាបន្តបន្ទាប់នៃក្រមនីតិវិធីព្រហ្មទណ្ឌ)

ឆ្នាំពីរពាន់............. ខែ............. ថ្ងៃទី................. វេលាម៉ោង.................................

យើង........................................................ ចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្ត ........................... អមដោយលោក/លោកស្រី......................................... ជាក្រឡាបញ្ជី ។

និងដោយមានវត្តមានលោក/លោកស្រី......................................... ជាអ្នកបកប្រែ ។

យោងតាមដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលេខ.................. ចុះថ្ងៃទី...........ខែ .................. ឆ្នាំ.......................... ។

បានមកបង្ហាញខ្លួននៅក្នុងដំណាក់កាលស៊ើបសួរនៅចំពោះមុខយើង ជនដែលមានអត្តសញ្ញាណដូចខាងក្រោម៖

| | |
|---|---|
| នាមត្រកូល | ៖.......................... នាមខ្លួន ៖............................................ |
| កើតថ្ងៃទី | ៖............................................................................ |
| ទីកន្លែងកំណើត | ៖............................................................................ |
| អាសយដ្ឋាន | ៖............................................................................ |
| មុខរបរ | ៖............................................................................ |

---

[1] កំណត់ហេតុនេះ ត្រូវធ្វើឡើងបន្តពីកំណត់ហេតុស្តីពីការបង្ហាញខ្លួនលើកដំបូង (នៅក្នុងថ្ងៃតែមួយ)

| | | | |
|---|---|---|---|
| នៅលីវ ☐ | ឬរៀបការ ☐ ឈ្មោះប្តី ឬប្រពន្ធ ៖.............................. មានកូន.......... | | |
| សញ្ជាតិ | ៖.................................................................................. | | |
| ឪពុកឈ្មោះ.............................. ។-ស៊ ម្តាយឈ្មោះ.............................. ។-ស៊ អនីតិជន | | | |
| ☐ ឬនីតិជន ☐ | | | |
| ☐ជននេះបានប្រកាសប្រាប់ថា ខ្លួនមានអំណាចមេបាលើក្មេងអាយុក្រោម ១០ (ដប់) ឆ្នាំ ដែលស្ថិតនៅលំនៅបច្ចុប្បន្ន ។ | | | |
| ប្រវត្តិនៃការផ្តន្ទាទោសដោយតុលាការ:.................................................................................. | | | |
| ☐ជននេះ ៖ | ☐ចេះនិយាយ | ☐ ចេះអាន | ☐ចេះសរសេរអក្សរខ្មែរ |
| ☐ជននេះ[2] ៖ | ☐មិនចេះនិយាយ | ☐មិនចេះអាន | ☐មិនចេះសរសេរអក្សរខ្មែរ |

ជននេះត្រូវបានដាក់ឲ្យស្ថិតនៅក្រោមការពិនិត្យ ពីបទ៖..................................................

អំពើដែលមានចែង និងផ្តន្ទាទោសដោយមាត្រា..........នៃច្បាប់...........................................

................................................................................................ ។

យោងតាមដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលេខ...................... ចុះថ្ងៃទី.............. ខែ............... ឆ្នាំ....................... ។

☐ដោយមានវត្តមាន លោក/លោកស្រីមេធាវី......................................... ដែលជនត្រូវចោទ បានជ្រើសរើសពឹងពាក់ដោយខ្លួនឯង ឬដែលត្រូវបានចាត់តាំងដោយគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា បានមកបង្ហាញខ្លួននៅក្នុងបន្ទប់នៅចំពោះមុខយើង បន្ទាប់ពីបានពិគ្រោះមើលសំណុំរឿង និងបានធ្វើទំនាក់ទំនងដោយសេរីជាមួយនឹងជនត្រូវចោទ នៅពេលបង្ហាញខ្លួនជាលើកដំបូងនៅចំពោះមុខយើង ។

☐យើងបានប្រាប់ដល់ជនត្រូវចោទថា យើងមានបំណងសម្រេចឃុំខ្លួនគាត់ជាបណ្តោះអាសន្ន ។

☐យើងបានប្រាប់ថា ជនត្រូវចោទអាចស្នើសុំពន្យារពេលដើម្បីរៀបចំការពារខ្លួន ។

☐យើងក៏បានបញ្ជាក់ប្រាប់ជនត្រូវចោទដែរថា យើងនឹងសម្រេចអំពីការឃុំខ្លួនបណ្តោះអាសន្ននៅថ្ងៃនេះ ។

---

[2]ក្នុងករណីដែលជននេះមិនចេះភាសាខ្មែរ ត្រូវសរសេរអត្តសញ្ញាណរបស់អ្នកបកប្រែចូលក្នុងកំណត់ហេតុ

□ជនត្រូវចោទមិនទាន់មានជំនួយពីមេធាវីនៅឡើយ ហើយយើងបានបញ្ជាក់ប្រាប់ថា ជនត្រូវចោទមានសិទ្ធិទទួលបានជំនួយពីមេធាវីតាមការជ្រើសរើសដោយខ្លួនឯង ឬពីមេធាវីតាមការចាត់តាំង ។

ជនត្រូវចោទបានប្រកាសប្រាប់ថា៖

□ខ្ញុំបដិសេធជំនួយពីមេធាវី

□ខ្ញុំចង់បានជំនួយពីមេធាវីម្នាក់

□លោក/លោកស្រីមេធាវី............................................ ត្រូវបានជូនដំណឹងដោយ ............................................ អាចពិគ្រោះមើលសំណុំរឿងដែលទុកឲ្យគាត់ពិនិត្យ និងអាចសន្ទនាដោយសេរីជាមួយកូនក្តីរបស់គាត់ ។

ការពិភាក្សាដេញដោលចំពោះមុខទាក់ទងនឹងការឃុំខ្លួនបណ្តោះអាសន្ន៖

□ត្រូវបានធ្វើ

□ត្រូវបានលើកទៅថ្ងៃទី........ខែ............ឆ្នាំ...............តាមសំណូមពររបស់.............. ...............................។

តំណាងអយ្យការបានបង្ហាញសេចក្តីសន្និដ្ឋានរបស់ខ្លួន ដូចខាងក្រោម៖

..........................................................................................................................

..........................................................................................................................

